ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ៣៥ឆ្នាំកន្លងផុតទៅ ភាពគង្វង់ក្នុងរបបប្រល័យពូជសាសន៍
- ការរៀបចំសំណាង ការប្រឈមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអង្គជំនុំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ១៦៩ ខែមករា ឆ្នាំ២០១៤

# ស្វែងរកការពិត

លេខ១៦៩ ខែមករា ឆ្នាំ២០១៤

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ៣៥ឆ្នាំកន្លងផុតទៅ ភាពតក់ស្លុតនៅក្នុងរបបប្រល័យ ..........១

**ផ្នែកឯកសារ**

◆ "កុំស្មានបងភ្លេច" បន្លាញពីប្រលឹងមនុស្ស ..........៤

◆ ថោង ស៊ីវ៉ាម៉ុន ពីប៉ារីស មកស-២១ ..........៥

◆ ចម្លើយសារភាពរបស់ យូ ដួស បញ្ញាការ ..........៦

◆ ចម្លើយ ចាន់ ថុល ហៅ ប៉ូល យោធា ..........១១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កុំស្មានបងភ្លេច ខ្មែរបាត់បង់តន្ត្រីរ៉ក ..........១៣

◆ ខ្សែភាពយន្តរំឭកពីប្រវត្តិសាស្ត្រ វប្បធម៌ និង ..........១៦

◆ មួយរាត្រីនៅទសវត្សរ៍៦០ ..........២០

◆ ឱ! ភ្នំពេញអើយ ..........២២

◆ ចាន់ ស៊ាន់ ហៅ សាម ក្នុងបដិវត្តន៍ ..........២៤

◆ រឿង ស៊ីន "អតីតកាល នៅតែធ្វើឲ្យខ្ញុំ ..........២៦

◆ ហេតុផលសំខាន់ៗដែលនាំឲ្យខ្មែរក្រហម ..........២៩

◆ ដំណើរជីវិត ព្រុំ គីម ក្នុងរបបខ្មែរក្រហម ..........៣២

◆ ការរើសអើងជនជាតិវៀតណាមនៅតែជា ..........៣៤

**ផ្នែកច្បាប់**

◆ ការរៀបចំសំណាង ការប្រឈមរបស់ ..........៤០

◆ ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់ ..........៤៨

**វេទិកាពិភាក្សាសាធារណៈ**

◆ តម្លៃនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា ..........៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតគ្រួសារម្ដាយខ្ញុំក្នុងរបបខ្មែរក្រហម ..........៥៤

◆ ដេង កេង បាត់បង់ប្ដីជារៀងរហូត ..........៥៦

◆ ហម រុំ ខ្មែរក្រហមសម្លាប់ប្ដីរបស់ខ្ញុំ ..........៥៨

◆ រឿងរ៉ាវរបស់ ឈុន វ៉ាត ..........៦០



ទូច សៀងតាណា អតីតតន្ត្រីករនៅក្រុមតន្ត្រីបាយ័ន

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ :*** *សយ សូលីដា, ម៉ែន សូនីតា, អេរិច ហាសប៊េត, សុខ វណ្ណៈ, ទី លីកូ, ហួរ ហាច, ឡុង ដានី, គ្រីស្ទីន ប័រគ័រលី, វ៉ាន់ថាន់ ពៅដារ៉ា, ភូល ស្រីនាថ, អ៊ុំ ណាត្រី, កោ សែប, មីន សាណាស់ និង រ៉េត ណៃហ៊ីរ* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា* ***អ្នកបកប្រែ :*** *នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត* ***និពន្ធនាយកទូទៅ :*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក :*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ :*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ :*** *ឆេង វ៉េង*

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ៣៥ឆ្នាំកន្លងផុតទៅ... ភាពគថ្លង់នៅក្នុងរបបប្រល័យពូជសាសន៍

ក្នុងនាមជាសាក្សីមួយរូបដែលបានឆ្លងកាត់ភាពព្រៃផ្សៃនៃរបបខ្មែរក្រហម និងក្នុងនាមជាអ្នកស្រាវជ្រាវម្នាក់ដែលបានចំណាយពេលវេលាជាច្រើនឆ្នាំដើម្បីសិក្សាស្រាវជ្រាវ និងចងក្រងឯកសារ អំពីរឿងរ៉ាវរបស់បុគ្គលដែលបានឆ្លងកាត់ ទទួលរងគ្រោះ និងស្លាប់ក្រោមរបបខ្មែរក្រហម ខ្ញុំតែងតែគិតខ្លួនឯងថាខ្ញុំយល់ពីទិដ្ឋភាពជាច្រើននៃប្រវត្តិសាស្ត្រខ្មែរក្រហម ។ ជាការពិតខ្ញុំបានរៀនសូត្រអំពីរឿងរ៉ាវភាពនៃមនុស្សជាតិគ្រប់បែបយ៉ាងទាំងអស់របស់ប្រជាជនកម្ពុជាដែលឆ្លងកាត់របបខ្មែរក្រហម ។ គ្មានពេលណាមួយដែលខ្ញុំមិនកោតនិងស្ងើចសសើរដល់ស្មារតីដ៏អង់អាចរឹងមាំ និងដ៏អស្ចារ្យរបស់ប្រជាជនកម្ពុជានោះទេ ។ ក៏ប៉ុន្តែមានពេលខ្លះខ្ញុំបានជួបរឿងរ៉ាវផ្សេងៗទៀតហើយរឿងទាំងនោះធ្វើឲ្យខ្ញុំរឹតចង់ដឹងចង់ឮកាន់តែខ្លាំងថែមទៀតនូវអ្វីដែលខ្ញុំធ្លាប់បានដឹងរួចមកហើយ ។

បងស្រីរបស់ខ្ញុំឈ្មោះ កែវ កុលធីតា ឯកសក័ កើតនៅឆ្នាំ១៩៥៩ ។ គាត់មានពិការភាពជាមនុស្សគតាំងពីកំណើត ។ គាត់គឺជាបងស្រីពៅក្នុងចំណោមបងស្រីទាំងប្រាំនាក់របស់ខ្ញុំ ។ ដោយសារតែគាត់ជាមនុស្សគ អ្នកផ្សេងទៀតមិនសូវជាមកនិយាយលេងសំណេះសំណាលជាមួយគាត់ប៉ុន្មានទេ ។ គាត់ក៏មិនមានសមត្ថភាពទំនាក់ទំនងជាមួយអ្នករាល់គ្នាដែរ លើកលែងតែអ្នកដែលចេះភាសាកាយវិការតែប៉ុណ្ណោះ ។ ហេតុដូច្នេះ ក្នុងសកម្មភាព និងទំនាក់ទំនងប្រចាំថ្ងៃ គាត់ធ្វើកិច្ចការអ្វីៗដោយខ្លួនឯងទាំងស្រុង ហើយមានតែមនុស្សមួយចំនួនប៉ុណ្ណោះដែលមានការអត់ធ្មត់និងចង់ស្គាល់គាត់ ។ ម្តាយរបស់ខ្ញុំ ឈ្មោះ កែវ ណាន ដែលសព្វថ្ងៃមានវ័យ៨៥ឆ្នាំ តែងតែមើលថែទាំបងស្រីខ្ញុំយ៉ាងយកចិត្តទុកដាក់ខ្លាំងណាស់ ។ ដោយសារតែបងស្រីខ្ញុំមានអាយុខុសគ្នាតែពីរឆ្នាំ ខ្ញុំហើយនិងគាត់ហាក់បីដូចជាមិត្តដ៏ស្និទ្ធស្នាលដូច្នេះដែរ ។ ក៏ប៉ុន្តែនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចយើងទាំងពីរនាក់ក៏ព្រាត់ប្រាស់គ្នា ហើយយើងមិនដែលបានជួបមុខគ្នាទេរហូតដល់របបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ។

នៅពេលដែលខ្ញុំនិងបងស្រីខ្ញុំជួបគ្នាឡើងវិញក្រោយរបបខ្មែរក្រហម យើងទាំងពីរនាក់ភ្លេចភាសាកាយវិការដែលយើងធ្លាប់ប្រើសម្រាប់ទំនាក់ទំនងគ្នាកាលពីមុនរបបខ្មែរក្រហម ហើយអស់រយៈពេលជាច្រើនឆ្នាំយើងមិនសូវមានទំនាក់ទំនងជាមួយគ្នាច្រើនទេ ។ ខ្ញុំដឹងថា អស់រយៈពេលដែលយើងមិនសូវបានជួបមុខគ្នាបងស្រីខ្ញុំតែងមានវិធីសាស្ត្រផ្សេងៗដើម្បីប្រាប់អ្នកដទៃអំពី



បងស្រីរបស់លោក ឆាំង យុ កែវ កុលធីតា ឯកសក្ក នៅភ្នំពេញ

អារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ ។ ក្រោយរបបខ្មែរក្រហម គាត់បានបង្រៀនខ្លួនឯងឲ្យចេះគូររូប គូរគំនូរនៅលើផ្ទាំងក្រណាត់ដើម្បីប្រាប់អ្នកដទៃអំពីអារម្មណ៍របស់គាត់ ។

ថ្មីៗនេះគាត់ត្រូវបានរកឃើញថាមានជំងឺមហារីកដំណាក់កាលចុងក្រោយ ។ ជំងឺនេះធ្វើឲ្យខ្ញុំចំណាយពេលវេលាច្រើននៅក្បែរគាត់ ។ ខ្ញុំនិងបងស្រីខ្ញុំបានទៅមើលផ្ទះចាស់ដែលគ្រួសាររបស់យើងធ្លាប់រស់នៅកាលពីមុនរបបខ្មែរក្រហមនៅម្តុំទួលគោក និងបានរៀបរាប់ពីប្រវត្តិដើមអំពីការស្លាប់ និងការបាត់ខ្លួនសមាជិកគ្រួសារជាទីស្រលាញ់របស់យើង ។ ចំណុចខ្លះពេលដែលខ្ញុំកំពុងនិយាយធ្វើឲ្យគាត់នឹកឃើញដល់បទពិសោធរបស់គាត់កាលពីរបបខ្មែរក្រហម ដែលមកទល់ពេលនេះមានរយៈពេល៣៥ឆ្នាំ ហើយ ។

នៅក្នុងរបបខ្មែរក្រហម បងស្រីខ្ញុំធ្វើការនៅសហករណ៍ដោយដាំដំឡូង និងកាប់ឆ្ការព្រៃក្រោមការត្រួតត្រារបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីដឹកនាំដោយ តាម៉ុក និងយាយចែម ។ តាម៉ុក គឺជាអតីតមេបញ្ជាការយោធាម្នាក់របស់កងយោធាខ្មែរក្រហម ។ មេភូមិមកពីភូមិភាគនិរតីគឺជាស្ត្រីវ័យក្មេងចំនួនបីរូប គឺ សមមិត្តនារី ម៉ន, សមមិត្តនារី ហាន និងសមមិត្តនារី អូន ។ កម្មាភិបាលទាំងបីនេះ មានអាយុប្រហាក់ប្រហែលនឹងបងស្រីខ្ញុំដែរ ។ ដូចអ្នកដទៃទៀតដែរ បងស្រីរបស់ខ្ញុំខិតខំត្រដររស់នៅដោយស្មារតីសម្បជញ្ញៈរបស់គាត់ ។ នៅពេលដែលគាត់ឃ្លានខ្លាំងគាត់បានស្វែងរកឫសឈើស្លឹកឈើ និងសត្វល្អិតនានាដើម្បីហូបជាអាហារ ។ ថ្ងៃមួយគាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់បាន ។ ក្នុងរបបខ្មែរក្រហម អង្គការគឺជាម្ចាស់កម្មសិទ្ធិលើអ្វីគ្រប់យ៉ាងទាំងអស់ មិនថាដំណាំបន្លែ ផ្លែឈើទេ សូម្បីតែសត្វល្អិតនិងឈើព្រៃក៏ជាកម្មសិទ្ធិរបស់អង្គការដែរ ។ កម្មាភិបាលខ្មែរក្រហមបានឃើញបងស្រីខ្ញុំ ហូបឫសដំឡូងជ្វាដែលគាត់ជីកបាន ហើយក៏បានចាប់



ក្មួយ និងបងស្រីរបស់លោក ឆាំង យុ ថតនៅពេលទៅចូលរួមពិធីបុណ្យនៅវត្ត

ខ្លួនគាត់ភ្ជាមដោយចងដៃគាត់ទៅក្រោយ ។ កម្មាភិបាលទាំងនោះគ្រាន់តែដេរស្តីគាត់ ហើយក៏ដោះលែងគាត់ទៅវិញ ។

ខ្ញុំនិងបងស្រីខ្ញុំបានសន្ទនាជាមួយគ្នាដោយភាសាកាយវិការអស់រយៈពេលជាច្រើនម៉ោងអំពីបទពិសោធរបស់គាត់ ។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ គាត់ចាំថា កាលនោះខ្ញុំនៅផ្ទះតែម្នាក់ឯងរីឯអ្នកដទៃទៀតបានភៀសខ្លួនទៅកន្លែងផ្សេងបាត់អស់ទៅហើយ ។ គាត់បានប្រាប់ខ្ញុំទៀតថា ក្នុងរបបខ្មែរក្រហមគាត់ចង់ដឹងរាល់ថ្ងៃថាតើមានរឿងអ្វីកើតឡើងចំពោះខ្ញុំព្រោះពេលនោះ ខ្ញុំនិងគាត់មិនបាននៅជាមួយគ្នាទេ ។ គាត់បានរំឭកអំពីការស្លាប់ដោយខ្វោចផ្សាររបស់កូនស្រីរបស់បងស្រីយើងម្នាក់ឈ្មោះ តាន់ កែវកេតនា កើតក្នុងឆ្នាំ១៩៧៥ ការស្លាប់របស់ឪពុកយើង និងការបាត់ខ្លួនសមាជិកគ្រួសារដទៃទៀតរបស់យើង ។ នៅពេលដែលខ្ញុំដឹងពីប្រវត្តិរឿងរ៉ាវរបស់គាត់ ខ្ញុំមានអារម្មណ៍ក្តុកក្តួលនិងរំជួលចិត្តយ៉ាងខ្លាំង ។ ខ្ញុំគិតថា ខ្ញុំជាមនុស្សមានសំណាងណាស់ដែលបានដឹងពីប្រវត្តិរបស់គាត់ ហើយពេលនោះដែរ ខ្ញុំមានអារម្មណ៍ទុក្ខសោក និងមានអារម្មណ៍ថាបានធ្វើខុសយ៉ាងខ្លាំងចំពោះគាត់ ។

ដោយសារតែគាត់គឺជាមនុស្សគ មិនសូវមាននរណាមកសួរនាំគាត់អំពីបទពិសោធគាត់កាលពីរបបខ្មែរក្រហមទេ ។ អស់រយៈពេលសាមសិបប្រាំឆ្នាំក្រោយរបបខ្មែរក្រហម ខ្ញុំមិនទាំងដឹងពីរឿងពិតរបស់គាត់កាលពីរបបខ្មែរក្រហមផង ។ នៅពេលដែលខ្ញុំសន្ទនាជាមួយគាត់អំពីរឿងរ៉ាវជីវិតរបស់គាត់ដែលគាត់បានទទួលរងកាលពីរបបខ្មែរក្រហមធ្វើឲ្យខ្ញុំជឿងឆ្ងល់ថា តើបទពិសោធរបស់គាត់មានលក្ខណៈខុសពីអ្នកផ្សេងយ៉ាងដូចម្តេចព្រោះគាត់ជាមនុស្សគ និងឆ្ងល់ថាតើគាត់មានកម្លាំង និងប្រាជ្ញាស្មារតីអ្វីខ្លះដើម្បីធ្វើឲ្យគាត់អាចរស់រានមានជីវិតពីរបបខ្មែរក្រហមបាន ។

ខ្ញុំក៏មានការជឿងឆ្ងល់ដែរថាតើមានមនុស្សពិការ និងមានវិបត្តិផ្លូវចិត្តប៉ុន្មាននាក់ទៀតដែលទទួលរងទុក្ខតែម្នាក់ឯងបែបនេះ ។ តើមានរឿងរ៉ាវប៉ុន្មានទៀតដែលត្រូវបានបំភ្លេចចោល មើលរំលង ហើយមិនដែលដឹងរឿងរ៉ាវរបស់អ្នកទាំងនោះទាល់តែសោះនោះ ។

សោកនាដកម្មដែលមិនអាចជៀសផុតនៃរបបឃោរឃៅទ្រង់ទ្រាយធំទាំងឡាយ គឺជាការបាត់បង់ប្រវត្តិសាស្ត្រ ។ ក៏ប៉ុន្តែក្រោយពីបានរៀនសូត្រនិងសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំយល់ឃើញថាសាច់រឿងរបស់បងស្រីខ្ញុំ គឺជាសក្ខីកម្មមួយដើម្បីឲ្យយើងឆ្លុះបញ្ចាំងឲ្យឃើញថាតើកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអម្បាលម៉ានដើម្បីទាមទារយុត្តិធម៌នៅមានកម្រិតខ្វះខាតប៉ុណ្ណា ។ បងស្រីខ្ញុំមិនទាំងដឹងថាមាន តុលាការមួយដើម្បីស្វែងរកយុត្តិធម៌សម្រាប់ប្រទេសកម្ពុជាផង ។

រឿងរ៉ាវរបស់បងស្រីខ្ញុំធ្វើឲ្យខ្ញុំពិចារណាសាជាថ្មីនូវអ្វីដែលខ្ញុំធ្លាប់អះអាងថាខ្ញុំដឹងច្រើនពីរបបខ្មែរក្រហមហើយខ្ញុំមានជំនឿថាសាច់រឿងរបស់គាត់គឺជាការលំបាកមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។ នៅប្រទេសកម្ពុជា យើងមិនអាចនិយាយអំពីប្រជាធិបតេយ្យ យុត្តិធម៌ ឬសិទ្ធិមនុស្សដោយគ្មានគិតពីប្រវត្តិសាស្ត្រនោះទេ ។ ដើម្បីនិយាយអំពីប្រធានបទអ្វីមួយក្នុងចំណោមប្រធានបទទាំងនេះគឺតម្រូវឲ្យមានការបកស្រាយពីបញ្ហាមួយផ្សេងទៀត ដោយជៀសមិនផុត ។

សាច់រឿងនិងបទពិសោធរបស់បងស្រីខ្ញុំគឺជាសាច់រឿងមួយផ្នែកតូចនៃរបបខ្មែរក្រហម ហើយក៏ជាសាច់រឿងផ្ទាល់ខ្លួនសម្រាប់ខ្ញុំដែរ ។ ដូចគ្នាទៅនិងអ្នកមានពិការភាពពីកំណើតផ្សេងទៀតដែរ ដែលមិនមានលទ្ធភាពក្នុងការនិយាយចេញមក សាច់រឿងរបស់បងស្រីខ្ញុំបានបង្កជាឧបសគ្គដល់យើងដើម្បីវាយតម្លៃអំពីនិយមន័យនៃពាក្យយុត្តិធម៌និងដើម្បីវាយតម្លៃថា តើយើងបានធ្វើអ្វីគ្រប់យ៉ាងអស់ ហើយឬនៅសម្រាប់អ្នក ដែលមិនមានសំឡេងដើម្បីប្រាប់យើងនោះ ។

**ឆាំង យុ**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# «កុំស្មានបងភ្លេច» បង្ហាញពីព្រលឹងមនុស្ស

ចំណែកលោក ឆាំង យុ បាននិយាយថា “កុំស្មានបងភ្លេច ៈ ខ្មែរបាត់បង់តន្ត្រី រ៉ក់ អេន រ៉ូល មិនមែនគ្រាន់តែបង្ហាញអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជាប៉ុណ្ណោះទេ តែក៏បានបង្ហាញអំពីរឿងរ៉ាវព្រលឹងរបស់មនុស្ស និងកិច្ចខិតខំស្រាវជ្រាវរបស់ជាតិទាំងមូលដើម្បីឲ្យឃើញអំពីអត្តសញ្ញាណរបស់ខ្លួន ក្រោយពីសង្គ្រាម និងរបបប្រល័យពូជសាសន៍ ។ ខ្សែភាពយន្តឯកសារនេះបានបង្ហាញនូវរូបភាព និងសំឡេងរបស់កម្ពុជាដែលបានបំភ្លេចចោលជាយូរមកហើយកាលពីមុនសង្គ្រាមវៀតណាម ។ ខ្សែភាពយន្តនេះ បាននាំទស្សនិកជនទៅរកយុគសម័យមួយដែលពោរពេញទៅដោយជីវិតស្រស់បំព្រងនិងទាន់សម័យរបស់តន្ត្រីករខ្មែរ ។ ពេលសម្លឹងទៅមើលអតីតកាលដែលកម្ពុជាធ្លាប់ជាប្រទេសមួយដ៏សុខក្សេមក្សាន្ត និងរីកចម្រើន ទស្សនិកជនតែងតែឆ្ងល់ថា តើប្រទេសជាតិ និងរីកចម្រើនបែបណា បើសិនជាគ្មានសង្គ្រាមកើតឡើង? ខ្សែភាពយន្តនេះបាននាំយើងទាំងអស់គ្នាឲ្យស្គាល់ពីក្រអៅចិត្តនៃលក្ខណ្ឌរបស់មនុស្ស រវាងភាពស្រស់ស្អាតដ៏អស្ចារ្យ និងភាពរន្ធត់ដែលមិនអាចវាស់ស្ទង់បាន ហើយខ្សែភាពយន្តនេះបានបន្សល់ឲ្យយើងនូវការដាស់តឿនរំឭកស្មារតីមួយថា សូម្បីតែសង្គ្រាមដ៏សាហាវព្រៃផ្សៃក៏មិនអាចបំផ្លាញព្រលឹងរបស់មនុស្សជាតិបានឡើយ» ។

**ឆាំង យុ**



រូបពីឆ្វេងទៅស្តាំ ៈ ចន ពីរ៉ូហ្ស៊ី ផលិតកររឿង “កុំស្មានបងភ្លេច”, វិស្វករ វណ្ណ ម៉ូលីវណ្ណ, ឆាំង យុ ប្រធានផលិតកម្មរឿង “កុំស្មានបងភ្លេច”, លីនដា ប្រពន្ធនិងកូនរបស់ ចន ពីរ៉ូហ្ស៊ី និងខាងស្តាំបង្អស់ កូនរបស់លោក វ៉ាន់ មូលីវណ្ណ ថតនៅសាលសន្និសីទចតុមុខ កាលពីខែមករា ឆ្នាំ២០១៤ ។

# ថោង ស៊ីវ៉ាម៉ុន ពីប៉ារីស មកប៉េកាំង មកស-២១

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពD៥៨៩៨៨*

ថោង ស៊ីវ៉ាម៉ុន ហៅ ជឿន ត្រូវអង្គការចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៨ ។ នៅចុងបញ្ចប់នៃឯកសារចម្លើយសារភាពកម្រាស់បួនទំព័រ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៨ មានកំណត់ត្រាលើចម្លើយសារភាពថា ៖

១) ជឿន ជាប់ជំពាក់ជាមួយឪពុកបង្កើតវាផង ឪពុកក្មេកវាផង ។ អាចជាសេអ៊ីអា ។

២) ពេលនៅបារាំង មានការទាក់ទងជាមួយ សុគុន និង សូកាន

ខាងក្រោមនេះគឺជាចម្លើយសារភាពរបស់ ថោង ស៊ីវ៉ាម៉ុន ប៉ុន្តែយើងមិនដឹងថាតើការសារភាពរបស់គាត់ពិតឬយ៉ាងណានោះទេ ព្រោះគាត់ត្រូវឆ្លងកាត់ការធ្វើទារុណកម្មពីអ្នកសួរចម្លើយ ។

ជឿន មានអាយុ២៧ឆ្នាំ កើតនៅសង្កាត់លេខ៦ ក្រុងភ្នំពេញ ។ គាត់មានឪពុកឈ្មោះ ថោង ម៉ាម៉ុត គ្រូខាងជាងដែកនៅសាលាដែកគីឡូលេខ៦ ។ ក្រោយមក ម៉ាម៉ុត ផ្លាស់ទៅធ្វើការនៅក្រសួងហិរញ្ញវត្ថុ ។

នៅអាយុ៦ឆ្នាំ ជឿន ចូលរៀនថ្នាក់ទី១២ (សង្គមចាស់) នៅសាលាព្រះជ័យជេស្ដា ភ្នំពេញ ។

នៅឆ្នាំ១៩៦៦ ជឿន ប្រលងជាប់ចូលរៀនថ្នាក់ទី៦ នៅវិទ្យាល័យទួលគោក ។ ដល់ឆ្នាំ១៩៦៧ គាត់បានផ្លាស់មករៀននៅថ្នាក់ទី៥ នៅវិទ្យាល័យយុគន្ធរវិញ ។ នៅក្នុងពេលនោះ គាត់មានមិត្តម្នាក់ឈ្មោះ សុក តូស៊ីម៉ាណូ ជាកូនរបស់ សុខ តូប៊ិនឡា នាយកកីឡាដ្ឋានខាងផ្នែកហែលទឹក ។

នៅឆ្នាំ១៩៦៩ ជឿន រៀនដល់ថ្នាក់ទី៣ ហើយសំណាក់រៀននៅផ្ទះ សុក តូស៊ីម៉ាណូ ។

នៅឆ្នាំ១៩៧០ គាត់រៀនថ្នាក់ទី២នៅសាលាយុគន្ធរដដែល ពេលនោះក៏បានស្គាល់បដិវត្តន៍តាមរយៈ តូស៊ីម៉ាណូ ។ ដល់ឆ្នាំ១៩៧២ ជឿន ទាក់ទងស្រឡាញ់បងប្អូនរបស់ តូស៊ីម៉ាណូ ឈ្មោះ ស៊ីវណ្ណា រហូតបានគ្នាជាគ្រួសារ ។ ស៊ីវណ្ណា ជាកូនស្រីរបស់ សុខ តូសាឌុម ជាពេទ្យព្យាបាលសម្ដេចព្រះ នរោត្តម សីហនុ ផ្ទាល់ ។

នៅឆ្នាំ១៩៧២ ដោយ លន់ នល់ រកចាប់ឪពុកក្មេក និងឪពុកម្ដាយរបស់គាត់ ទើបគាត់រត់ទៅនៅស្រុកបារាំងដោយឆ្លងកាត់ស្រុកអារញ្ញ ប្រទេសសៀម ។ ពេលទៅនៅស្រុកបារាំង ជឿន បានចូលរៀនអក្សរចិន និងអក្សរបារាំងនៅសាកលវិទ្យាល័យវ៉ាំងសែន នៅក្រុងប៉ារីស ។

នៅខែតុលា ឆ្នាំ១៩៧២ ជឿន ជួបជាមួយឈ្មោះ អោក សុគុន នៅប្រទេសបារាំង ។ ពេលនោះ គាត់បានសុំ សុគុន ធ្វើជាសមាជិករណសិរ្ស គឺចូលបដិវត្តន៍ ។ រយៈពេលនៅរៀនឯស្រុកបារាំង ជឿន ស៊ីឈ្នួលលីសែងទំនិញឲ្យអ្នកជំនួញបារាំងនៅប៉ារីស ហើយឆ្លៀតពេលទៅជួយបោះកាសែត អា.កា.អ៊ី ជាមួយ អោក សុគុន និង អ៊ិន សូកាន ។

ឆ្នាំ១៩៧៤ សុគុន បានបញ្ជូន ជឿន មកក្រុងប៉េកាំង ។ ពេលមកនៅប៉េកាំង អង្គការឲ្យ ជឿន រៀនបច្ចេកទេសពេទ្យ ។

នៅខែតុលា ឆ្នាំ១៩៧៥ ជឿន ត្រឡប់មកកម្ពុជាវិញ ដោយធ្វើការនៅក្រសួងការបរទេស ផ្នែកបង្កើតផល ។ នៅទីនោះ អង្គការចាត់តាំងគាត់ឲ្យទៅធ្វើស្រែនៅស្ទឹងត្រង់ ភូមិភាគខត្តរ ក្រោមការដឹកនាំរបស់ អឿន ជាគណៈស្រុក ។

នៅខែមករា ឆ្នាំ១៩៧៦ អង្គការបានឲ្យ ជឿន មកនៅមន្ទីរ ក-១៧ ភ្នំពេញខាងបង្កើតផលដដែល ជាមួយឈ្មោះ ទី ភាគ, ម៉េង ហួត និង ហ៊ីង អ៊ុន ។

នៅមន្ទីរក-១៧ ជឿន បានបង្កទំនាស់ជាមួយអ្នកនៅជាប់គ្នា ។ បាតុភាពរួមគ្នានៅពេលប្រធានមន្ទីរហៅប្រជុំនាំគ្នាស្រែកជ័យឃោសដើម្បីបញ្ឈឺចិត្ត ឬថ្កើងមាត៌ាបក្សដោយគ្មានការចាត់តាំង ។ បំផុសគ្នាវាយប្រហារ និងបង្កទំនាស់ជាបន្តបន្ទាប់ ។

នៅខែមីនា ឆ្នាំ១៩៧៨ អង្គការចាប់ខ្លួន ជឿន តែម្ដង ។

**សោម ប៊ុនថន**

# ចម្លើយសារភាពរបស់ យូ ផូស បញ្ជាការអនុសេនាធំ០៨

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពJ០០៥៩០*

យូ ផូស មុនចាប់ខ្លួនមាននាទីជាបញ្ជាការអនុសេនាធំលេខ០៨ ក្នុងវរសេនាតូចលេខ៣៣២ វរសេនាធំ៣៣ កងពល៧០៣ ។ ក្នុងឯកសារចម្លើយសារភាពដែលមានកម្រាស់៥៨ទំព័រ យូ ផូស បានរៀបរាប់ពីសកម្មភាពរបស់ខ្លួន និងខ្សែសន្ទាក់ក្នុងការបំផ្លាញអង្គការបដិវត្តន៍ ចាប់តាំងពីមុន និងចូលបម្រើក្នុងជួរបដិវត្តន៍ ។ នៅក្របខាងក្រៅនៃចម្លើយសារភាព បានសរសេរថា ចម្លើយសារភាពរបស់ យូ ផូស លើកទី១ នេះសរបញ្ជាក់ឲ្យឃើញថា យូ ផូស អាចត្រូវឲ្យសរសេរចម្លើយសារភាពរបស់ខ្លួនលើសពីមួយលើក ។ ជាពិសេសឯកសារចម្លើយសារភាពនេះ ត្រូវបានពិនិត្យ និងមានចំណារដោយ ឌុច ប្រធានគុកទួលស្លែង ឬមន្ទីរសន្តិសុខស-២១ អំពីការវិភាគលើខ្លឹមសារចម្លើយរបស់ផូស ដែលមានឈ្មោះ អឿនជាអ្នកសួរចម្លើយ និងឈ្មោះ ចាន់ ជាអ្នកសង្ខេបខ្លឹមសារឡើងវិញ សម្រាប់ផ្ញើទៅអង្គការលើពិនិត្យ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ យូ ផូស អំពីសកម្មភាពក្បត់អង្គការបដិវត្តន៍ៈ

ខ្ញុំឈ្មោះ យូ ផូស អាយុ ២៥ឆ្នាំ នៅលីវ ។ មុនអង្គការចាប់ខ្ញុំទទួលនាទីបញ្ជាការ អនុសេនាធំ០៨ ក្នុងវរសេនាតូច៣៣២ វរសេនាធំ៣៣ កងពល៧០៣ ។ ខ្ញុំកើតនៅភូមិព្រែកគ្រួស ឃុំព្រែកអំបិល ស្រុក២០ តំបន់២៥ ។

ចាប់តាំងពីខ្ញុំដឹងក្តីមក ខ្ញុំបានរស់នៅជាមួយឪពុកម្តាយខ្ញុំរហូតដល់ឆ្នាំ១៩៦០ ទើបឈ្មោះ ឃុត អតីតមេឃុំព្រែកអំបិល មកសុំឪពុកខ្ញុំ ដើម្បីយកខ្ញុំទៅនៅជាមួយ ។ ខ្ញុំបានរស់នៅជាមួយឃុតដល់ឆ្នាំ១៩៦៣ ទើបឃុតឲ្យខ្ញុំចូលរៀននៅសាលាវត្តកំពតពុល ហើយបានអប់រំខ្ញុំថា «ឯងទៅរៀន ត្រូវដើរស៊ើបពិនិត្យ មើលសិស្ស បើឃើញខ្មែរក្រហមចូលមកបំផុសកូនសិស្សត្រូវប្រាប់អញ ត្រូវក្តាប់មើលប្រជាជនក្នុងភូមិយើងនេះផង» ។ ខែមិថុនា ឃុត ប្រាប់ខ្ញុំថា ត្រូវទាក់ទងបួននាក់ទៀត ដែលមានឈ្មោះ ប៉ោះ បច្ចុប្បន្ននៅកងពល៨០១, វន បច្ចុប្បន្ននៅកងពល៨០១, ទូច បច្ចុប្បន្ននៅកងពល៨០១ និងស្រ៊ុន បច្ចុប្បន្ននៅកងពល៨០១ ដោយឲ្យយើងទាំងអស់គ្នា ដើរស៊ើបពិនិត្យមើលសិស្ស និងប្រជាជនពីព្រែកអំបិលរហូតដល់ភូមិព្រែកគ្រួស ។ ការដើរស៊ើបពិនិត្យរបស់ខ្ញុំនៅក្នុងសាលា និងតាមភូមិរហូតដល់ឆ្នាំ១៩៧០ ខ្ញុំឥតបានឃើញ និងជួបប្រទះអ្វីទេ ។

លុះដល់ខែមេសា ឆ្នាំ១៩៧០ ពេលនោះវៀតណាមបានវាយមកដល់សំប៉ាន ក្នុងនោះខ្ញុំ និងឈ្មោះ សាយ កំពុងអង្គុយនៅក្នុងសាលាដំណាក់ក្បែរផ្លូវ ខ្ញុំឃើញ ឃុត ជិះកង់ត្រហេបត្រហបមក ឈប់ប្រាប់ខ្ញុំ និង សាយ ថា ចូលទំពនឹងគេទៅ ហើយទៅនៅជាមួយឈ្មោះ វ៉ាត ពីព្រោះខ្ញុំឲ្យ វ៉ាត នេះចូលមុនយូរហើយ ហើយ ឃុត ក៏ជិះកង់ហួសទៅ ។ ដល់ថ្ងៃទី២ ខែមេសា ឆ្នាំ ១៩៧០ ទើបខ្ញុំ និង សាយ នាំគ្នាចូលទៅនៅជាមួយ វ៉ាត នាទីអនុសេនាធំក្នុងអង្គភាពវៀតណាម ។ ដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧០ ទើប វ៉ាត នាំខ្ញុំ និងសុាយ ឲ្យទៅជួបឈ្មោះ ផល នាទីបញ្ជាការអនុសេនាតូច៧០៥ កងពល៧០៣ បច្ចុប្បន្នក្បត់, ជឿន នាទីយុទ្ធជននៅក្នុងអង្គភាព វ៉ាត និង យ៉ា (ក្តាប់មិនបាន) ដើម្បីទាក់ទងស្គាល់គ្នាមុន ។ ក្រោយមកទើប វ៉ាត បានហៅខ្ញុំទាំងអស់គ្នាមកអប់រំណែនាំ គឺ

◆ ឲ្យដើរបំផុសបំផុលប្រជាជនក្នុងភូមិឲ្យគាំទ្រ និងជួយឧបត្ថម្ភវៀតណាម ទាំងស្បៀងអាហារ ទាំងទីកន្លែងរស់នៅ ។

◆ បំផុសកូនចៅប្រជាជន ឲ្យចូលធ្វើកងទ័ពបម្រើវៀតណាម

ក្រោយពី វ៉ាត បានណែនាំរួច ខ្ញុំ, សាយ, ជឿន និង យ៉ា បានដើរធ្វើសកម្មភាពដើរបំផុសប្រជាជនក្នុងភូមិឲ្យគាំទ្រ និងឧបត្ថម្ភវៀតណាម រហូតឲ្យកូនចៅចូលទៅបម្រើអង្គភាពវៀតណាម ។ ខែឧសភា ឆ្នាំ១៩៧០ អង្គភាពវៀតណាមបែករំលែកគ្នាជាពីរ មួយផ្នែកទៅសង្ឃ៍ និងសីវ៉ា មួយផ្នែកទៀតនៅទន្លេបាសាក់ ។ ពេលនោះខ្ញុំ និង ផល មកនៅសង្ឃ៍ និងសីវ៉ា ក្រោមការដឹកនាំរបស់ ទីសឹង វៀតណាម នាទីស្នងការវរសេនាតូចវៀតណាម ។ ទីសឹង បានចាត់

តាំង ផល ឲ្យនាទី ជាអនុបញ្ជាការអនុសេនាធំ និងខ្ញុំនៅក្នុងក្រុមនីរសារ និងជាអ្នកដាំបាយ ។ ទីសឹង បានអប់រំខ្ញុំនិងផល ថា វៀតណាម កម្ពុជា គឺសាច់មួយឈាមមួយជាមួយគ្នា ហើយខ្ញុំមកនេះ គឺមកវាយរំដោះប្រជាជន ខ្មែរដែលចក្រពត្តិអាមេរិកឈ្លានពាន ។

ដល់ខែមិថុនា ឆ្នាំ១៩៧១ ទើប ផល បានយកខ្ញុំមកបញ្ចូលជាសមាជិកបក្សពលករវៀតណាម នៅពេលនោះបានរៀបចំពិធីត្រឹមត្រូវ អ្នកនាំចូលមានពីររូប គឺ ទីសឹង និង ផល នេះ និងមានអ្នកប្រកាសទទួលស្គាល់ឈ្មោះ ទីសាញ់ វៀតណាម នាទីស្នងការវរសេនាតូចវៀតណាម ។ នៅពិធីបញ្ចូលនេះ ទីសាញ់ បានអប់រំខ្ញុំថា ឯងត្រូវធ្វើការប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ព្រោះឈ្មោះនេះគឺជាបក្សក្លែងក្លាយ មិនបរិសុទ្ធទេ ឯបក្សបរិសុទ្ធ គឺបក្សពលករកម្ពុជា ដែលមានប្រវត្តិយូរលង់ណាស់ ក្នុងការតស៊ូបដិវត្តន៍កន្លងមកដល់បច្ចុប្បន្ន ពិសេស ដូចជាបដិវត្តន៍វៀតណាមជាដើម ។ បន្ទាប់ពីស្តាប់ការណែនាំរបស់ ទីសឹង មក ខ្ញុំ និង ផល បានធ្វើសកម្មភាពដើរបំផុសប្រជាជនដែលនៅក្នុងភូមិនីមួយៗ ឲ្យប្រជាជនជួយឧបត្ថម្ភវៀតណាម តាំងពីត្រី សាច់ បន្លែបង្កា និងផ្ទះសម្បែង រហូតដល់ប្រជាជនសុខចិត្តឲ្យកូន ឲ្យចៅ ធ្វើកងទ័ពបម្រើអង្គភាពវៀតណាម បានជាបន្តបន្ទាប់ ។ រហូតដល់ខែ កញ្ញា ឆ្នាំដដែល ពេលនោះ ខ្ញុំបានឃើញវៀតណាមដកកាំភ្លើងខ្មែរ និងបញ្ជូនខ្មែរទៅស្រុកយួន ហើយ បើនរណាមិនទៅនឹងបាញ់សម្លាប់ចោល ពេលនោះ ខ្ញុំបានហៅ ផល មកនិយាយប្រាប់ថា ខ្ញុំគិតរត់ទៅផ្ទះហើយ ពីព្រោះខ្ញុំឃើញវៀតណាមបាញ់ខ្មែរយើងចោលច្រើនណាស់ ហើយមួយទៀត ខ្ញុំឃើញវៀតណាម យកខ្មែរទៅស្រុកយួនច្រើនណាស់ ។ ក្រោយមកទើបខ្ញុំ និង ផល នាំគ្នារត់ចេញពីអង្គភាពវៀតណាម រហូតមកដល់ផ្ទះរៀងៗខ្លួន ។

ខែសីហា ឆ្នាំ១៩៧២ ខ្ញុំបានចូលធ្វើបដិវត្តន៍នៅភូមិជ្រោយតាកែវ ឃុំជ្រោយតាកែវ ស្រុក១៨ តំបន់២៥ ដោយមាន ផល ជាអ្នកនាំចូល ពេលនោះ ផល មាននាទីជាស្នងការអនុសេនាតូច ៧០៥ កងពល៧០៣ ដោយយកខ្ញុំមកនៅក្រុមនីរសារក្នុងមន្ទីរអនុសេនាតូច២១ ។

លុះដល់ខែវិច្ឆិកា ឆ្នាំ១៩៧២ ទើបឈ្មោះ ផល បានឲ្យខ្ញុំយកសំបុត្រទៅឲ្យឈ្មោះ ដៃ មុនី លេខាស្រុក១៨ តំបន់២៥, ស៊ីន សាឌី អនុលេខា ស្រុក១៨ តំបន់២៥, យិត ប្រធានឈ្លប ភូមិពាមឃ្លាំង ឃុំពាមទោល ស្រុក១៨ តំបន់២៥, យិន ប្រធានឈ្លបភូមិពាមទោល ឃុំពាមទោល ស្រុក១៨ តំបន់២៥, ឆិល ប្រធានឈ្លបភូមិអណ្តូង ឃុំពាមទោល ស្រុក១៨ តំបន់២៥ និងឈ្មោះ ទៀក អតីតមេភូមិចាស់ នៅភូមិអណ្តូង ឃុំពាមទោល ស្រុក១៨ តំបន់២៥ នាទីជាប្រធានឃុំពាមទោល ស្រុក១៨ តំបន់២៥ ។ ចំពោះសំបុត្រនេះដែលឈ្មោះ ផល បានឲ្យខ្ញុំរត់យកទៅឲ្យ ដៃ មុនី, ស៊ីន សាឌី, ទៀក, យិត, យិន និងឆិល គឺ ផល មានផែនការសំខាន់ ៣យ៉ាង គឺៈ

- ◆ បំផុសប្រជាជននៅក្នុងឃុំពាមទាំងអស់ឲ្យរត់ចូលតំបន់ខ្មាំង
- ◆ បំផុសប្រជាជនឲ្យបញ្ចេញស្បៀងឲ្យខ្មាំង
- ◆ ផែនការកសាងកម្លាំងក្បត់នៅតាមភូមិ

ដល់ក្រោយមកទៀត ទើប ផល ឲ្យខ្ញុំទាក់ទងជាមួយបក្ខពួកដែលនៅក្នុងអង្គភាពមានៈ សារឿន ជាស្នងការអនុសេនាតូច ក្នុងអនុសេនាធំ២១ ប្រចាំស្រុក១៨ តំបន់២៥ បច្ចុប្បន្នក្នុង វរសេនាតូច១២១ ក្នុងកងពល៨០១, ស៊ាន នាទីបញ្ជាការអនុសេនាតូច ក្នុងអនុសេនាធំ២១ ប្រចាំ ស្រុក១៨ តំបន់២៥ បច្ចុប្បន្ននៅក្នុងវរសេនាតូច១២១ ក្នុងកងពល៨០១, អឿន នាទីបញ្ជាការ អនុសេនាតូច ក្នុងអនុសេនាធំ២១ ប្រចាំស្រុក១៨ តំបន់២៥ បច្ចុប្បន្ននៅក្នុងវរសេនាតូច១២១ ក្នុងកងពល៨០១, ផុល នាទីមេក្រុមក្នុងអនុសេនាធំ២១ ប្រចាំស្រុក១៨ តំបន់២៥ បច្ចុប្បន្ននៅក្នុងវរសេនាតូច១២១ ក្នុងកងពល៨០១, អ៊ុន នាទីប្រធានក្រុមកងការពារមន្ទីរស្រុក១៨ តំបន់២៥ បច្ចុប្បន្ននៅក្នុងវរសេនាតូច ១២១ កងពល៨០១, សុន នាទីប្រធានមន្ទីរស្រុក១៨ តំបន់២៥ បច្ចុប្បន្ននៅក្នុងវរសេនាតូច១២១ កងពល៨០១ ។ ក្រោយមក ផល បានហៅខ្ញុំ និងអ្នកទាំងអស់នេះ មកប្រជុំប្រាប់ផែនការឲ្យបក្ខពួកនៅក្នុងអង្គភាពធ្វើគឺៈ

- ◆ បំផុសប្រជាជនឲ្យរត់ចូលទៅតំបន់ខ្មាំង
- ◆ បំផុសប្រជាជនឲ្យបញ្ចេញស្បៀងឲ្យខ្មាំង
- ◆ ផែនការរៀបចំកម្លាំងយោធានាំប្រជាជនទៅតំបន់ខ្មាំង
- ◆ ផែនការកសាងខ្សែនៅក្នុងប្រជាជន

លុះដល់ខែមេសា ឆ្នាំ១៩៧៣ ទើប ផល បានដកកម្លាំងនៅ

ក្នុងអង្គភាពអនុសេនាធំ២១ ប្រចាំស្រុក១៨នេះទៅអង្គភាពវរសេនាតូច១២១ ប្រចាំតំបន់២៥ ពេលនោះ ផល បានដកខ្ញុំ និងបក្ខពួកបីនាក់មានៈ សារឿន, អ៊ុន និងសុន ឲ្យមកនៅជាមួយឈ្មោះ សិទ្ធិ ស្នងការវរសេនាតូច១២១ ប្រចាំតំបន់២៥ បច្ចុប្បន្នលេខស្រុក ១៨ តំបន់២៥ ។ នៅជាមួយ សិទ្ធិដប់ថ្ងៃ ទើប សិទ្ធិ បានណែនាំខ្ញុំឲ្យទៅទាក់ទងបក្សពួកដែលនៅអង្គភាពមាន បួននាក់គឺៈ ហឿង, សុន, អ៊ឹម អន និង សារិន ព្រមទាំងណែនាំឲ្យយើងទាំងអស់គ្នាធ្វើសកម្មភាពនៅសមរភូមិគឺៈ

◆ បំផុសយុទ្ធជនឲ្យរត់ចោលខ្សែត្រៀម និងបាញ់ដៃខ្លួនឯង ។

◆ ពេលវាយនៅក្នុងសមរភូមិ ត្រូវធ្វើតេអូរទាក់ទងគ្នាលែងកើត ។

◆ ពេលវាយនៅក្នុងសមរភូមិ ត្រូវបង្អត់បាយយុទ្ធជន ។

រហូតដល់ខែឧសភា ឆ្នាំ១៩៧៣ ទើប សិទ្ធិ ឲ្យខ្ញុំ និង សារិន ទៅនៅក្នុងកងវរសេនាតូច១២១ តំបន់២៥ ដែលនៅក្រោមការដឹកនាំរបស់ឈ្មោះ សុទ្ធ ស្នងការវរសេនាតូច តំបន់២៥ ។ ក្រោយមក សុទ្ធ យកខ្ញុំទៅបញ្ចូលជាសមាជិក សេ.អ៊ី.អា ជាមួយមនុស្សពីរនាក់ទៀតគឺ លន និងអ៊ុន ដែលមានឈ្មោះ ផល និង សុទ្ធ ជាអ្នកនាំចូល ។ បន្ទាប់ពីធ្វើពិធីបញ្ចូលរួច សុទ្ធ បានអប់រំណែនាំថា ត្រូវធ្វើការប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាគ្រប់សកម្មភាព ទាំងនយោបាយ យោធា ទាំងសេដ្ឋកិច្ច និង វប្បធម៌ ដើម្បីបម្រើឲ្យភារកិច្ច សេ.អ៊ី.អា នេះឲ្យបានសម្រេចដល់ទិសដៅ ។ ក្រោយពីចូល សេ.អ៊ី.អា ហើយ ទើប សុទ្ធ ឲ្យខ្ញុំទាក់ទងបក្ខពួកដែលនៅក្នុងអង្គភាពមាន ៈ ធា នាទីអនុបញ្ជាការ វរសេនាតូច៧០៥ កងពល៧០៣, ឃួន នៅវរសេនាតូច១២១ កងពល៨០១, ចូ នៅកងវរសេនាតូច១២១ កងពល៨០១, អ៊ុន នៅកងវរសេនាតូច១២១ កងពល៨០១, ក្រុះ នៅកងវរសេនាតូច១២១ កងពល៨០១, ឆន បញ្ជាការអនុសេនាធំ វរសេនាតូច៧០៦ កងពល៧០៣ និងឈ្មោះ មាន នៅកងវរសេនាតូច១២១ កងពល៨០១ ។ សុទ្ធ បានហៅអ្នកទាំងអស់គ្នា ព្រមទាំងរូបខ្ញុំ មកប្រជុំប្រាប់ផែនការគឺៈ

◆ ពេលនាំទ័ពចូលសមរភូមិ ត្រូវធ្វើឲ្យវង្វេងផ្លូវក្នុង កុំឲ្យចូលដឹកត្រង់សេបាន

◆ ចំពោះបន្ទាយណាដែលពិនិត្យបានហើយត្រូវធ្វើឲ្យបែកការ

◆ បំផុសយុទ្ធជនឲ្យរត់ចោលខ្សែត្រៀមទៅផ្ទះ

◆ បំផុសប្រជាជនឲ្យរត់ចូលតំបន់ខ្មាំង ។

ក្រោយពីឈ្មោះ សុទ្ធ បានប្រាប់ផែនការហើយ ចំពោះបក្ខពួកខ្ញុំក៏បានធ្វើសកម្មភាពបានគឺៈ

◆ ពេលដែលនាំទ័ពចូលសមរភូមិព្រែកជី ចំពោះបក្ខពួកខ្ញុំបាននាំទ័ពបង្វែងផ្លូវ រហូតដល់ជិតភ្លឺ ដឹក ត្រង់សេលែងកើត ក៏ត្រឡប់មកវិញ ។

◆ ចំពោះបន្ទាយព្រែកក្រសា ក្រោយពីពិនិត្យបានហើយ បក្ខពួកខ្ញុំបានយកខ្សែទៅទាញមីន ភ្លើងឲ្យផ្ទុះ ដើម្បីកុំឲ្យសម្រេចផែនការវាយបន្ទាយ

◆ បំផុសប្រជាជនឲ្យរត់ទៅតំបន់ខ្មាំងបានបីគ្រួសារ ដោយក្នុងបក្ខពួកបានអប់រំថា នៅក្នុងតំបន់ រំដោះដូចជាប់គុកអីចឹងទៅណាមិនបាន ចង់ហូបអីក៏មិនបាន រកស៊ីពិបាក ធ្វើអ្វីទាល់តែមានសំបុត្រ ស៊ីញ៉េ ទើបធ្វើបាន ឯនៅតំបន់ខ្មាំងវិញ ចង់ធ្វើអ្វីបានស្រេចតែក្បាលចិត្ត គ្មានពិបាក ហើយគ្មានគ្រាប់ផ្លោងទៀតផង ។

ដល់ខែមិថុនា ឆ្នាំ១៩៧៣ ទើបអង្គភាពវរសេនាតូច២៥ រំលាយចូលទៅក្នុងអង្គភាពនីមួយៗអស់ តែដោយឡែក ចំពោះរូបខ្ញុំ, ឆន និងសារិន ត្រូវ សុទ្ធ ឲ្យទៅនៅជាមួយ សាត ប្រធានមន្ទីរកងពល៧០៣ ។ ពេលនោះទើប សាត ឲ្យខ្ញុំទៅនៅក្នុងអនុសេនាធំ៧២ ជាមេក្រុមនៅក្នុងវរសេនាតូច១៨៧ ប្រចាំតំបន់២៥ ។ លុះដល់ខែសីហា ឆ្នាំដដែល ទើប សាត ណែនាំឲ្យខ្ញុំទាក់ទងបក្សពួកដែលនៅក្នុងអង្គភាពមានៈ គង់ ប្រធានពេទ្យ៧០៣, កួយ ពលីនៅសមរភូមិកោះក្របីលើ, ឈឹន បញ្ជាការវរសេនាតូច១២៧ វរសេនាធំ៣២ កងពល៧០៣, អឿង អនុបញ្ជាការអនុសេនាធំ វរសេនាតូច១២៧ វរសេនាធំ៣២ កងពល៧០៣, ថុន នៅវរសេនាធំ៣២ កងពល៧០៣, ខន នៅវរសេនាតូច១២៧ វរសេនាធំ៣២ កងពល៧០៣, សុង ម៉ិ កាន់គេអូមន្ទីរកងពល៧០៣, ចាន់ ស្នងការ វរសេនាតូច១៣០ វរសេនាធំ៣៣ កងពល៧០៣, ឡាច ស្លាប់នៅសមរភូមិកោះក្របីក្រោម, តុម ស្នងការអនុសេនាធំ វរសេនាតូច១៣០ វរសេនាធំ៣២ កងពល៧០៣ ដើម្បីធ្វើសកម្មភាពនៅក្នុងសមរភូមិ ក្រោយពីបានទាក់ទងស្គាល់បក្ខពួកនៅក្នុងអង្គភាពមក រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៣ ទើបឈ្មោះ គង់

បានហៅខ្ញុំ និង អឿង នៅក្នុងអនុសេនាធំនេះ កើតឲ្យបាញ់ទៅខាងជើង ដោយប្រាប់ថា បន្ទាយខ្ញុំនៅជ្រុងនេះ ហើយនៅពេលនោះក៏ធ្វើឲ្យរបួសបីនាក់នៅក្នុងខ្សែត្រៀម ។ នៅពេលវាយខ្មាំងនៅសមរភូមិកោះក្របីលើ និងកោះក្របីក្រោម ខ្ញុំ, ម៉េង និងអឿង បានបង្ហត់បាយយុទ្ធជននៅខ្សែត្រៀមចាប់តាំងពីម៉ោង៧ព្រឹករហូតដល់ម៉ោង៩យប់ ទើបបានឲ្យហូប បាយ ដោយយកលេសថាគ្មានកម្លាំងរៀបបាយ ឬបើកអង្ករមិនទាន់ ។ នៅពេលខ្មាំងបានវាយបុកខ្លាំងនៅខ្សែត្រៀម ចំពោះបក្ខពួកខ្ញុំ គង់ និង ប៉េង បានធ្វើឲ្យគេអូខូចលែងទាក់ទងគ្នាបានពីខ្សែត្រៀមមួយទៅខ្សែត្រៀមមួយទៀត ។ កាលនៅសមរភូមិកោះក្របីលើ និងគល់ទទឹង នៅពេលនោះខ្ញុំ, ប៉េង, គង់ និងអឿង បានបំផុសយុទ្ធជនឈ្មោះ ធី,រី និង វុធ រត់ចោលខ្សែត្រៀម និងបាញ់ដៃខ្លួនឯង ។ លុះដល់ខែសីហា ឆ្នាំ១៩៧៤ ទើបឈ្មោះ ណត ចាត់តាំងខ្ញុំ, សារិន និងឆាន នាទីអនុបញ្ជាការ វរសេនាតូច១២៧ តំបន់២៥ ឲ្យមកនៅក្នុងវរៈសេនាតូច១៨៣ កងពល៧០៣ ។ ខែមករា ឆ្នាំ១៩៧៥ ទើប ណត បានប្រាប់ឈ្មោះ ម៉ាត់ ថា ចំពោះខ្ញុំ, ឆាន និងសារិន នេះគឺជាខ្សែចាត់តាំងរបស់យើងទេ ។

ក្រោយមកទើប ម៉ាត់ បានណែនាំខ្ញុំឲ្យទាក់ទងបក្ខពួកនៅក្នុងអង្គភាពមាន ៖ វ៉ាត នៅវរសេនាតូច១០៧ វរសេនាធំ៣១ កងពល៧០៣, ណៃ នៅវរសេនាតូច៣៨ វរសេនាធំ៣៣ កងពល៧០៣, ហៃ ស្នងការអនុសេនាធំ វរសេនាតូច៣៣១ វរសេនាធំ៣៣ កងពល៧០៣, សារឹម ស្នងការអនុសេនាតូច វរសេនាតូច១៨៣ កងពល៧០៣, សារី អនុប្រធានសេដ្ឋកិច្ច វរសេនាតូច១៨៣ កងពល៧០៣, រិត ប្រធានសេដ្ឋកិច្ច វរសេនាតូច១៨៣ កងពល៧០៣ និងឌី សារី បញ្ជាការ អនុសេនាតូច វរសេនាតូច៣៣២ វរសេនាធំ៣៣ កងពល៧០៣ ។ ក្រោយពី ម៉ាត ណែនាំឲ្យស្គាល់ហើយ ម៉ាត បានហៅអ្នកទាំងអស់គ្នា និងខ្ញុំមកប្រជុំដាក់ផែនការសម្រាប់ធ្វើសកម្មភាពនៅក្នុងអង្គភាពគឺ ៖

◆ ចំពោះបន្ទាយដែលពិនិត្យបានហើយ និងរៀបផែនការវាយត្រូវធ្វើឲ្យបែកការណ៍

◆ ពេលយកមីនទៅវាយរបងលួសខ្មាំងគឺវាយកុំឲ្យដាច់អស់ពិសេសវាយឲ្យដាច់ខាងក្រៅទុក ខាងក្នុងមួយជាន់ សំខាន់គឺនៅពេលវាយសម្រុកបន្ទាយ ។

◆ ពេលនាំទ័ពទៅសម្រុកបន្ទាយត្រូវធ្វើជាវង្វេងផ្លូវ ដើម្បីកុំឲ្យសម្រេចភារកិច្ចរបស់បក្ស ។

◆ ពេលវាយនៅបន្ទាយណា ត្រូវធ្វើឲ្យខូចគេអូ ។

ក្រោយពីទទួលផែនការហើយ យើងទាំងអស់គ្នាបានធ្វើសកម្មភាពនៅក្នុងអង្គភាព ក្នុងរយៈកាលពីខែកុម្ភៈ ឆ្នាំ១៩៧៥ ដល់ខែមេសា ឆ្នាំ១៩៧៥ ។ ដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ទើបខ្ញុំត្រូវរបួសបាក់ជើងម្ខាង ពេលនោះខ្ញុំបានមកព្យាបាលនៅមន្ទីរពេទ្យអស់ជាងមួយឆ្នាំ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៦ ទើបមកអង្គភាពវិញ ពេលនោះទើបអង្គការឲ្យខ្ញុំនៅមន្ទីរវរសេនាធំ៣៣ កងពល៧០៣ ។ នៅពេលនោះ ខ្ញុំមិនទាន់ជារបួស នៅដេកពេទ្យមន្ទីរវរសេនាធំ៣៣ កងពល៧០៣ អស់៥ខែ រហូតដល់ខែមេសា ឆ្នាំ១៩៧៧ ទើបឃើញ លន ដែលចូល សេ.អ៊ី.អា ជាមួយខ្ញុំនោះ មកសួរថារបួសជិតជាហើយឬនៅ ខ្ញុំឆ្លើយថា ជិតជាហើយនៅតែបន្តិចទៀតទេ ហើយដើររួចខ្លះៗហើយដែរ ដល់ក្រោយមកទៀត លន និយាយប្រាប់ខ្ញុំថា អង្គការចាប់អស់ហើយចំពោះបក្សពួកខ្ញុំដែលនៅក្នុងអង្គភាពនេះ បច្ចុប្បន្ននេះ នៅសល់គ្នាតិចណាស់ ពេលនោះខ្ញុំសួរថា នៅប៉ុន្មាននាក់ថាតិចនោះ? លន ប្រាប់ ថា នៅឈ្មោះ ហ៊ាង, គ្រុយ, ខា, ហ៊ាង, អ៊ុន, គង់ និងឡេង ហៅ ឃី ឡុយ ។

លុះដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ ទើបអង្គការចាត់តាំងខ្ញុំឲ្យមកនៅអនុសេនាធំ០៤ វរសេនាតូច៣៣៤ វរសេនាធំ៣៣ កងពល៧០៣ ។ នៅពេលនោះ ខ្ញុំបានទាក់ទងជាមួយ លន ដល់ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៧ ទើប លន និងហ៊ាង បានហៅខ្ញុំ, ហៃ, គ្រុយ និងខា ដើម្បីដាក់ ផែនការប្រឆាំងនឹងផែនការបង្កបង្កើនផលរបស់បក្សពីខែឧសភា ដល់ខែកក្កដា ឆ្នាំ១៩៧៧ គឺៈ

◆ បើអង្គការចាត់តាំងឲ្យទៅថែសំណាប យើងត្រូវធ្វើឲ្យសំណាបខូច ។

◆ បើអង្គការចាត់តាំងឲ្យទៅថែសន្ទូង ត្រូវបំផ្លាញសន្ទូង ។

◆ បើអង្គការចាត់តាំងឲ្យស្ទូង ត្រូវចាប់ស្មើគ្នាកុំចាប់តូច កុំចាប់ធំ ហើយស្ទូងឲ្យស្មើគ្នា កុំឲ្យញឹក កុំរង្វើល យើងត្រូវស្ទូងញឹករង្វើល និងចាប់តូចធំឲ្យខុសពីផែនការ ។

◆ បើអង្គការចាត់តាំងឲ្យទៅវាយសំណាប យើងត្រូវធ្វើឲ្យ

សំណាបប្រឡូកប្រឡំគ្នា ពីស្រូវ ក្រហូនស ទៅស្រូវសម្បុកអក្រង

◆ បើអង្គការចាត់ឲ្យទៅភ្ជួរដី ត្រូវធ្វើឲ្យមុតជើងគោ បង្អត់ស្មៅគោ និងធ្វើឲ្យបាក់នង្គ័ល ។

◆ ផែនការបំផ្លាញសត្វ និងផលដំណាំ ។

◆ ផែនការបំផុសយុទ្ធជនឲ្យរត់ទៅផ្ទះ ។

◆ ផែនការកសាងខ្សែបន្ត ។

ក្រោយពីបានទទួលផែនការពី លន និងហ៊ាង ហើយ ខ្ញុំ, ហៃ, គ្រុយ និងខា បានចេញធ្វើសកម្មភាពនៅក្នុងអង្គភាព ចាប់តាំងពីខែឧសភា ដល់ខែកក្កដា ឆ្នាំ១៩៧៧ ដូចជា៖

◆ នៅពេលដែលទៅរាយសំណាប ខ្ញុំ, គង់, អ៊ុន និងខា បានរាយសំណាប យកសំណាបក្រហូនស និងសំណាបសម្បុកអក្រងប្របល់គ្នា ហើយយកឲ្យគេស្ទូងខូច៥ហិចតា ។

◆ ពេលអង្គការចាត់តាំងឲ្យទៅថែសំណាប ខ្ញុំ, ហ៊ាង, អ៊ុន និងគង់ បំផ្លាញសំណាបឲ្យខូចអស់២ហិចតា មូលហេតុគឺ បង្ហូរទឹកចោល ។

◆ ពេលអង្គការចាត់តាំងឲ្យភ្ជួរដី ខ្ញុំ, ហ៊ាង, គ្រុយ និង ហៃ បានបង្អត់ស្មៅគោ ធ្វើឲ្យមុតជើង គោ ធ្វើឲ្យបាក់នង្គ័ល ។

◆ ពេលដែលអង្គការចាត់តាំងឲ្យថែសន្ទូង ខ្ញុំ, ហៃ, ខា និង ហ៊ាង បានបង្ហូរទឹកចេញពីសន្ទូង បណ្តាលឲ្យខូចអស់១ហិចតា ។

◆ ពេលដែលអង្គការឲ្យទៅស្ទូងស្រូវ ខ្ញុំ, ខា, ហៃ, ហ៊ាង និង អ៊ុន បានស្ទូងកាច់គល់សំណាប ចាប់តូច ចាប់ធំ ស្ទូងញឹក ស្ទូងរង្កើល ស្ទូងពន្លិចសំណាបទៅក្នុងទឹក ។

◆ ចំពោះខ្ញុំ, អ៊ុន និងគង់ បានបំផុសយុទ្ធជនឲ្យរត់ទៅផ្ទះបីនាក់ គឺ ឈ្មោះ មាស, រស់ និងនី ដោយនិយាយបំភ័យថា នៅកង០៨នេះ គឺជាកងសមាសភាពទេ មិនមែនកងល្អដូចកងដទៃទេ ហើយ ម្យ៉ាងទៀត ១០ថ្ងៃ អង្គការមកយក ម្នាក់ ទៅបួននាក់ ទៅដាក់គុក ដូច្នេះនៅតែបន្តិចទៀតទេ អង្គការនឹងចាប់ដាក់គុកហើយ ។

◆ ចំពោះ ខ្ញុំ, អ៊ុន និងគង់ បានកសាងកម្លាំងបានម្នាក់ឈ្មោះ គឹម សេង នាទីមេក្រុមសេដ្ឋកិច្ច អនុសេនាធំ០៤ វរសេនាតូច ៣៣២ វរសេនាធំ៣៣ កងពល៧០៣ ដោយបានអប់រំថា ចូលធ្វើបដិវត្តន៍យូរហើយ បានត្រឹមនឹងទៅមុខក៏មិនទៅ ថយទៅវិញបែរជាជាប់នៅក្នុងកងសមាសភាពទៅវិញ បើពិនិត្យទៅឃើញថា ការងារមិត្តល្អជាងគេ ហេតុអីបានអ៊ីចឹង គួរឲ្យឆ្ងល់ណាស់ ។ តែឥឡូវនេះរឿងអីក៏ដោយត្រូវជឿខ្ញុំ ហើយធ្វើតាមខ្ញុំ ខ្ញុំនឹងប្រគល់កិត្តិយសឲ្យតែធ្វើតាម ។ ក្រោយមកទើប សេង បានចូលរួមធ្វើសកម្មភាពនៅក្នុងអង្គភាពជាបន្តបន្ទាប់ ។

ខ្ញុំ, អ៊ុន, ហៃ និង គង់ បានបំផ្លាញល្ពៅ ត្រឡាច អស់មួយហិចតា និងយកថ្នាំកណ្តុរទៅបាចឲ្យមាន់ស៊ីងាប់អស់៥០ក្បាល ទា២០ក្បាល រហូតដល់អង្គការដកខ្ញុំឲ្យមកនៅស-២១ នៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៧ ។ ពីរថ្ងៃក្រោយមក ទើបអង្គការចាប់ខ្ញុំនៅម៉ោង១០យប់ រហូតដល់ម៉ោង២យប់ ទើបខ្ញុំរត់រួចពីកន្លែងនោះមកបន្ទាយនេះ ពេលនោះបានជួបនឹង អ៊ុន កំពុងតែអង្គុយធ្វើបញ្ជីបំណាច់ខែ ពេលនោះខ្ញុំក៏ប្រាប់ អ៊ុន ថា ស្អែកយកបាយឲ្យខ្ញុំហូបផង ហើយ អ៊ុន សួរខ្ញុំថា មានគ្នាប៉ុន្មាននាក់? ខ្ញុំឆ្លើយថា តែម្នាក់ឯងទេ ហើយយកទៅឲ្យខ្ញុំនៅដើមឈើក្រោយផ្ទះ ។ ក្រោយមក អ៊ុន បានហុចអង្រឹងមួយ តង់មួយមកឲ្យខ្ញុំ ហើយខ្ញុំក៏ទៅពួនដេកនៅក្នុងព្រៃជើងឯកចម្ងាយពីបន្ទាយនេះ ៤០០ម៉ែត្រ ដល់ថ្ងៃទី៥ ម៉ោង៩យប់ទើបខ្ញុំឃើញ អ៊ុន, ហ៊ាង និងឡយ មកជួបខ្ញុំ ពេលនោះ ហ៊ាង និយាយប្រាប់ខ្ញុំថា កុំភ័យមកដល់កន្លែងនេះហើយ ចំពោះបាយ ទឹក ចាំខ្ញុំឲ្យ អ៊ុន យកមកឲ្យរាល់ថ្ងៃ តែឥឡូវនេះ ត្រូវលាក់ខ្លួនឲ្យបាត់កុំឲ្យគេឃើញ ។ ហ៊ាង និយាយបានត្រឹមនេះ ទើបនាំគ្នាទៅវិញ ។ ដល់ថ្ងៃទី៦ ម៉ោង៩យប់ ទើបឃើញ អ៊ុន, ហ៊ាង និងស៊ីម មកជួបខ្ញុំទៀត ពេលនោះ ហ៊ាង បាននិយាយណែនាំខ្ញុំថា កុំភ័យគិតតែលាក់ខ្លួនទៅចាំដល់បន្តិចទៀត ខ្ញុំគិតឲ្យចេញពីនេះហើយ ម្យ៉ាងទៀត ខ្ញុំនៅក្រោយខិតខំបន្តធ្វើសកម្មភាពពង្រឹងខ្សែ ដើម្បីប្រឆាំងបដិវត្តន៍បន្តទៀត ហ៊ាង និយាយបានត្រឹមនេះនាំគ្នាទៅវិញ ។ លុះដល់ម៉ោង៧យប់ថ្ងៃដដែល អ៊ុន, ហ៊ាង, លន, គង់ និង សារី មកជួបខ្ញុំទៀត ពេលនោះ ហ៊ាង និយាយប្រាប់ខ្ញុំថា ដល់ថ្ងៃទី១០នេះ ខ្ញុំឲ្យរត់ចេញពីនេះ ហើយអ្នករត់ទៅជាមួយមាន ស៊ីម, ហ៊ាង និង ឡយ ហើយរកអ្នកស្គាល់ផ្លូវទៅស្រុកយួនផង ហើយនៅពេលទៅនោះ ខ្ញុំរៀបចំស្បៀងក្នុងរយៈប្រាំថ្ងៃ ហើយសម្លៀកបំពាក់ អង្រឹង មុង ថែមទៀត ។ លុះដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ ១៩៧៧ ម៉ោង៣ ភ្លៀងទទឹកខ្ញុំ ដល់ម៉ោង៧យប់ទើបខ្ញុំដើរមកកន្លែង អ៊ុន ដើម្បីរកខោអាវផ្លាស់ ពេលនោះខ្ញុំចូលជិតដល់ផ្ទះ អ៊ុន ទើបអ្នកយាមចាប់ខ្ញុំបាន ហើយអង្គការបញ្ជូនខ្ញុំមកដាក់នៅគុករហូតដល់សព្វថ្ងៃនេះ ។ **ធាម សារៈមុនិន្ទ**

# ចម្លើយ ចាន់ ថុល ហៅ ប៉ូល : អតីតយោធាខ្មែរក្រហមនៅសៀមរាប-ឧត្តរមានជ័យ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព J00062*

ចាន់ ថុល ហៅ ប៉ូល ត្រូវបានអង្គការចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១ពីបទក្បត់បដិវត្តន៍ និងធ្វើគិញឲ្យសេ.អ៊ី.អា ។ ប្រវត្តិតាំងពីកុមារភាព និងរាល់សកម្មភាពរបស់អ្នកទោស ចាន់ ថុល ត្រូវ បានកត់ទុកយ៉ាងល្អិតល្អន់ក្នុងចម្លើយសារភាពដែលមានចំនួន២៤ទំព័រ ដែលធ្វើឡើងចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៧ ។

ចាន់ ថុល មានស្រុកកំណើតនៅភូមិព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងមាន ឪពុកម្តាយជាកសិករ ពេលអាយុ៩ឆ្នាំ ចាន់ ថុល ត្រូវឪពុកម្តាយបញ្ជូនឲ្យទៅរៀនសូត្រនៅសាលាវត្ត ។

នៅឆ្នាំ១៩៦២ ថុល បានប្រឡងជាប់សាលារាជការ ។ ក្នុងរយៈកាលសិក្សារៀនសូត្រ ថុល មានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយមិត្តរួមថ្នាក់ម្នាក់ដែលមានឈ្មោះថា អ៊ឹង ម៉ាតាក់ ដែលមានឪពុក ឈ្មោះ អ៊ឹង គេង ជាចៅហ្វាយស្រុក ។ អ៊ឹង គេង ស្រឡាញ់រាប់អាន ពេញចិត្ត ថុល ជាខ្លាំង ដោយសារតែ ថុល ជាសិស្សរៀនពូកែ និងជាប្រធានថ្នាក់ ។ ដោយឃើញពីការលំបាករបស់ ថុល ក្នុងការធ្វើដំណើរពីកន្លែងស្នាក់ទៅសាលា អ៊ឹង គេង ក៏ហៅ ថុល មករស់នៅជាមួយ ដូចជាកូនធម៌ ។

ឆ្នាំ១៩៦៧ ចលនាបដិវត្តន៍មានសន្ទុះខ្លាំងនៅក្នុងភូមិរបស់ ថុល ដែលជំរុញឲ្យ អ៊ឹង គេង សម្រេចចិត្តហៅ ថុល មកនិយាយជាមួយនៅវេលាយប់មួយ ។ អ៊ឹង គេង បានអប់រំ ថុល កុំឲ្យចូលរួមក្នុងចលនាបដិវត្តន៍ និងបញ្ចុះបញ្ចូលក្រុមគ្រួសារគាត់ទៀត ព្រោះបើចូលធ្វើបដិវត្តន៍ នឹងមានការចាប់ខ្លួន ។

នៅចុងឆ្នាំ១៩៦៨ ថុល ត្រូវបាន អ៊ឹង គេង បញ្ជូនទៅរៀនសាលា ក្នុងខេត្តកំពង់ចាម ។ នៅទីនោះ ថុល បានជួបជាមួយ អ៊ឹង ទី ដែលត្រូវជាបងប្អូនរបស់ អ៊ឹង គេង ។ ថុល ត្រូវបាន អ៊ឹង ទី អប់រំជាច្រើនលើក ជាច្រើនសាមិនឲ្យជឿ និងចូលរួមជាមួយបដិវត្តន៍ ។ បន្ទាប់ពីប្រលងធ្លាក់ពីរដងក្នុងឆ្នាំ១៩៦៩ ថុល បានត្រឡប់មកស្រុកកំណើតរបស់គាត់វិញ ។ មួយខែកន្លះក្រោយមក អ៊ឹង គេង បានហៅ ថុល មកប្រាប់



មន្ទីរសន្តិសុខស-២១ (អតីតសាលាបឋមសិក្សាទួលស្វែង) ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩



រូបថតអ្នកទោសនៅគុកទួលស្លែង ឬមន្ទីរសន្តិសុខស-២១

ឲ្យកាត់ចិត្តពីការរៀនសូត្រ និងឲ្យមកធ្វើជាគិញខ្លួនវិញ ។ ក្រោយមក ថុល ក៏សម្រេចចិត្តយល់ព្រម ។ ប៉ុន្តែការងារនោះ ថុល មិនត្រូវធ្វើដោយបើកចំហនោះទេ គឺត្រូវរក្សារូបភាពជាសិស្សធម្មតា តាមពិតជាគិញសម្ងាត់ដើរស៊ើបការណ៍ និងយកព័ត៌មានផ្សេងៗ ។

ក្រោយថ្ងៃរដ្ឋប្រហារ ថុល ត្រូវបានបញ្ជាឲ្យទៅយកព័ត៌មាន ពីភូមិមាយ ភូមិបឹងកេត គីឡូលេខ១០ និងព្រែកកក់ជាដើម ។ នៅខែឧសភា ឆ្នាំ១៩៧០ បន្ទាយស្ទឹងត្រង់ត្រូវបានកម្លាំងបដិវត្តន៍រំដោះ អ៊ឹង តេង និងក្រុមគ្រួសារបានរត់គេចខ្លួន ។ ថុល ក៏បានរត់ភៀសខ្លួនដែរ តែត្រូវបាន អ៊ឹង ទី លួងលោមឲ្យមកស្រុកកំណើតដើម្បីស៊ើបការណ៍ផែនការក្បត់ទៀត ។ ថុល បានយល់ព្រម ទទួលភារកិច្ចនេះ និងបានត្រឡប់ទៅស្រុកកំណើតវិញ ដោយចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ មានតួនាទីជាអនុកងពល៣៣៥ ។ ដោយសារការអនុវត្តសកម្មភាពក្នុងផែនការក្បត់ ថុល ត្រូវបានអនុញ្ញាត ឲ្យមានសិទ្ធិចូលជាសមាជិកនៃអង្គការប្រជាជន ។ ថុល មានតួនាទីរៀបចំចាត់តាំងឲ្យធ្វើសកម្មភាពដើម្បីបង្អាក់ការវាយសម្រុករបស់បក្សបន្ថយកម្លាំងបដិវត្តន៍របស់បក្ស និងបន្ថែមកម្លាំងឲ្យខ្លាំង ធ្វើឲ្យផ្ទៃក្នុងបដិវត្តន៍ស្មុគស្មាញ ។ លើសពីនេះទៅទៀត ថុល បានចាត់តាំងកម្លាំងធ្វើការបំផុសឲ្យកងទ័ព ប្រព្រឹត្តអំពើខុសសីលធម៌ ជាមួយនារីសែងរបួស ក៏ដូចជាធ្វើឲ្យកងទ័ពមានភាពភ័យខ្លាចពីការរបួស ។ ដូច្នេះហើយ ទើបទ័ពរត់ចោលសមរភូមិប្រយុទ្ធ ។

នៅខែមីនា ឆ្នាំ១៩៧៧ ថុល ត្រូវបានអង្គការផ្លាស់ទៅខេត្តសៀមរាប និងឧត្តរមានជ័យ ។ ថុល បានធ្វើសកម្មភាពក្បត់ដោយទាក់ទងជាមួយនឹងកងទ័ពសៀមនៅតាមជាយដែនបណ្ដោយឲ្យកងទ័ពលេងសើច និងប្រើប្រាស់សម្ភារខ្ជះខ្ជាយដើម្បីបំផ្លាញអង្គការ ។ លើសពីនេះទៅទៀត នៅពេលបក្សដាក់ផែនការឲ្យ ថុល អប់រំយុទ្ធជនការពារព្រំដែននាំគ្នារក្សាអនាម័យដើម្បីកុំឲ្យជំងឺគ្រុនចាញ់ ថុល បែរជាណែនាំ និងអប់រំកម្មាភិបាល និងយុទ្ធជនឲ្យផឹកទឹកត្រជាក់ បណ្ដាលឲ្យកើតជំងឺគ្រុនចាញ់ជាច្រើននាក់ និងគ្មានមនុស្សធ្វើការ ។

នៅឆ្នាំ១៩៧៧ ដដែល ថុល ត្រូវបានចាប់ខ្លួន និងសួរចម្លើយបញ្ចប់នៅថ្ងៃទី១០ ខែមីនា ។

**សយ សុលីជា**

# កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់

ក្នុងអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ នៅពេលដែលសង្គ្រាមក្នុងប្រទេសវៀតណាម បានគំរាមកំហែងនៅតាមព្រំដែន តន្ត្រីបែបថ្មីបានលេចឡើងក្នុងប្រទេសកម្ពុជា ដែលចម្លងយកតន្ត្រីរ៉ក់ អេនរ៉ូល មកពីបស្ចិមប្រទេស ដោយមានឫសគល់នៃទម្រង់តន្ត្រីដើមរបស់ខ្លួន ក៏បានបង្កើតជាតន្ត្រីមួយបែបថ្មីខុសពីតន្ត្រីដទៃទៀត ។

តន្ត្រីករខ្មែរបានបង្កើតតន្ត្រីមួយបែបនេះ ចេញពីក្បួនខ្នាតដ៏សំខាន់នៃតន្ត្រីរ៉ក់ផ្សេងៗរបស់អាមេរិក អង់គ្លេស និងបារាំង ដោយដាក់បញ្ចូលសំឡេង និងចង្វាក់តន្ត្រីប្រពៃណីខ្មែរតែមួយគត់របស់ខ្លួន ។ សំឡេងដ៏ពិរោះរបស់អ្នកចម្រៀងស្ត្រីដែលល្បីឈ្មោះបានក្លាយជាចំណុចទាក់ទាញ ហើយធ្វើឲ្យតន្ត្រីច្នៃប្រឌិតមួយនេះទទួលបានការពេញនិយមយ៉ាងខ្លាំងពីសាធារណជន ។




ប៉ុន្តែនៅពេលដែលសង្គមខ្មែរ ជាពិសេសតន្ត្រីករវ័យក្មេងទទួលយកវប្បធម៌បស្ចិមប្រទេស ហើយបានវិវឌ្ឍខ្លួនក្រោមឥទ្ធិពលនៃវប្បធម៌នេះ ប្រទេសកម្ពុជាក៏បានធ្លាក់ក្នុងភ្លក់ភ្លើងសង្គ្រាមយ៉ាងឆាប់រហ័ស ។ ចំពោះនិន្នាការឆ្វេងនិយម សម្តេចព្រះ នរោត្តម សីហនុ បានចូលរួមជាមួយនឹងខ្មែរក្រហម ហើយបានបង្រួបបង្រួមប្រជាជនតាមជនបទប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលដែលបានបណ្តេញព្រះអង្គ ។ ចំពោះនិន្នាការស្តាំនិយមក្រោមជំនួយទំនុកបម្រុងរបស់យោធាសហរដ្ឋអាមេរិក កងកម្លាំងយោធាកម្ពុជាបានបង្កសង្គ្រាមដែលមានយុទ្ធនាការទម្លាក់គ្រាប់បែកក្នុងទ្រង់ទ្រាយធំនៅតាមទីជនបទ ។ ចុងក្រោយ បន្ទាប់ពីខ្លួនបានទទួលជ័យជម្នះលើសង្គ្រាម ខ្មែរក្រហមបានកំណត់ទិសដៅកម្ទេចវប្បធម៌ខ្មែរ ។

បន្ទាប់ពីខ្មែរក្រហមត្រួតត្រាប្រទេសកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមលុបបំបាត់ចោលសញ្ញាណនៃឥទ្ធិពលរបស់បស្ចិមប្រទេស និងភាពទាន់សម័យទាំងអស់ ។ បញ្ញវន្ត សិល្បករ និងតន្ត្រីករ ត្រូវបានដៅជាមុខសញ្ញាដាក់លាក់ និងត្រូវកម្ទេចចោលជាប្រព័ន្ធ ។ ដូច្នេះហើយ អំពើប្រល័យពូជសាសន៍មួយនៅក្នុងចំណោមអំពើដ៏ឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រមនុស្ស ជាតិក៏បានចាប់ផ្តើមឡើងដោយខ្មែរក្រហមដែលបានសម្លាប់ប្រជាជនប្រមាណពីរលាននាក់ ស្មើនឹងមួយភាគបួននៃប្រជាជនកម្ពុជា ។

កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់ ដឹកកកាយនូវលក្ខណៈធាតុផ្សំរបស់តន្ត្រីខ្មែរដែលបានប្រែក្លាយទៅជាតន្ត្រី រ៉ក់ អេន រ៉ូល ហើយបានរីកចម្រើនឆ្ពោះទៅមុខ ប៉ុន្តែស្ទើរតែត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ ខ្សែភាពយន្តឯកសារនេះបានផ្តល់គំហើញថ្មីស្តីពីប្រទេសមួយដែលយើងធ្លាប់តែឮពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។

ខ្សែភាពយន្តនេះ គឺជាពិធីប្រារព្ធអបអរអំពីសិល្បៈតន្ត្រីដ៏អស្ចារ្យមកពីប្រទេសកម្ពុជា និងស្វែងយល់អំពីសារសំខាន់របស់សិល្បៈតន្ត្រីមកលើសង្គមពីអតីតកាល និងបច្ចុប្បន្នកាល ។












តន្ត្រីហោណាភិរម្យ




ស៊ីន. ស៊ីសាមុត
SARAVANN


66094
មួយស មួយខ្មៅ
CHA CHA CHA
CHA CHA CHA
5


Terk


PEN
RAN
Promenade en barque (Surf)
Chantée par Sinn Sisamouth
Musique et paroles de Sinn Sisamouth
Chef orchestre de Has Salan
Ha! Ha! Monkeys (Monkeys)


ម៉ាឡាមាស បង
MALA CHERIE
(Rumba lent)
Musique et paroles de SINN-SISAMOUTH
Chantée par SINN - SISAMOUTH
Arrangement de MER-BUN
ORCHESTRE PHNOM-MEAS
PM-1001

# ខ្សែភាពយន្តរំឭកអំពីប្រវត្តិសាស្ត្រ វប្បធម៌ និងប្រវត្តិតន្ត្រី

ទស្សនិកជនប្រមាណជាពីរពាន់នាក់បានមកទស្សនាខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រី រ៉ក់ អេន រ៉ូល" និងចូលរួមពិធីប្រគុំតន្ត្រី កាលពីយប់ថ្ងៃទី១១ ខែមករា នៅសាលសន្និសីទចតុមុខ ។ កម្មវិធីនេះគាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ។ "កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់ អេនរ៉ូល គឺជាខ្សែភាពយន្តឯកសារមួយផ្តិតទៅដោយខ្សែវីដេអូដែលកម្ររកបាន ព្រមទាំងរូបថតគម្របថាសចម្រៀង អ្នកចម្រៀង និងតន្ត្រីករកាលពីទសវត្សរ៍៦០ និង៧០ ដែលធ្វើឲ្យខ្សែភាពយន្តនេះក្លាយជាភាពយន្តឯកសារដោយកម្រមួយ និងទទួលបានចំណាប់អារម្មណ៍ខ្លាំងពីបណ្តាសាធារណជនទូទៅ ជាពិសេស សិល្បករ និងអ្នកដែលធ្លាប់ជាយុវវ័យកាលពីជំនាន់មុនរបបខ្មែរក្រហម ។

ដោយសារតែចំនួនអ្នកមកទស្សនាច្រើនជាងចំនួនកៅអី អ្នកទស្សនាជាច្រើននាក់បានអង្គុយនៅលើកម្រាលឥដ្ឋ ខ្លះទៀតឈរនៅផ្នែកខាងក្រោយនៃកៅអី និងនៅគ្រប់មាត់ទ្វារទាំងអស់ ហើយមានអ្នកឈរខ្លះទៀតខំប្រឹងឈរមើលនៅជិតមាត់ទ្វារទោះបីជាអាចមើលឃើញត្រឹមតែពាក់កណ្តាលជាំង ក្រណាត់សក៏ដោយ ។ អ្នកខ្លះទៀតបានត្រឡប់ទៅវិញព្រោះតែគ្មានកន្លែងសម្រាប់អង្គុយនិងឈរ ។

មន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់ ព្រះរាជវង្សានុវង្ស សិល្បករតន្ត្រីករ អ្នកចម្រៀង អគ្គរដ្ឋទូត នានា និងឥស្សរជនជាច្រើនរូបបានមកចូលរួមទស្សនាខ្សែភាពយន្តឯកសារនេះ ។ ក្នុងនោះក៏មានវត្តមានលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងលោក វណ្ណ ម៉ូលីវណ្ណ ដែលជាស្ថាបត្យករដ៏ឆ្នើមកាលពីទសវត្សរ៍៦០ក្នុងសម័យសង្គមរាស្ត្រនិយមដឹកនាំដោយអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ។ លោក វណ្ណ ម៉ូលីវណ្ណ ដែលពេលនេះមានវ័យ៨៨ឆ្នាំ និងអាចដើរបានដោយមានអ្នកជួយគ្រានិងឈើច្រត់ គឺជាអ្នករចនាប្លង់សាលសន្និសីទចតុមុខនេះផ្ទាល់ ដោយយកគំនិតចេញពីធាងរបស់ដើមត្នោត ដែលជាអត្តសញ្ញាណរបស់ជាតិកម្ពុជា ហើយបានបញ្ចប់ការសាងសង់រួចរាល់ក្នុងឆ្នាំ១៩៦១ ដោយជំនួយថវិការបស់សហរដ្ឋអាមេរិក ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាប្រធានផលិតកម្មរបស់ខ្សែភាពយន្តឯកសារនេះមានប្រសាសន៍ថា សាធារណជនបានចូលមកទស្សនាច្រើនជាងចំនួនកំណត់ ដែលទង្វើនេះអាចបញ្ជាក់បានថា ប្រជាជនកម្ពុជាចង់ដឹងចង់ឮពីប្រវត្តិសាស្ត្ររបស់ខ្លួន "យើងបានបម្រុងកៅអីតែ៧០០ប៉ុណ្ណោះ តែនៅថ្ងៃបញ្ចាំងខ្សែភាពយន្ត អ្នកចូលរួមមានរហូតដល់ទៅជិតពីរពាន់នាក់ ។ តន្ត្រីមានឥទ្ធិពលខ្លាំងណាស់នៅក្នុងសង្គមខ្មែរ ។ ខ្មែរក្រហមអាចសម្លាប់សិល្បករបាន តែមិនអាចសម្លាប់ព្រលឹងសិល្បៈខ្មែរបានទេ ។ សិល្បៈគឺជាព្រលឹងរបស់ជាតិ ហើយសិល្បៈនេះមិនចេះសាបសូន្យទេ" ។

ខ្សែភាពយន្តនេះត្រូវបានចំណាយពេលជិត១០ឆ្នាំដើម្បីផលិត ។ ចន ពីរ៉ូហ្ស៊ី ដែលជាផលិតករខ្សែភាពយន្តនេះ បានស្រាវជ្រាវប្រមូលឯកសារនានា រួមទាំងថាសចម្រៀងដែលនៅសេសសល់ពីរបបខ្មែរក្រហម ព្រមទាំងស្រាវជ្រាវរកសាច់ញាតិរបស់អ្នកចម្រៀងនិងសិល្បករកាលពីមុនរបបខ្មែរ ក្រហមដែលនៅរស់



ពិធីតាំងពិពណ៌រូបថតខ្សែភាពយន្តឯកសាររឿង "កុំស្មានបងភ្លេច"

បានមានជីវិត ។ ចន ពីរ៉ូហ្ស៊ី បាននិយាយថា «នៅពេលដែលខ្ញុំចាប់ផ្ដើមស្រាវជ្រាវដើម្បីថតខ្សែភាពយន្តនេះលើកដំបូង អ្នកណាក៏ប្រាប់ខ្ញុំដែរថា ខ្ញុំនឹងមានការលំបាកក្នុងការស្វែងរកឯកសារ និងសំនៀងដើមរបស់អ្នកចម្រៀងកាលពីមុនរបបខ្មែរក្រហម ព្រោះរាល់ឯកសារទាំងអស់នោះត្រូវបានបំផ្លាញដោយរបបខ្មែរក្រហមអស់ហើយ ហើយឯកសារមួយចំនួនទៀតបានបាត់បង់ទាំងស្រុងដោយសារពេលវេលា ។ ប៉ុន្តែ វាមិនពិតទាំងស្រុងនោះទេ យើងអាចរកឯកសារដែលបានកប់ទុកជាយូរមកហើយ បាននិងចំណាយពេលជាង១០ឆ្នាំជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកខ្លះមានចិត្តស្រលាញ់សិល្បៈតន្ត្រីខ្មែរយ៉ាងខ្លាំង និងបានលាក់ទុកថាសចម្រៀងនិងចម្រៀងមួយចំនួនដោយប្រថុយប្តូរជីវិត» ។

លោក ទូច សៀងតាណា បាននិយាយក្នុងអំឡុងពិធីប្រគុំតន្ត្រីនៅថៃនោះដែរថា បទចម្រៀងមួយចំនួនដែលក្រុមតន្ត្រីរបស់គាត់បានថតចូលក្នុងថាសបានបាត់សូន្យតែម្តង ហើយរហូតមកដល់ពេលនេះ គាត់មិនអាចរកបានទាល់តែសោះទោះបីជាគាត់ខិតខំស្វែងរកនៅក្នុងបណ្តាប្រទេសផ្សេងៗក៏ដោយ ។ ក្នុងពិធីប្រគុំតន្ត្រីនេះ លោក ទូច សៀងតាណា បានប្រគុំបទចម្រៀងដែលបានបាត់នោះម្តងទៀត តែជាអកុសល សមាជិកមួយចំនួននៅក្នុងក្រុមរបស់គាត់បានបាត់បង់ជីវិតកាលពីរបបខ្មែរក្រហមទៅហើយ ។

ក្នុងអំឡុងពិធីបញ្ចាំងខ្សែភាពយន្ត ទស្សនិកជនបានរំពៃមើលគ្រប់សកម្មភាពនៅលើផ្ទាំងក្រណាត់សយ៉ាងយកចិត្តទុកដាក់ ដោយមើលនិងស្តាប់ការរៀបរាប់របស់តន្ត្រីករនិងអ្នកចម្រៀងជំនាន់ដើម ដោយក្តីកោតសរសើរយ៉ាងជ្រាលជ្រៅ លាយឡំដោយភាពរំជួលចិត្តផង និងសប្បាយផងនៅពេលដែលអ្នកនៅរួចរស់ជីវិតរៀបរាប់អំពីអ្នកចម្រៀងជំនាន់ដើម ដូចជា ស៊ីន ស៊ីសាមុត, រស់ សេរីសុទ្ធា ហួយ មាស ជាដើម ។ ទស្សនិកជនខ្លះបានកោតសរសើរដល់គំនិតច្នៃប្រឌិតខ្ពស់របស់អ្នកចម្រៀងនិង តន្ត្រីករខ្មែរជំនាន់ដើមដែលបានប្រែយកឥទ្ធិពលតន្ត្រីបរទេសមកច្នៃប្រឌិតធ្វើជារបស់ខ្លួន ។ ទស្សនិកជន ខ្លះទៀតបាននិយាយថា ខ្លួនបានដឹងពីប្រវត្តិសាស្ត្រផង និងប្រវត្តិតន្ត្រីខ្មែរផងក្រោយពីមើលខ្សែភាពយន្តឯកសារនេះ ។

លោក រស់ សុវាចា បានមានប្រសាសន៍ថា «ខ្ញុំពេញចិត្តខ្សែភាពយន្តឯកសារនេះយ៉ាងខ្លាំង ជាពិសេស ខ្សែភាពយន្តឯកសារនេះធ្វើឲ្យខ្ញុំយល់ដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែលខ្ញុំមិនដែលធ្លាប់ដឹងពីមុនមកទាក់ទងទៅនឹងភាពអង់អាចក្លាហានរបស់ទ្រង់ សិរិមតៈ ដែលសម្រេចចិត្តមិនភៀសខ្លួនចេញពីប្រទេសតាមការអញ្ជើញរបស់អតីតអគ្គរដ្ឋទូតអាមេរិក» ។

ជួន សុចិត្រា សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ហើយបាននាំជីតានិងមិត្តភក្តិមកលេងស្រុកកំណើត បានឆ្លៀតឱកាសមកមើលខ្សែភាពយន្តនេះដែរ ។ សុចិត្រា បាននិយាយថា «រឿងនេះពិតជាអស្ចារ្យណាស់ មិនធ្វើឲ្យទស្សនិកជនធុញទ្រាន់ឡើយ តាមរយៈបទចម្រៀងមនោសញ្ចេតនា និងកន្ត្រាក់អារម្មណ៍នៅក្នុងភាពយន្តនោះ ។ ចំណែកឯក្នុងន័យប្រវត្តិសាស្ត្រវិញ ពេលនេះ សហរដ្ឋអាមេរិកហាក់បីដូចជាទទួលស្គាល់ថា ការទម្លាក់គ្រាប់បែករបស់ខ្លួននៅតាមព្រំដែនកម្ពុជា-វៀតណាម ក្នុងអំឡុងសង្គ្រាមវៀតណាម បានបង្កឲ្យមានសង្គ្រាមនៅកម្ពុជា» ។

យុវជន សុខ សីហា បាននាំមិត្តភក្តិរបស់ខ្លួនម្នាក់មកមើលខ្សែភាពយន្តឯកសារនេះដែរ ហើយបានបង្ហាញចំណាប់អារម្មណ៍ថា «រឿងនេះពោរពេញទៅដោយចំណេះដឹងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងប្រវត្តិតន្ត្រី ។ រឿងនេះពោរពេញទៅដោយភាពរីករាយផង និងភាពរំជួលចិត្តផង ហើយទស្សនិកជនពេញចិត្តតាំងពីដើមរហូតដល់ចប់» ។

យុវនារី លី សេរីរ័ត្ន អាយុ២៦ឆ្នាំ បាននិយាយថា «ខ្សែភាពយន្តនេះមិនត្រឹមតែធ្វើឲ្យខ្ញុំដឹង ពីប្រវត្តិតន្ត្រីខ្មែរប៉ុណ្ណោះទេ តែក៏ធ្វើឲ្យខ្ញុំដឹងអំពីប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកចម្រៀងមួយចំនួន ជាពិសេស ប្រវត្តិស្នេហារបស់ រស់ សេរីសុទ្ធា និង សុះ ម៉ាត់ ។ តាមរយៈរឿងនេះ ខ្ញុំបានឃើញទិដ្ឋភាពទីក្រុង ភ្នំពេញក្នុងរបបខ្មែរក្រហមនៅពេលដែលទីក្រុងក្លាយជាទីក្រុងស្ងាត់ជ្រងំ» ។

ហុង កែវមុន្នី អាយុ២៥ឆ្នាំ បាននិយាយថា «ខ្សែភាពយន្តនេះធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក និងនឹកឃើញដល់អ្នកចម្រៀងចាស់ៗដែលបានបាត់បង់ជីវិតទៅ ។ ក្រោយពីមើលខ្សែភាពយន្តនេះហើយ ធ្វើឲ្យខ្ញុំស្រលាញ់ចម្រៀងកាលពីសម័យដើមកាន់តែខ្លាំងជាងមុន» ។

**ញាណ សុជាតិ**









# មួយរាត្រីនៅក្នុងទសវត្សរ៍៦០ ៖ កុំស្មានបងភ្លេច

ប្រវត្តិសាស្ត្រត្រូវបានសរសេរឡើងនៅសាលសន្និសីទចតុមុខកាលពីរាត្រីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៤ ។ រាត្រីនោះចាប់ផ្តើមឡើងដោយមានការបញ្ចាំងខ្សែភាពយន្តឯកសារខ្នាតពិភពលោក ផលិតដោយ ចន ពីរ៉ូហ្ស៊ី ជាមួយនិងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្សែភាពយន្តឯកសារនោះមានចំណងជើងថា "កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់" ។ ក្រោយពីការបញ្ចាំងខ្សែភាពយន្តនេះ ក៏មានការរៀបចំកម្មវិធីមួយចំនួនទៀតដូចជា កម្មវិធីសំណួរ-ចម្លើយ ការហូបអាហារ កម្សាន្ត និង ការប្រគុំតន្ត្រីដ៏អស្ចារ្យ ដោយអ្នកចម្រៀងជើងចាស់មួយចំនួនដូចជា លោក ហួ ឡុញ មកពីក្រុម ភ្លេងអប្សរា, លោក ហុង សំឡី មកពីក្រុមភ្លេងបាយ័ន និងលោក ទូច សៀងតារា មកពីក្រុមភ្លេងដារាហ្គា ។ ក្រុមភ្លេងទាំងបីនេះបានបង្កើតឡើងតាំងពីទសវត្សរ៍៦០ ។ ការប្រគុំតន្ត្រីនោះ ក៏មានការចូលរួមសម្តែងពីចម្រៀងសម័យថ្មី គឺ កញ្ញា ឆោម និមល មកពីក្រុមភ្លេង ឌនេង៉ុ ធវេរេ ។

ខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់" បានបង្ហាញខ្ញុំឲ្យដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាចាប់តាំងពីពេលដែលអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ទាមទារឯករាជ្យពីអាណានិគមនិយមបារាំង ។ ខ្សែភាពយន្តឯកសារនេះបានបរិយាយពីព្រឹត្តិការណ៍ក្នុងន័យងាយស្រួលយល់តាមលំដាប់លំដោយប្រវត្តិសាស្ត្រ ។ និយាយតាមត្រង់ទៅចុះខ្សែភាពយន្តឯកសារនេះធ្វើឲ្យខ្ញុំស្រួលយល់ជាងការរៀនប្រវត្តិសាស្ត្រតាមថ្នាក់រៀនកាលពីខ្ញុំរៀនថ្នាក់វិទ្យាល័យទៅទៀត ។


រស់ សេរីសុទ្ធា

ខ្ញុំចូលចិត្តខ្សែភាពយន្តនេះខ្លាំងណាស់! តាមគំនិតរបស់ខ្ញុំ ខ្សែភាពយន្តនេះគឺជាភាពយន្តឯកសារប្រវត្តិសាស្ត្រដោយបានរៀបរាប់អំពីភាពបត់បែនរបស់តន្ត្រីតាមសម័យកាល ។ ជាការពិតមែនហើយ នៅពេលដែលនិយាយអំពីតន្ត្រីដែលបាត់បង់ គឺនិយាយអំពីប្រវត្តិសាស្ត្រ ប៉ុន្តែខ្សែភាពយន្តនេះមិនត្រឹមតែនិយាយអំពីប្រវត្តិតន្ត្រី រ៉ក់ អេន រ៉ូល ដែលតួអង្គបានរៀបរាប់នៅក្នុងខ្សែភាពយន្តតែប៉ុណ្ណោះទេ ប៉ុន្តែខ្សែភាពយន្តនេះថែមទាំងរៀបរាប់អំពីប្រវត្តិផ្ទាល់ខ្លួនរបស់តួអង្គ អំពីថាតើអ្នកទាំងនោះចាប់ផ្តើមអាជីពក្នុងឧស្សាហកម្មតន្ត្រីតាំងពីពេលណា ដោយរបៀបណា និងអំពីជីវិតដ៏ខ្លោចផ្សានៅពេលឆ្លងកាត់របប

ខ្មែរក្រហម ។

តើនរណាខ្លះដែលជាតួអង្គដែលត្រូវបានសម្ភាសនៅក្នុងខ្សែភាពយន្តនេះ? តួអង្គខ្លះគឺជាបុគ្គលផ្ទាល់ដែលធ្លាប់ជាអ្នកចម្រៀង ឬ តន្ត្រីករ កាលពីទសវត្សរ៍៦០ ។ អ្នកខ្លះទៀតគឺជាសាច់ញាតិរបស់អ្នកចម្រៀង ឬ តន្ត្រីករ ហើយពីរនាក់ក្នុងចំណោមអ្នកទាំងនោះគឺជាប្រិយមិត្តនៅតែចូលចិត្តចម្រៀង និងតន្ត្រី កាលពីជំនាន់ដើម ។ អ្នកប្រវត្តិសាស្ត្រសញ្ជាតិអាមេរិក ដេវីដ ឆេនដ៍ល័រ គឺជាមនុស្សម្នាក់ដែលត្រូវបានសម្ភាសនៅក្នុងខ្សែភាពយន្តនោះដែរ ហើយខ្ញុំរីករាយណាស់ដែលបានជួបមុខគាត់ដោយផ្ទាល់ជាលើកដំបូង ព្រោះខ្ញុំធ្លាប់តែអានសៀវភៅគាត់ ហើយនៅថ្នាក់រៀនយើងបានប្រើប្រាស់សៀវភៅរបស់គាត់សម្រាប់ថ្នាក់ប្រវត្តិសាស្ត្រខ្មែរ ។

រាត្រីថ្ងៃនោះគឺជារាត្រីដ៏រំភើបមួយ លាយឡំទៅដោយអតីតកាលផងនិង បច្ចុប្បន្នកាលផង ចម្រុះគ្នា អមដោយការចូលរួមច្រៀងនិងប្រគុំតន្ត្រីពីសំណាក់ក្រុមភ្លេងបក្សីចាំក្រុង, ក្រុមដ្រាហ្គា, ការចូលរួមរបស់បងស្រីរបស់អ្នកចម្រៀង រស់ សេរីសុទ្ធា, ការចូលរួមរបស់អ្នក ចម្រៀងជើងចាស់ ឌី សាវ៉េត, អ្នកចម្រៀងស៊ីន ចាន់ឆាយា ជាកូនប្រុសរបស់អ្នកចម្រៀង ស៊ីន ស៊ីសាមុត ដែលត្រូវបានផ្តល់រហស្សនាមថាជាអធិរាជសំឡេងមាស ។ ការប្រគុំតន្ត្រីនោះ អធិប្បាយអំពីភាពអស្ចារ្យនាសម័យកាលដ៏រុងរឿងនៃតន្ត្រី និងសង្គមខ្មែរ ។

នៅក្នុងខ្សែភាពយន្តនោះមានខ្សែវីឌីអូខ្លីៗសល់ពីសម័យដើម ដែលរៀបរាប់អំពីបែបផែនជីវិត និងរបៀបរស់នៅរបស់ប្រជាជនកម្ពុជាអំពីអ្នកធាក់ស៊ីក្លូដែលចតស៊ីក្លូជុំគ្នាដើម្បីស្តាប់វិទ្យុជាតិពេលសម្រាកពីការងារ ។ អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះគឺការនិយមចូលចិត្តជប់លៀង និងការរាំរែករបស់ប្រជាជនខ្មែរ ការដែលប្រជាជនខ្មែរបិទរាំងននៅផ្ទះរបស់ខ្លួនពេលប្រទេសកំពុងជួបគ្រោះសង្គ្រាម ដើម្បីស្តាប់តន្ត្រី និងរាំលេង និងការបើកក្លឹបរាំកម្សាន្តនៅពេលថ្ងៃព្រោះនៅពេលយប់មិនមានសុវត្ថិភាពគ្រប់គ្រាន់ ។ សិល្បករជាច្រើននាក់ដែលកាលពីជំនាន់ដើមបានផ្តល់ឥទ្ធិពលយ៉ាងខ្លាំងដល់អ្នកស្តាប់ រួមមាន អ្នកចម្រៀងដែលជាទីពេញនិយមរបស់ខ្ញុំគឺ យល់ អ៊ូឡារាំង ដែលជាអ្នកចម្រៀងមានស្នារតីរស់រវើក ហើយតន្ត្រីរបស់គាត់ដែលតែងច្រៀងបទ រ៉ក់ បានផ្តល់ចំណាប់អារម្មណ៍យ៉ាងខ្លាំង ដល់ប្រជាជនកម្ពុជាទូទៅតាំងពីទសវត្សរ៍៧០រហូតមកដល់បច្ចុប្បន្ន ។ ជារឿងគួរឲ្យស្តាយណាស់ដែលគាត់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម ។

ដោយសារតែកាលៈទេសៈនាពេលនោះ ប្រទេសកម្ពុជាទទួលឥទ្ធិពលពីអាណានិគមនិយមបារាំង ក្រោយមកទទួលឥទ្ធិពលពីអាមេរិក សិល្បករខ្មែរបានចាប់យកឥទ្ធិពលតន្ត្រីពីប្រទេសទាំងនោះ ។ យោធាអាមេរិកាំងបាននាំមកយកតន្ត្រីតាមបែបគុយបាមកជាមួយ ។ ខ្មែរបានទទួលយកឥទ្ធិពលវប្បធម៌ពីបស្ចិមប្រទេស ហើយកែច្នៃតន្ត្រីនោះទៅជារបស់ខ្លួន ដោយមានក្រុមលេងហ្គីតាការច្រៀងចម្រៀងដែលធ្វើឲ្យអ្នកស្តាប់ងាយយល់និងច្រៀងក្បាច់រាំ និងការស្លៀកពាក់បែបទាន់សម័យ កាលពីជំនាន់នោះ ។

មុននឹងខ្ញុំត្រឡប់ទៅផ្ទះវិញ ក្រោយពីការទស្សនាការប្រគុំតន្ត្រីនោះ ខ្ញុំមានឱកាសជួបនិយាយលេងជាមួយលោក ហុង សំឡី មកពីក្រុមភ្លេងបាយ័ន ។ ខ្ញុំបានប្រាប់គាត់ថា កូនខ្មែរជំនាន់ក្រោយមានចិត្តស្រឡាញ់តន្ត្រីខ្មែរកាលពីសម័យដើមខ្លាំងណាស់ ។

ក្រោយមក គាត់បានឱបខ្ញុំដោយក្តីរំភើប និងថ្លែងអំណរគុណខ្ញុំដោយក្តីអំណរ ។ រាត្រីនោះគឺជារាត្រីដ៏សែនរីករាយពន់ពេក! រាត្រីដ៏សែនរំជួលចិត្ត និងរីករាយដែលខ្ញុំមិនដែលជួបប្រទះទាល់តែសោះ ជារាត្រីដែលធ្វើឲ្យខ្ញុំស្ទើរស្រក់ទឹកភ្នែកក្នុងចំណោមមហាសាគរនៃមនុស្ស ។

ព្រឹត្តិការណ៍ដ៏អស្ចារ្យបែបនេះអាច ឬក៏មិនអាចនឹងមានម្តងទៀតទេ ។ បើអាចមានមែនខ្ញុំក៏មិនដឹងថានឹងអាចមានពេលណាដែរ ប៉ុន្តែរាត្រីនោះ ខ្ញុំបានរៀនសូត្រច្រើនណាស់ ។ សូមថ្លែងអំណរគុណជាពន្លឹកដល់ក្រុមផលិត និងក្រុមរៀបចំកម្មវិធីដែលធ្វើឲ្យរាត្រីនេះក្លាយជារាត្រីមួយក្នុងទសវត្សរ៍៦០ ។ ខ្ញុំសង្ឃឹមថាថ្ងៃណាមួយខ្ញុំនឹងបានជួបព្រឹត្តិការណ៍ធំបែបនេះទៀត និងប្រសើរជាងនេះទៀតបើអាចមាន ខ្ញុំចង់ធ្វើកិច្ចការរបៀបនេះ ដោយច្នៃប្រឌិតអ្វីមួយដែលផ្តល់អត្ថន័យយ៉ាងជ្រាលជ្រៅដល់ប្រជាជនកម្ពុជាទូទៅ ហើយធ្វើឲ្យអ្នកទាំងនោះទទួលបាននូវអារម្មណ៍ថាខ្ញុំហាក់បីដូចជាទទួលបានអារម្មណ៍បែបនោះ គឺរាត្រីមួយនៅក្នុងទសវត្សរ៍៦០ ។ **ម៉ែន សុនីតា**

# ឱ! ភ្នំពេញអើយ-កុំស្មានបងភ្លេច

ខ្ញុំនឹងចាកចេញពីទីក្រុងភ្នំពេញក្នុងពេលឆាប់ៗនេះ បន្ទាប់ពីបានធ្វើការនៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអស់រយៈពេលពីរឆ្នាំកន្លងមក ។ ខ្ញុំមានការពិបាកដើម្បីគ្រប់គ្រងអារម្មណ៍របស់ខ្ញុំ ។ សំបុត្រយន្តហោះធ្វើដំណើរត្រឡប់ទៅផ្ទះក៏បានកក់ទុករួច ចំណងមិត្តភាព និងទំនាក់ទំនងដែលមាននៅទីនេះ ក៏នឹងត្រូវបញ្ចប់ ការវិលត្រឡប់នេះបានធ្វើឲ្យអារម្មណ៍ខ្ញុំច្របូកច្របល់ជាខ្លាំង ។ ស្របពេលជាមួយគ្នានេះដែរ កម្មវិធីដែលទាក់ទងនឹងវប្បធម៌ជាច្រើនបានប្រារព្ធឡើងនៅពាសពេញទីក្រុងភ្នំពេញ ។ កម្មវិធី ទាំងនេះបានរំឭកខ្ញុំអំពីសេចក្តីស្នេហារបស់ក្រុងភ្នំពេញ ។

ក្នុងចំណោមកម្មវិធីទាំងនោះ ខ្ញុំបានចូលរួមក្នុងការសម្ពោធខ្សែភាពយន្ត «កុំស្មានបងភ្លេច» ដែលជាភាពយន្តឯកសារមួយក្នុងចំណោមភាពយន្តឯកសារល្អបំផុតដែលខ្ញុំធ្លាប់បានទស្សនាកន្លងមក ។ ខ្សែភាពយន្តនេះបានឆ្លុះបញ្ចាំងពីសម័យដ៏ត្រចះត្រចង់នៃតន្ត្រីពេញនិយមរបស់ខ្មែរ ឋិតនៅចន្លោះសម័យទទួលបានឯករាជ្យ និងសម័យខ្មែរក្រហម ។ ខ្មែរក្រហមមិនត្រឹមតែសម្លាប់មនុស្សតែប៉ុណ្ណោះទេ ប៉ុន្តែខ្មែរក្រហមថែមទាំងបានបំផ្លាញសម្រស់នៃជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា បំផ្លាញសុភមង្គលដែលបានមកពីការរាំច្រៀងតាមចង្វាក់ភ្លេង និងបំផ្លាញអារម្មណ៍មនោសញ្ចេតនាដែលធ្លាប់មានក្នុងរោងភាពយន្ត ។ ដោយសារតែវប្បធម៌ ដ៏ប្រជាប្រិយរបស់កម្ពុជាសម័យឯករាជ្យ និងទំនើបត្រូវបានបំផ្លាញយ៉ាងធ្ងន់បំផុតនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តន្ត្រីពេញនិយមនាសម័យបច្ចុប្បន្នមានទឹកដមផ្អែមល្ហែម បែបអាឡោះអាល័យ ប៉ុន្តែ តន្ត្រីបច្ចុប្បន្នមានលក្ខណៈមិនពេញលេញ ដោយសារតែតន្ត្រីករខ្មែរភាគច្រើនតែងតែចម្លងតន្ត្រីពីតារាចម្រៀង ឡូឌីហ្កាហ្កា ឬចម្រៀងថៃ វៀតណាម ជាជាងតែងនិពន្ធចម្រៀង ដែលជាស្នាដៃខ្មែរពិតៗ ។

ខ្ញុំនឹកឃើញពីបទពិសោធរបស់ខ្ញុំក្នុងការធ្វើដំណើរទៅទីក្រុងញូវយ៉ក ក្រោយពីការវាយប្រហារពីសំណាក់ភេរវជននៅថ្ងៃទី១១ ខែកញ្ញា ។ កាលនោះ គឺនៅក្នុងរដូវក្តៅនាឆ្នាំ២០០៤ នៅពេលដែលខ្ញុំកំពុងរៀនច្បាប់ ហើយខ្ញុំរស់នៅ ដាំបូ ក្នុងទីក្រុងប្រ៊ូគគ្លីន ។ ខ្ញុំមិនមែនជាពលរដ្ឋ ដែលមានដើមកំណើតនៅក្រុងញូវយ៉ក ទេ ប៉ុន្តែនៅពេលដែលខ្ញុំដើរកាត់ស្ពាន ប្រ៊ូគគ្លីន ទៅធ្វើការនៅម៉ាហាតាន់ ខ្ញុំមានអារម្មណ៍ថាទីក្រុងញូវយ៉ក ហាក់បីដូចជាមានអន្លង់មួយយ៉ាងធំសម្បើម ហាក់បីដូចជាមានកន្លែងទំនេរមួយដែលគួរតែមានវត្តមានអ្វីម៉្យាងនៅទីនោះ ។

ខ្ញុំមិនមែន ជាជនជាតិខ្មែរនោះទេ ប៉ុន្តែនៅពេលដែលខ្ញុំរស់នៅទីក្រុងភ្នំពេញ ខ្ញុំតែងតែមានអារម្មណ៍ខ្វះខាតដូចគ្នាដែរពីអវត្តមាននៃសម្រស់ដ៏ត្រចង់ ដែលគួរតែមានវត្តមាននៅទីក្រុងភ្នំពេញនេះ ។ អ្នកដែលធ្លាប់បានទៅទស្សនាគុកទួលស្លែង និងវាលពិឃាតជើងឯក តែងតែមានប្រតិកម្មខុសៗគ្នាចំពោះកន្លែងទាំងពីរនេះ ប៉ុន្តែសម្រាប់ខ្ញុំ ទួលស្លែងជាកន្លែងដែលធ្វើឲ្យខ្ញុំស្រងេះស្រងោចចិត្តអារម្មណ៍ស្រងោចចិត្តដែលបន្សល់ពីភាពល្ហល្ហេវ ។ បន្ទប់ល្ហល្ហេវ នៅទួលស្លែង គឺជាកន្លែងដែលមានមនុស្សជាច្រើនត្រូវបានដាក់ច្រវាក់ វាយដំ ឆក់ខ្សែភ្លើង ដាក់ទណ្ឌកម្ម ចាក់ទឹកចូលច្រមុះ ហើយទណ្ឌកម្មទាំងនេះ កាន់តែធ្វើឲ្យអារម្មណ៍នូវភាពល្ហល្ហេវនេះកាន់តែធ្ងន់បន្ថែមទៀត ។ បន្ទប់ដែលមិនទំនេរ មានរូបថតមនុស្សរាប់ពាន់នាក់ដែលបានឆ្លងកាត់កន្លែងនេះ ហើយអ្នកខ្លះបានស្លាប់ដោយការដាក់ទណ្ឌកម្មនៅក្នុងបន្ទប់ដដែលនេះ ឬខ្លះទៀតត្រូវបានខ្មែរក្រហមវាយសម្លាប់នៅឯវាលពិឃាត ។ រូបថតនីមួយៗនៅទីនេះ តំណាងឲ្យចន្លោះខ្វះខាតនៃអន្លង់មួយរបស់ពិភពលោក ដែលមានទំហំស្មើនឹងមនុស្សម្នាក់ ។ ការបាត់បង់នូវអ្វីដែលមនុស្សគួរតែអាចធ្វើបាន មិនថាមនុស្សដែលបាត់បង់ទាំងនេះសាមញ្ញប៉ុណ្ណានោះទេ ពិតជាជាក់ស្តែងណាស់ ដោយសាររូបភាពទាំងនេះមើលទៅដូចមនុស្សដែលកំពុងតែនៅជុំវិញខ្លួនខ្ញុំ

ឥឡូវនេះអ៊ីចឹង គ្រាន់តែនៅក្នុងរូបថតមានសម្លៀកបំពាក់ពណ៌ខ្មៅដែលគ្មានភាពសប្បាយរីករាយនៃរបបដែលសម្លាប់គេទាំងអស់គ្នា ។ ការចងចាំទាំងនេះនៅស្រស់ៗនៅឡើយ ។ មុខរបួសក៏ហាក់បីដូចជានៅថ្មីៗដែរ ។

ហេតុដូច្នេះហើយ ខ្ញុំបានដឹងថាព្រឹត្តិការណ៍អស្ចារ្យមួយនឹងកើតឡើងនៅពេលដែលខ្ញុំអង្គុយទស្សនាខ្សែភាពយន្ត "កុំស្មានបងភ្លេច" នៅឯសាលមហោស្រពចតុមុខ ដែលជាកន្លែងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្រប់គ្រងដោយវៀតណាមធ្លាប់បានធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅឆ្នាំ១៩៧៩ ជាមួយនឹងវត្តមានស្ថាបត្យករដែលសាងសង់មហោស្រពនេះ ដែលជាបិតាទំនើបនិយមរបស់ខ្មែរ និង ជាភ្ញៀវកិត្តិយសមួយរូប ។ នៅកៅអីជួរខាងមុខ មានតន្ត្រីករ តន្ត្រីការិនីមួយចំនួនដែលបានរួចជីវិតពីសម័យខ្មែរក្រហម និងញាតិសន្តាននៃតន្ត្រីករ និងតន្ត្រីការិនីដែលត្រូវបានសម្លាប់ ក្រោមការចោទប្រកាន់ថាជាវរជនបញ្ញើខ្លួននិងអាយ៉ងរបស់ពួកចក្រពត្តិនិយម ។ នៅជុំវិញខ្លួនខ្ញុំ ពុំមានចន្លោះទំនេរឡើយ មហោស្រពទាំងមូល ពោរពេញទៅដោយអ្នកដែលធំដឹងក្តីឡើងស្តាប់ចម្រៀងទាំងនោះ ចម្រៀងខ្លះមានលក្ខណៈ ពិរោះរណ្ដំ ឯខ្លះទៀតមានលក្ខណៈប្រឡឹម និងគួរឲ្យខ្លាញ់ ។ អ្នកទាំងនោះមកកាន់ទីនេះដើម្បីសម្តែងភាពគោរកអរក្នុងការចងចាំ ហើយវាជាកិត្តិយសដែលខ្ញុំបានចូលរួមអង្គុយជាមួយទស្សនិកជនទាំងអស់នេះ ។

ខ្សែភាពយន្ត "កុំស្មានបងភ្លេច" បានរៀបរាប់អំពីប្រវត្តិសាស្ត្រកម្ពុជាយ៉ាងក្បោះក្បាយ ។ ប៉ុន្តែផ្នែកដ៏រំជើបរំជួលបំផុតរបស់ភាពយន្តនេះគឺអារម្មណ៍នៃអ្វីដែលនៅរស់រានមានជីវិតសម្រស់ភាពសប្បាយរីករាយ និងការចងចាំ ដែលនៅតែរស់រានពីរាល់ការប៉ុនប៉ងបំផ្លាញចោលទាំងស្រុងដោយខ្មែរក្រហម ។ នេះជាអ្វីដែលធ្វើឲ្យខ្ញុំស្រឡាញ់ប្រទេសកម្ពុជា និងទីក្រុងភ្នំពេញនេះខ្លាំងបំផុត ។ ទីនេះជាកន្លែងពិបាកមួយ ។ អ្នករស់នៅទីនេះត្រូវតស៊ូយ៉ាងខ្លាំង ប៉ុន្តែគេនៅតែអាចរស់បាន ។ នេះជាមូលហេតុ ដែលនាំឲ្យខ្ញុំស្រឡាញ់ និងគោរពទីក្រុងនេះជាខ្លាំង ។ នេះជាមូលហេតុដែលនាំឲ្យខ្ញុំមានការព្រួយបារម្ភ ដូចដែលខ្ញុំបារម្ភចំពោះក្រុមគ្រួសារខ្ញុំដែរ ។

ខ្សែភាពយន្ត "កុំស្មានបងភ្លេច" បានបញ្ចប់ដោយចម្រៀងមួយបទដែលខ្ញុំតែងតែឆ្ងល់អំពីអត្ថន័យរបស់វា ។ នៅពេលដែលអ្នកទៅទស្សនាវាលពិឃាតជើងឯក អ្នកនឹងទទួលបានមគ្គុទេសក៍សំឡេងដ៏អស្ចារ្យ ដែលបញ្ចប់នៅចេតិយរំឭកវិញ្ញាណក្ខន្ធមួយកម្ពស់ប្រាំពីរជាន់ ដែលជាកន្លែងតម្កល់ឆ្អឹងជនរងគ្រោះដែលត្រូវបានសម្លាប់នៅទីនោះ ។ ក្រោយពីការពន្យល់ចុងក្រោយអំពីចេតិយ មគ្គុទេសក៍សំឡេងនោះនឹងផ្តល់ជូននូវចម្រៀងខ្មែរមួយបទ ។ ខ្ញុំមិនសូវចេះនិយាយខ្មែរទេ ហើយពាក្យក្នុងចម្រៀងដែលខ្ញុំស្តាប់បានមានតែពាក្យ "ឱ!ភ្នំពេញអើយ" ។ ខ្សែភាពយន្ត "កុំស្មានបងភ្លេច" បានបញ្ចប់ដោយឯកសាររូបភាពដ៏កម្រមួយដែលបង្ហាញអំពីសកម្មភាពនៃការធ្វើដំណើរត្រឡប់មកទីក្រុងភ្នំពេញវិញក្រោយវៀតណាមបានផ្តួលរំលំពួកខ្មែរក្រហមនៅឆ្នាំ១៩៧៩ ។ ទីក្រុងភ្នំពេញក៏ចាប់ផ្តើមមានជីវិតឡើងវិញ នៅពេលដែលបទ "ឱ!ភ្នំពេញអើយ" បានបន្លឺឡើងព្រមជាមួយនឹងការបកប្រែជាភាសាអង់គ្លេសនៅបន្ទាត់ខាងក្រោម ។ ខ្ញុំជឿថាគ្មាននរណាម្នាក់នៅក្នុងសាលមហោស្រពនេះមិនស្រក់ទឹកភ្នែកនោះទេ ។ ឥឡូវខ្ញុំបានដឹងពីមូលហេតុហើយ ។

ខ្ញុំត្រូវបានអញ្ជើញចូលរួមការចាក់បញ្ចាំងជាលើកដំបូងនេះដោយមិត្តភក្តិខ្មែរអាមេរិកាំងវ័យក្មេងម្នាក់ ដែលធ្វើការពាក់ព័ន្ធនឹងខ្សែភាពយន្តនេះ ។ គាត់ស្រឡាញ់កម្ពុជា និងដូនតារបស់គាត់ដោយការស្វែងរក និងថែរក្សាតន្ត្រីរបស់ខ្មែរ ។ ខ្ញុំសូមអរគុណចំពោះមិត្តភក្តិរបស់ខ្ញុំ និងខ្សែភាពយន្ត "កុំស្មានបងភ្លេច" ។ ឥឡូវខ្ញុំបានយល់ពីអត្ថន័យនៃបទ "ឱ!ភ្នំពេញអើយ" ហើយ ។ "ឱ!ភ្នំពេញអើយ" ជាបទមនោសញ្ចេតនា នៃក្រុងដ៏មានមន្តស្នេហ៍មួយនេះ ។ បទនេះនិពន្ធដោយមនុស្សម្នាក់ដែលវិលត្រឡប់មកផ្ទះវិញក្រោយពីទទួលរងនូវភាពអត់ឃ្លាននៅក្នុងសម័យខ្មែរក្រហមអស់រយៈពេលជាងបីឆ្នាំ ដោយការបង្ខំឲ្យចាកចេញទៅទីជនបទដាច់ស្រយាលនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដូចនឹងប្រជាជនខ្មែរដទៃទៀតដែរ ។ ជាមនុស្សម្នាក់ដែលតែងតែនៅឆ្ងាយពីផ្ទះ បទនេះជាបទមួយក្នុងចំណោមបទដែលធ្វើឲ្យខ្ញុំមានអារម្មណ៍រំជួលចិត្តយ៉ាងជ្រាលជ្រៅបំផុត ។

**អេរិច ហាសប៊េត**

# ចាន់ ស៊ាន់ ហៅ សាម ក្នុងបដិវត្តន៍ខ្មែរក្រហម


ចាន់ ស៊ាន់ ហៅ សាម

ចាន់ ស៊ាន់ ហៅ សាម អាយុ៦៨ឆ្នាំ ជាអតីតយោធាខ្មែរក្រហម ។ ស៊ាន់ មានស្រុកកំណើត នៅឃុំត្រពាំងរាំង ស្រុកជុំគិរី ខេត្ត កំពត ។ ស៊ាន់ មាន ឪពុក ឈ្មោះ ប៉ិញ សុខ ម្តាយឈ្មោះ ជា ផុង មានបងប្អូនបង្កើតចំនួនដប់នាក់ ស្រីពីរនាក់ ប្រុសប្រាំបីនាក់ ។

កាលពីក្មេង ស៊ាន់ រៀនបានត្រឹមថ្នាក់ទី៧ "ចាស់" ។ នៅឆ្នាំ១៩៦១ ស៊ាន់ បានឈប់រៀន រួចមកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ នៅឆ្នាំ១៩៦៤ បានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធឈ្មោះ ជិន ណៃ ហៅ ឃួយ សព្វថ្ងៃ មានកូនប្រាំមួយនាក់ (ប្រុសបួន ស្រីពីរ) ។ ក្រោយពីរៀបការរួច ស៊ាន់ និងប្រពន្ធបានប្រកបរបរ ធ្វើស្រែចម្ការ ។

នៅពេលមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ឆ្នាំ១៩៧០ ស្ថានភាពនយោបាយក្នុងប្រទេសមានការផ្លាស់ប្តូរ ។ ប្រជាជននៅតាមស្រុកស្រែចម្ការ នៅតាមតំបន់ដាច់ស្រយាលមានកំហឹងនឹងរបបលោកសេនាប្រមុខ លន់ នល់ តាមរយៈការឃោសនាពីថ្នាក់ភូមិឃុំ និងបានស្តាប់ការប្រកាសរបស់សម្តេច សីហនុ តាមវិទ្យុពីទីក្រុងប៉េកាំង ប្រទេសចិន ឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីរំដោះជាតិ ។

នៅឆ្នាំ១៩៧១ ស៊ាន់ និងយុវជនជាច្រើននាក់ បានចូលព្រៃម៉ាគី ដំបូងនៅក្នុងខេត្តកំពង់ស្ពឺ ។ អ្នកចូលរួមចលនានៅពេលនោះមានគ្នាប្រហែលជា៣០០នាក់ ប៉ុន្តែមិនទាន់រៀបចំជាកងពលទេ គឺមានតែវរសេនាធំលេខ៣៥ ដែលមានប្រធានវរសេនាធំឈ្មោះ ង៉ែតគីន ប្រធានវរសេនាតូចឈ្មោះ ឡាំ នៅភូមិភាគនិរតី ។

នៅឆ្នាំ១៩៧២ ស៊ាន់ បានចូលនៅក្នុងកងពលទី១ ដែលមានប្រធានកងពលឈ្មោះ សឿង ឈ្មោះ ឆន និងឈ្មោះ សេង ។ នៅពេលនោះ ស៊ាន់ជាប្រធានកងធំ មានមុខសញ្ញាវាយចូលទីក្រុងភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៣ ។ នៅឆ្នាំ១៩៧៥ ស៊ាន់ បានរងរបួស ហើយបានសម្រាករយៈពេលបីថ្ងៃដោយមិនបានវាយចូលក្រុងភ្នំពេញទេ ។ ប៉ុន្តែពេល ស៊ាន់ ធ្វើដំណើរបន្តចូលមកដល់ភ្នំពេញ គាត់បានឃើញប្រជាជនកំពុងនាំគ្នាចាកចេញពីទីក្រុងទៅរស់នៅតំបន់ផ្សេងៗ ។

ក្រោយឆ្នាំ១៩៧៥ ស៊ាន់ បានប្តូរទៅនៅក្នុងកងពល ៥០២ គ្រប់គ្រងដោយឈ្មោះ ស៊ូ ម៉េត ។ កងពល៥០២ មានបីវរសេនាធំ រួមបញ្ចូលគ្នា គឺវរសេនាធំ៥១, ៥២ និង ៥៣ ហើយ ស៊ាន់ មានឋានៈជាប្រធានអនុសេនាធំ គ្រប់គ្រងយោធាចំនួន ៥០០នាក់ ។

នៅឆ្នាំ ១៩៧៨ ស៊ាន់ អង្គភាពចាត់តាំងឲ្យទៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដោយមានឋានៈជាអនុវរសេនាធំ នៃកងពល ៥០២ គ្រប់គ្រងដោយគណៈកងពលឈ្មោះ តា រ៉ៃ ។ យោធាខ្មែរក្រហមនៅទីនោះ មានរាប់ម៉ឺននាក់ដែលសុទ្ធតែអ្នកជាប់និន្នាការក្បត់ មកពីភូមិភាគបូព៌ា ភូមិភាគឧត្តរ និងភូមិភាគផ្សេងៗទៀត មកធ្វើការលត់ដំ ។ នៅទីនោះ មានជំនាញការដែលជាជនជាតិចិនរាប់រយនាក់ ធ្វើការសាងសង់ផ្លូវព្រលានយន្តហោះ និងអគារ ។

ខ្មែរក្រហមបាននាំគ្រឿងយន្តហោះ ពីប្រទេសចិនបានមួយចំនួន ដើម្បីរៀបចំតម្លើងសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ។

នៅឆ្នាំ១៩៧៨ ដដែល ស៊ាន់ ត្រូវអង្គការចាត់តាំងឲ្យមកភ្នំពេញវិញដោយឲ្យនៅកន្លែងរថភ្លើង ។ នៅឆ្នាំ១៩៧៩ ស៊ាន់ បានរត់ភៀសខ្លួន និងបែកពីប្រពន្ធ កូន ទៅជាយដែនថៃ។ ស៊ាន់ បានជួបជុំប្រពន្ធកូននៅពេលទៅដល់ព្រំដែនខ្មែរ-ថៃ នៅម្តុំម៉ុបឺ ។ ក្រោយមក ខ្មែរក្រហមបានរៀបចំកងទ័ព និងកងពលឡើងវិញ ដើម្បីវាយជាមួយកងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលលោក ហេង សំរិន ។ កាលនោះ យោធាខ្មែរក្រហមបានទទួលជំនួយពីប្រទេសចិនទាំងសម្ភារ និង អាវុធគ្រប់ធុន ។ ស៊ាន់ មានឋានៈជាអនុវរសេនាធំនៃកងពល៦១២ ដឹកនាំយោធាចំនួន១៥០នាក់ វាយប្រយុទ្ធជាមួយកម្លាំងរដ្ឋាភិបាល ។ ក្រៅពីនោះ ស៊ាន់ មានភារកិច្ចអូសទាញ និងអប់រំប្រជាជនឲ្យយល់ពី គោលនយោបាយខ្មែរក្រហមដើម្បីដេញយួនចេញពីប្រទេសកម្ពុជា ។ ប្រជាជនភាគច្រើនបានគាំទ្រកម្លាំងខ្មែរក្រហម និងបានជួយផ្តល់ស្បៀង និងរាយការណ៍ព័ត៌មានឲ្យខ្មែរក្រហម ។

នៅឆ្នាំ១៩៨៨ ស៊ាន់ បានឡើងមកនៅអន្លង់វែងវិញ ហើយបានដឹកនាំប្រជាជននៅសមរភូមិ ក្រោយដែលពិការ និងរងរបួស ។ នៅឆ្នាំ១៩៩០ តាម៉ុក បានធ្វើផ្លូវចុះពីលើភ្នំដងរែក និងបន្តធ្វើផ្លូវតាមព្រំដែនខ្មែរ-ថៃរហូតដល់ប្រាសាទព្រះវិហារ និងនាំប្រជាជនចុះមករស់នៅជើងភ្នំ ដែលខ្លះនៅស្រុកអន្លង់វែង ខ្លះនៅស្រុកត្រពាំងប្រាសាទ ។ នៅឆ្នាំ១៩៩៣ កងកម្លាំងរដ្ឋាភិបាលបានធ្វើការវាយប្រហារទៅលើកម្លាំងខ្មែរក្រហម ធ្វើឲ្យប្រជាជនរស់នៅតំបន់នោះរត់ទៅរស់នៅជំរំអូរត្រាវ និងតំបន់មួយចំនួនទៀតជាប់ប្រទេសថៃ ។ រហូតដល់ឆ្នាំ១៩៩៤ ទើបកម្លាំងខ្មែរក្រហមវិលមករស់នៅកន្លែងដើមវិញ (អន្លង់វែង និងត្រពាំងប្រាសាទ) ។

នៅឆ្នាំ១៩៩៤ ដដែល ស៊ាន់ ត្រូវ តាម៉ុក ចាត់តាំងឲ្យធ្វើជាចៅហ្វាយស្រុកត្រពាំងប្រាសាទ ។

ក្រោយមកទៀតកម្លាំងខ្មែរក្រហមបានបែកបាក់គ្នា ដោយ តាម៉ុក កាត់ទោស ប៉ុល ពត ក្រោយពីមានព្រឹត្តិការណ៍សម្លាប់គ្រួសារលោក សុន សេន ទាំងគ្រួសារ ។ តាម៉ុក បានបញ្ជាឲ្យចាប់ប្រធានកងពលឈ្មោះ តាសារឿន ហៅ ០៥ ឈ្មោះ តាសាន ហៅ ០៦ យកទៅសម្លាប់នៅក្នុងរណ្តៅតែមួយ ។ តា ម៉ុក ចាប់ផ្តើមសង្ស័យ ប្រធានកងពលផ្សេងទៀតថា មានគម្រោងងាកទៅរករដ្ឋាភិបាលភ្នំពេញ និងចង់បែងចែកកម្លាំងជាពីរ គឺនៅខាងស្រុកអន្លង់វែង ជាកម្លាំងរបស់ តាម៉ុក ខាងស្រុកត្រពាំងប្រាសាទ ជាកម្លាំងគាំទ្រលោក ប៉ុល ពត ដែលមានបួនកងពល គឺកងពល៦១២, ៦១៦, ៤១៧ និង ៨០២ ។

នៅចុងឆ្នាំ១៩៩៨ តា ម៉ុក បានហៅឈ្មោះ កែវ, សារី សយ, ជុំ ជាតិ និង វ៉ាយ ពីន ឲ្យមករៀនសូត្រនយោបាយនៅសាលាស្រុកអន្លង់វែង (នៅម្តុំធនាគារអេស៊ីលីដា សព្វថ្ងៃ) ។ កាលនោះ ដោយសារ កែវ, សារី សយ, ជុំ ជាតិ និង វ៉ាយ ពីន ធ្លាប់ស្គាល់ឈ្មោះ ខឹម ង៉ុន ជាប្រធានគ្រប់គ្រងនៅទីនោះក៏បានសុំចេញមកខាងក្រៅដោយបានប្រាប់ថា មកប្រមូលស្បៀងដើម្បីធ្វើកន្លែងរស់នៅ ។ ទទួលបានឱកាសល្អ អ្នកទាំងនោះក៏រកផ្លូវមកជួបជាមួយកម្លាំងរដ្ឋាភិបាល ព្រោះគិតថា បើនៅទីនោះបន្តទៀតពិតជាស្លាប់មិនខាន ។ ដោយសារយល់ដូចនេះ ជុំ ជាតិ បាននាំកម្លាំងមួយចំនួនធ្វើដំណើរឆ្លងកាត់ព្រៃទាំងយប់ទាំងថ្ងៃ ទើបទៅដល់ខេត្តព្រះវិហារ ហើយបានជួបជាមួយនឹងអភិបាលរងខេត្តឈ្មោះ ឃួយ ឃុនហួរ ។ ក្រោយពីការទទួលរាក់ទាក់ ខួយ ឃុនហួរ បានទាក់ទងទៅភ្នំពេញ ហើយថ្ងៃបន្ទាប់អ្នកទាំងបួននាក់នេះក៏ធ្វើដំណើរតាមឧទ្ធម្ភាគចក្រមកភ្នំពេញ ដោយទុកប្រពន្ធកូន និងប្រជាជនមួយចំនួននៅខេត្តព្រះវិហារ ។ ក្រោយមក ក៏មានយន្តហោះបោះ ត្រាក់នៅតំបន់ខ្មែរក្រហម ឲ្យកម្លាំងខ្មែរក្រហមទាំងអស់ចុះចូលជាមួយរដ្ឋាភិបាល ដោយរដ្ឋាភិបាល មិនយកទោសពៃរ៍ ។ បន្ទាប់មកទៀត ទើប ស៊ាន់ ដឹងថា នៅអន្លង់វែងក៏មានគម្រោងចុះចូលជាមួយ រដ្ឋាភិបាលដែរ ដូចជាប្រធានកងពលឈ្មោះ យឹម ផាន់ណា, យឹម ពឹម និង យឹម សាន ។ កម្លាំងខ្មែរក្រហមទាំងអស់បានធ្វើការសម្រេចចិត្តធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ តែម្តង ដោយនៅពេលនោះ ស៊ាន់ នៅធ្វើជាអភិបាលស្រុកត្រពាំងប្រាសាទ ។

សព្វថ្ងៃ ស៊ាន់ មាន តួនាទីជាក្រុមប្រឹក្សាស្រុកត្រពាំងប្រាសាទ រស់នៅ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**សុខ ខណ្ណៈ**

# វឿង ស៊ីន ៖ «អតីតកាល នៅតែធ្វើឱ្យខ្ញុំរន្ធត់ និងសោកស្តាយ»

រហូតមកដល់បច្ចុប្បន្ន អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលស្ម័គ្រចិត្តចូលបម្រើឲ្យចលនាបដិវត្តន៍ខ្មែរក្រហម តាំងពីអាយុ ១៨ឆ្នាំ នៅតែរន្ធត់ និងសោកស្តាយចំពោះទង្វើរបស់ខ្លួនដែលបានបណ្តាលឲ្យអ៊ីរបស់គាត់ម្នាក់ស្លាប់បាត់បង់ជីវិត ។


វឿង ស៊ីន

វឿង ស៊ីន សព្វថ្ងៃអាយុ៥៥ឆ្នាំ រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដែលជាតំបន់រឹងមាំរបស់ចលនាខ្មែរក្រហមកាលពីទសវត្សរ៍៩០ បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅភូមិស្រែឫស្សី ឃុំសំរោង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។ គាត់មានឪពុកឈ្មោះ ស៊ីន និងម្តាយឈ្មោះ តាយ និងមានបងប្អូនប្រាំមួយនាក់ ។ គាត់បានចូលបដិវត្តន៍នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៤ ។

នៅឆ្នាំ១៩៧៥ ស៊ីន បានចូលកងតំបន់១០៤ ដែលមានគណៈតំបន់ឈ្មោះ ប៉ិត ។ នៅឆ្នាំដដែល ស៊ីន បានទៅឈរជើងនៅអូរតាង៉ូវ និងភូមិខិ ស្ថិតនៅតាមបណ្តោយព្រំដែនឡាវ ក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ។ ក្រោយមក អង្គការបានជ្រើសរើស ស៊ីន និងកងតំបន់ផ្សេងទៀតឲ្យទៅរៀនបើកយន្តហោះ នៅប្រទេសចិន ។ ប៉ុន្តែដោយសារអង្គការ ស្រាវជ្រាវរកឃើញថា ជីតារបស់គាត់ធ្លាប់ធ្វើមន្ត្រីរដ្ឋការក្នុងរបប លន់ នល់ ទើបអង្គការដកគាត់ និងមិត្តភក្តិគាត់ម្នាក់ទៀតឈ្មោះ រំសាយ (ក្រោយមកធ្វើមេភូមិនៅខេត្តប៉ៃលិន) មកដាក់នៅមន្ទីរភូបាំងវិញ ។ ចំណែកអ្នកផ្សេងទៀតអង្គការ បានបញ្ជូនបន្តទៅភ្នំពេញ ។ ស៊ីន នៅមន្ទីរបានមួយរយៈអង្គការក៏ដកគាត់ឲ្យមកធ្វើជានីរសារប្រធានសហករណ៍សម្បូរណ៍វិញ ។ ស៊ីន ធ្វើការនៅសហករណ៍បានរយៈពេលជិតមួយខែ តាយ៉ែង គណៈស្រុកសៀមប៉ាង ដែលស្រឡាញ់ និងរាប់អាន ស៊ីន បានយក ស៊ីន មកធ្វើជានីរសាររបស់ស្រុកវិញ ។

នៅក្រោយពេលអង្គការបានចាប់ខ្លួនគណៈតំបន់ឈ្មោះ ប៉ិត ដោយចោទថាក្បត់ ហើយដាក់ឈ្មោះ វឿន អតីតប្រធានកងពលទី១ ភូមិភាគបស្ចិមឲ្យមកគ្រប់គ្រងជំនួស ។ វឿន ក៏បានសុំយក ស៊ីន ពីស្រុកឲ្យមកធ្វើជាអង្គរក្ស (នីរសារ) របស់គាត់ផ្ទាល់ ។ នៅទីនោះ ស៊ីន រួមជាមួយ ឆុន, ឡាយ, លាង, អឿន ស (បច្ចុប្បន្នរស់នៅអន្លង់វែង) និង អឿន ខ្មៅ ព្រមទាំងពេទ្យម្នាក់ តែងតែអមដំណើរ វឿន ចុះទៅពង្រឹងសហករណ៍នៅតាមស្រុក ក្នុងខេត្តស្ទឹងត្រែង និងទៅចាប់អ្នកទោស ។ ពេលចុះទៅម្តងៗ មានឡានបីគ្រឿងអមដំណើរទៅជាមួយ ដោយឡាននីរសារ ឬអង្គរក្ស នៅខាងមុខ ឡានរបស់ វឿន នៅកណ្តាល ចំណែកឡានពេទ្យ និងអ្នកដាំស្លនៅខាងក្រោយ ។ នៅពេលទៅដល់សហករណ៍ វឿន តែងតែនិយាយពីការបង្កបង្កើនផល រីឯការចាប់អ្នកទោស គណៈតំបន់ប្រាប់តែនីរសារដែលមានអាយុច្រើនជាង ស៊ីន ដឹងប៉ុណ្ណោះ ។

ស៊ីន បានរៀបរាប់ថា មុនពេលចាប់ខ្លួន វឿន បានឲ្យប្រធានភូមិទៅហៅអ្នកទោសដោយប្រាប់ថាមកជួប និងឲ្យធ្វើការជាមួយគណៈតំបន់ ។ ប៉ុន្តែខណៈនោះ ឡានហ្ស៊ីបរបស់គណៈតំបន់ដែលមានអង្គរក្សពីរនាក់នៅអមឡានសម្រាប់នីរសារ និងឡានសម្រាប់ពេទ្យ និងអ្នកដាំស្ល នៅរង់ចាំរួចជាស្រេច ។ បន្ទាប់ពីអ្នកទោសឡើងជិះឡានជាមួយ វឿន រួចរាល់ហើយ អ្នកបើកបរបានបើកឡាន ចេញពីភូមិបានប្រមាណមួយគីឡូម៉ែត្រក៏ឈប់ឡានដោយកុហកថាឡានខូច រួចហើយឲ្យអ្នកទោសដែល ជិះជាមួយ វឿន ចុះជួយរុញឡាន ។ ភ្លាមនោះ កងនីរសារបីនាក់ បានចុះទៅចាប់ខ្លួនអ្នកទោស រួចហើយចងស្លាបសេក និងរុំមុខតែម្តង ។

អ្នកទោសភាគច្រើន ត្រូវបានកងនីរសារយកទៅសួរចម្លើយនៅក្នុងព្រៃ ដោយមិនមានបិច និងក្រដាស់សម្រាប់កត់ត្រាទេ ។ បន្ទាប់ពីសួររួច កងនីរសារ សម្លាប់អ្នកទោសនោះចោលតែម្តង ។

នៅយប់មួយ វឿន បានបញ្ជាឲ្យ ឡាយ និងកងនីរសារទៅចាប់ពូរបស់ ស៊ីន ម្នាក់ឈ្មោះ ជង់ (ធ្វើជាមេឃុំ) ពីភូមិគត់ឡុំលិត និងអ្នកទោសបួននាក់ទៀត យកមកអូរននោង (បច្ចុប្បន្ន ឃុំសន្តិភាព) ។ នៅតាមផ្លូវ អ្នកទោសដែលមានមាឌធំម្នាក់បានរបូតខ្សែចំណងរួចហើយលោតចុះពីលើឡាន តែត្រូវនីរសារឈ្មោះ ឆុន បាញ់សម្លាប់ ។ ពេល ស៊ីន មកដល់ឃើញអ៊ំរបស់គាត់យំ ព្រមទាំងភិតភ័យរហូតដល់រាកប្រឡាក់ខោ ។ ប៉ុន្តែស៊ីនមិនបាននិយាយជាមួយអ៊ំរបស់គាត់ទេ ។ នៅវេលាម៉ោង៧យប់ អឿន និងនីរសារពីរនាក់ទៀតបានបណ្តើរអ៊ំរបស់ ស៊ីន យកទៅព្រៃ នៅចុងទំនប់ដែលមានចម្ងាយប្រមាណ១០០ម៉ែត្រពីឡានដឹកអ្នកទោស ។ នៅទីនោះ ស៊ីន ត្រូវបានបញ្ជាឲ្យដឹករណ្តៅកប់អ៊ំរបស់គាត់ ។ ស៊ីន មានការភិតភ័យ និងរន្ធត់យ៉ាងខ្លាំង ។ អ៊ំរបស់ ស៊ីន ត្រូវបាន អឿន វាយសួរចម្លើយ និងធ្វើទារុណកម្មដោយចាក់នឹងចំពុះទុង បន្ទាប់មកវាយនឹងត្បូងចប ។ ប៉ុន្តែទោះបីធ្វើទារុណកម្មធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ ស៊ីន ឃើញអ៊ំរបស់គាត់នៅមានស្មារតីរឹងមាំ និងបាននិយាយថា "ខ្លួនគាត់មិនមែនជាខ្សែបង្កប់ សេ.អ៊ី.អា ទេ" ។ អ៊ំរបស់ ស៊ីន ត្រូវ អឿន សួរចម្លើយរយៈពេលមួយម៉ោង គឺចាប់ពីម៉ោង៧យប់ រហូតដល់ម៉ោង៨យប់ ទើបសម្លាប់ចោល ។ ចំណែកអ្នក ទោសបីនាក់ផ្សេងទៀត វឿន បានយកទៅសម្លាប់នៅព្រៃក្បែរមាត់ទន្លេ ។ ក្រៅពីអ៊ំរបស់ ស៊ីន, វឿន បានបញ្ជាឲ្យកងនីរសារសម្លាប់បងថ្លៃរបស់ ស៊ីន ឈ្មោះ ធី ហៅ សា និងពូរបស់គាត់ម្នាក់ទៀតឈ្មោះ ខាំ ។

ស៊ីន បានបន្តថា ការសម្លាប់អ្នកទោសនៅពេលនោះគឺធ្វើតាមបញ្ជារបស់ វឿន ផ្ទាល់តែម្តង ដោយមិនបានឆ្លងកាត់មន្ទីរសន្តិសុខនៅអូរពងមាន់ ក្នុងខេត្តស្ទឹងត្រែង ដែលមានឈ្មោះ ខាំ



ច្រកព្រំដែនខ្មែរ-ថៃ នៅអូរស្មាច់ ស្ថិតនៅស្រុកសំរោង ខេត្តឧត្តរមានជ័យ

វឿន ជាប្រធានទេ ។

នៅខណៈនោះដែរ កងយោធាបានធ្វើការចាប់ខ្លួនប្រជាជនដែលធ្វើការនៅក្នុងសហជីព នៅចម្ការកៅស៊ូស្រុកពញាក្រែក ស្រុកមេមត់ និងខេត្តព្រះវិហារ ដែលរត់មកខេត្តស្ទឹងត្រែង យកមកដាក់នៅមន្ទីរក្រោម (ស្ថិតនៅកំពង់ដែខេត្តស្ទឹងត្រែងសព្វថ្ងៃ) ជាកន្លែងដែល ស៊ីន ធ្វើការដែរ ។ អ្នកទោសទាំងនោះត្រូវបានឃុំឃាំងនៅក្នុងរោង បន្ទាប់មកទើបកងនីរសារសួរចម្លើយ ។ នៅទីនោះ ស៊ីន បានលួចផ្តល់អាហារឲ្យអ្នកទោសមួយចំនួនហូប ។ អ្នកទោសទាំងអស់ត្រូវបានបញ្ជូនឲ្យទៅអង្គភាពរៀងៗខ្លួនវិញ ក្រោយពេលកងនីរសារសួរចម្លើយរួច ។ ប៉ុន្តែ ស៊ីន មិនដឹងថាអ្នកទោសទាំងនោះ ស្លាប់ ឬរស់ទេ បន្ទាប់ពីត្រឡប់ទៅកងវិញ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ វឿន បានចាត់តាំង ស៊ីន គ្រប់គ្រងក្មេងៗប្រមាណ១០០នាក់ ដែលជ្រើសរើសមកពីភូមិក្នុងខេត្តស្ទឹងត្រែង ។ ក្មេងៗទាំងនោះត្រូវ ស៊ីន ហ្វឹកហ្វឺនឲ្យធ្វើជាយោធា រួចហើយបញ្ចូលទៅអង្គភាពតំបន់ដើម្បីត្រៀមទៅវាយនៅតាមព្រំដែន ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៨ ពេលវៀតណាមវាយចូលមក ស៊ីន បានរំសាយក្មេងៗទាំងនោះឲ្យទៅតាមស្រុកភូមិវិញ ។ ចំណែក ស៊ីន បានទទួលបញ្ជាមកពីតំបន់ឲ្យជម្លៀសប្រជាជនចេញពីខេត្តស្ទឹងត្រែង ។ ស៊ីន ជម្លៀសប្រជាជនបានប្រមាណ១០កាណូតកាត់តាមទន្លេទៅខេត្តព្រះវិហារ តែត្រូវកងទ័ពវៀតណាមវាយស្ទាក់ និងកៀរប្រជាជនត្រឡប់មកវិញ ។ ឃើញដូច្នេះ ស៊ីន បាននាំកងនារីតំបន់ប្រមាណ៣០នាក់ ឆ្លងពីអូរស្វាយនៃខេត្តស្ទឹងត្រែងមកព្រះនន្ទ័ល (ស្ថិតនៅជាប់ព្រំប្រទល់ប្រទេសឡាវ) នៃខេត្តព្រះវិហារ ។ នៅទីនោះ ស៊ីន បានជួបម្តាយ និងបងប្អូនដែលបានរត់ភៀសខ្លួនទៅប្រទេសឡាវ ។ បន្ទាប់មក ស៊ីន ក៏បន្តដំណើរមកអូរស្រឡៅ ស្ថិតនៅក្នុងស្រុកឆែប ខេត្តព្រះវិហារ ហើយក៏បានជួបមេរបស់គាត់ឈ្មោះ វឿន ។

នៅព្រះវិហារបានមួយរយៈ ស៊ីន បានធ្វើដំណើរបន្តមកអន្លង់វែង ដោយពេលនោះមានតែកងពិសេស និងកងថ្មើរជើងសម្រាប់ការពារប្រជាជន និងគ្រួសារទាហានប៉ុណ្ណោះ ។ ក្រោយមកទើបខ្មែរក្រហមរៀបចំជាកង, វរសេនាតូច និងវរសេនាធំ ហើយគាត់បានទទួលបញ្ជាឲ្យទៅវាយជាមួយ កងទ័ពវៀតណាម ដើម្បីកៀរយកប្រជាជននៅតាមបណ្តោយព្រំដែនទិសពាយ័ព្យ និងនៅបន្ទាយឆ្មារ ក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ បន្ទាប់មកគាចៀម ធ្វើការនៅមន្ទីររបស់ ប៉ុល ពត បានដក ស៊ីន មកនៅអង្គភាព៨០៨ ឬ ប-១ ឬ ត្រាច់ប-១ (ជាអង្គភាពបង្កើតឡើងដំបូង) ដើម្បីទាក់ទង ជាមួយថៃក្រហម ។ នៅក្នុងអង្គភាព ស៊ីន ក៏មានភារកិច្ចដើរប្រមូលប្រជាជនដែលមកពីខេត្តកណ្តាល ខេត្តកំពង់ធំ និង ប្រជាជនដែលវង្វេង និងអត់បាយនៅក្នុងព្រៃឲ្យឡើងទៅរស់នៅលើភ្នំដែរ ។ ក្រោយពីនោះ ស៊ីន បានដឹកនាំកម្លាំងទៅទាក់ជាមួយទាហានប៉ារ៉ា ដែលដឹកនាំដោយ សឹន សាន ដោយគាត់បានសរសេរអក្សរសម្គាល់នៅតាមជញ្ជាំងថ្មថា “ខ្មែរមិនវាយគ្នា គឺរួបរួមគ្នាវាយយួន” ដើម្បីជៀសវាងការប៉ះទង្គិចគ្នា ។

ក្រោយមក ស៊ីន បានទទួលបញ្ជាពីថ្នាក់លើឲ្យដើរបើកច្រកបន្ថែមទៀត ដើម្បីទាក់ទងជាមួយ ភាគីថៃ ដែលមានច្រក១០០៣ ច្រក១០០២ និងច្រក១០០១ ។ តមកទៀត ស៊ីន បានប្តូរមកនៅកងអន្តរាគមន៍ របស់កងពល៩១២ ហើយគាត់បានទទួលការចាត់តាំងឲ្យចុះទៅធ្វើការនៅខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម និងខេត្តក្រចេះ ។ ប៉ុន្តែពេលនោះ ស៊ីន បានរងរបួសនៅសមរភូមិបឹងទន្លេសាប ទើបអង្គភាពដកគាត់ត្រឡប់មកធ្វើជាប៉ូលីសនៅជំរំភូណយ (ស្ថិតនៅក្នុងប្រទេសថៃ) ដែលគ្រប់គ្រងដោយខ្មែរក្រហមវិញ ។ ស៊ីន នៅជំរំរហូតដល់ខ្មែរក្រហម ធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៨ ទើបគាត់ត្រឡប់មករស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យវិញ ។

ស៊ីន បាននិយាយថា ចាប់តាំងពីគាត់ចូលបដិវត្តន៍ គាត់បានជួបម្តាយគាត់បីដងប៉ុណ្ណោះ ។ លើកទីមួយ គាត់ជួបម្តាយគាត់នៅឆ្នាំ១៩៧៧ ពេលដែលគាត់មានជំងឺ ហើយម្តាយគាត់សុំយកគាត់ពីអង្គភាពតំបន់ទៅព្យាបាលនៅផ្ទះវិញ ។ លើកទីពីរ គាត់ជួបម្តាយនៅព្រះនន្ទ័ល នៅចុងឆ្នាំ១៩៧៨ ពេលវៀតណាមវាយចូលមក និងលើកទីបី គាត់បានសម្រេចចិត្តត្រឡប់ទៅរកម្តាយ និងបងប្អូននៅស្រុកកំណើត កាលពីឆ្នាំ២០១២កន្លងទៅនេះ ទោះបីគាត់ដឹងថា អ្នកភូមិមួយចំនួនមិនពេញចិត្តនឹងទង្វើរបស់គាត់ពីអតីតកាលក៏ដោយ ។

**សោម ប៊ុនថន**

# ហេតុផលសំខាន់ៗដែលនាំឱ្យខ្មែរក្រហមបានឡើងកាន់អំណាច

ចលនាខ្មែរក្រហម ជាចលនាតស៊ូប្រដាប់អាវុធរបស់ខ្មែរមួយក្រុមប្រកាន់លទ្ធិកុម្មុយនីស្ត ដែលដំបូងឡើងចលនានេះមានលក្ខណៈតូចតាច ធ្វើការប្រឆាំងនឹងរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដោយមានសម្តេចព្រះនរោត្តម សីហនុ ជាប្រមុខរដ្ឋ ។ ប៉ុន្តែក្រោយពីសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានសេនាប្រមុខ លន់ នល់ ទម្លាក់ពីតំណែងជាប្រមុខរដ្ឋ ព្រះអង្គបានចូលរួមជាមួយខ្មែរក្រហមធ្វើឲ្យចលនានេះកើនកម្លាំងរឹងមាំជាងមុន ដោយទទួលបានការគាំទ្រពីប្រទេសចិន វៀតណាម និងជាពិសេសពីសំណាក់ប្រជាជនខ្មែរខ្លួនឯងផ្ទាល់ផង ។ យោធាខ្មែរក្រហមប្រើរយៈពេលតែប្រាំឆ្នាំប៉ុណ្ណោះ អាចវាយបណ្តេញរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ ដែលមានសហរដ្ឋអាមេរិកជាខ្នងបង្អែកឲ្យធ្លាក់ចេញពីតំណែង ។ អត្ថបទនេះនឹងរៀបរាប់ពីមូលហេតុមួយចំនួនដែលធ្វើឲ្យចលនាខ្មែរក្រហមប្រើរយៈពេលខ្លីតែអាចឈានឡើងកាន់អំណាចបានមានដូចជា៖

### ១) ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០



យោធាខ្មែរក្រហមត្រៀមប្រយុទ្ធនៅសមរភូមិ

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាមានរបត់នយោបាយមួយយ៉ាងធំ ពីប្រទេសកាន់របបរាជានិយម មកជាប្រទេសប្រកាន់យករបបសាធារណរដ្ឋនិយម ។ នៅថ្ងៃនោះ ប្រទេសកម្ពុជាត្រូវបានដាក់ឲ្យស្ថិតក្នុងភាពអាសន្ន ហើយបានបោះឆ្នោតដកតំណែងសម្តេចព្រះ នរោត្តម សីហនុ ពីប្រមុខរដ្ឋ ។ ការធ្វើរដ្ឋប្រហារនេះ ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី លន់ នល់ និងព្រះអង្គម្ចាស់ សិរិមតៈ នៅក្នុងពេលដែលសម្តេចព្រះ នរោត្តម សីហនុ អវត្តមាននៅក្នុងប្រទេស ។ ក្រោយពីបានទទួលដំណឹងនេះហើយ សម្តេចព្រះ នរោត្តម សីហនុ បានចាកចេញពីសហភាពសូវៀតយាងទៅទីក្រុងប៉េកាំង ប្រទេសចិននៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧០ ។ ក្រោយពីមានការឧបត្ថម្ភពីប្រទេសចិន សម្តេចព្រះ នរោត្តម សីហនុ បានបង្កើត «រណសិរ្សរួបរួមជាតិកម្ពុជា» ដើម្បីប្រយុទ្ធតទល់នឹងរបបសាធារណរដ្ឋខ្មែរ ដោយសហការជាមួយកងកម្លាំងខ្មែរក្រហមនៅក្នុងប្រទេស ។ តាមរយៈរណសិរ្សនេះ ព្រះអង្គបានអំពាវនាវឲ្យអ្នកដែលគាំទ្រព្រះអង្គនៅក្នុងប្រទេសងើបឡើងបះបោរប្រឆាំងនឹងរបបលន់នល់ ។

ប្រជាជនក្នុងប្រទេសដែលមានចិត្តស្រលាញ់ព្រះអង្គ ក្រោយពីបានឮការអំពាវនាវនេះ បាននាំគ្នាចូលរួម ជាមួយរណសិរ្សរួបរួមជាតិកម្ពុជាក្នុងគោលបំណងយាងសម្តេចព្រះ នរោត្តម សីហនុ មកធ្វើជាប្រមុខរដ្ឋវិញ ។ ការអំពាវនាវរបស់

ព្រះអង្គធ្វើឲ្យយោធាខ្មែរក្រហមកើនចំនួនឡើងជាលំដាប់រៀងរាល់ថ្ងៃ ដោយអ្នកចូលរួមភាគច្រើនពុំបានស្គាល់អ្វីទៅថាជាចលនាខ្មែរក្រហម ។

ការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីសំណាក់ លន់ នល់ និងព្រះអង្គម្ចាស់ សិរិមតៈ បានធ្វើឲ្យចលនាខ្មែរក្រហមរីកចម្រើនយ៉ាងឆាប់រហ័ស ។

### ២) ជំនួយដល់ចលនាខ្មែរក្រហម

ប្រទេសចិនបានផ្តល់ឲ្យចលនាខ្មែរក្រហមនូវសម្ភារជំនួយយោធាចំនួន៤០០តោន និងរថយន្តធំចំនួន៥០គ្រឿង នឹងនៅឆ្នាំបន្តបន្ទាប់ទៀត ជំនួយផ្នែកយោធាជាច្រើនត្រូវបានផ្តល់ជូនចលនាខ្មែរក្រហម ។ កងទ័ពវៀតណាមខាងជើងក៏បានជួយដល់ចលនាខ្មែរក្រហមនូវជំនួយយោធា កងទ័ពប្រយុទ្ធ និងទីប្រឹក្សាយោធា ។ នៅពេលក្រោយៗនោះដែរ កងទ័ពវៀតណាមខាងជើងបាន ប្រើកងទ័ពប្រមាណប្រាំកងពលតូច ដោយមានការសហការជាមួយយោធាខ្មែរក្រហម ឆ្លៀតឱកាសវាយសម្រុកទៅលើកងទ័ព លន់ នល់ ដែលមិនបានត្រៀមទុកជាមុន បណ្តាលឲ្យមានមនុស្សស្លាប់ជាច្រើនពាន់អ្នក ។ ជំនួយសេដ្ឋកិច្ច និងសម្ភារយោធារបស់ចិននឹងជំនួយផ្នែកកងទ័ពប្រយុទ្ធរបស់វៀតណាម បានធ្វើឲ្យចលនាខ្មែរក្រហមមានកម្លាំងយ៉ាងខ្លាំងក្លាក្នុងការវាយសម្រុកទៅលើកងទ័ព លន់ នល់ និងមិនដល់មួយឆ្នាំផង កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាដណ្តើមបានតំបន់ភាគច្រើននៃប្រទេស ។

### ៣) ការទម្លាក់គ្រាប់បែកពីសំណាក់យន្តហោះកងទ័ពអាមេរិក

សហរដ្ឋអាមេរិក បានជ្រើសយកយុទ្ធសាស្ត្រទម្លាក់គ្រាប់បែកតាមផ្លូវអាកាសក្នុងគោលដៅជួយគាំទ្រកងទ័ពសាធារណរដ្ឋខ្មែរ ដើម្បីវាយកម្ទេចលើកុម្មុយនីស្តកម្ពុជា និងក្រោយមក ដើម្បីទប់ទល់ការវាយចូលទីក្រុងភ្នំពេញរបស់យោធាខ្មែរក្រហម និងគោលបំណងមួយទៀតគឺកម្ទេចកងទ័ពវៀតណាមខាងជើង ដែលកំពុងឈរជើងនៅលើទឹកដីកម្ពុជា ។ ក្នុងរយៈពេលតែមួយឆ្នាំក្រោយរដ្ឋប្រហារ មានការវាយប្រហារជាសម្ងាត់ជា៣.៦០០ដង ដោយគ្រាប់បែកចំនួនប្រហែលដប់ម៉ឺនតោន ត្រូវបានទម្លាក់លើទឹកដីកម្ពុជា ឯការបាត់បង់ជីវិតប្រជាជនស៊ីវិលមិនត្រូវបានបញ្ជាក់ឡើយ ។ រយៈពេលតែប្រាំខែប៉ុណ្ណោះ គ្រាប់បែកចំនួន២៥០.០០០តោន បានត្រូវបង្ហូរចាក់មកលើប្រទេសមួយ ដែលគ្មានធ្វើសង្គ្រាមជាមួយសហរដ្ឋអាមេរិក និងមកលើទឹកដីដែលគ្មានទាហានអាមេរិកាំងណាម្នាក់ស្ថិតនៅសោះ ។

តាមរយៈការទម្លាក់គ្រាប់បែកនេះធ្វើឲ្យប្រជាជនកម្ពុជាស្លាប់យ៉ាងច្រើន ចំណែកឯអ្នករួចពីសេចក្តីស្លាប់ភាគច្រើនបានរត់ចូលព្រៃម៉ាគី ដើម្បីចូលរួមជាមួយចលនាខ្មែរក្រហម ។ គោលបំណងគឺដើម្បីសងសឹកឲ្យបងប្អូន សាច់ញាតិ ឬឪពុកម្តាយ ដែលកងទ័ព លន់ នល់ និងកងទ័ពសហរដ្ឋអាមេរិកបានសម្លាប់ ។ ការទម្លាក់គ្រាប់បែកនេះ មិនបានធ្វើឲ្យចលនាខ្មែរក្រហមមានការចុះខ្សោយទេ ផ្ទុយទៅវិញ បានជំរុញឲ្យយោធាខ្មែរក្រហមពីចំនួនតិចទៅច្រើនទៅវិញក៏ព្រោះតែអ្នករងគ្រោះភាគច្រើនជាជនស៊ីវិល ។

### ៤) ស្ថានភាពផ្ទៃក្នុងរបស់របបសាធារណរដ្ឋខ្មែរ

ក្រោយពីទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតំណែងប្រមុខរដ្ឋមក លន់ នល់ និងព្រះអង្គម្ចាស់ សិរិមតៈ មិនបានប្រកាសដាក់ប្រទេសកម្ពុជាឲ្យទៅជាប្រទេសប្រកាន់យករបបសាធារណរដ្ឋភ្លាមទេ រហូតដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ ទើបប្រកាសដាក់ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបសាធារណរដ្ឋ ដោយមានឈ្មោះថា "សាធារណរដ្ឋខ្មែរ" ។ នោះក៏ព្រោះតែអ្នកដែលទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បានបែងចែកចេញជាពីរក្រុម ៖ គឺក្រុមអភិរក្ស និងក្រុមអ្នកសាធារណរដ្ឋនិយមរបស់លោកវរសេនីយ៍ឯក លន់ ណុន ប្អូនប្រុសរបស់ លន់ នល់ ដែលក្រោយមកក្លាយជាឧត្តមសេនីយ៍ ។

ក្រោយពីប្រកាសដាក់ប្រទេសកម្ពុជាជាប្រទេសប្រកាន់យករបបសាធារណរដ្ឋ ដែលមានសហរដ្ឋអាមេរិកជាខ្នងបង្អែករួចមក រដ្ឋាភិបាលរបស់ លន់ នល់ បានបន្តដឹកនាំឲ្យរីតតែមានសភាពខ្លាំងឡើង នោះគឺអំពើពុករលួយ តាមរយៈបុណ្យស័ក្តិ កិត្តិយស ការយកលុយទិញមុខដំណែង និងបក្ខពួកនិយម បានធ្វើឲ្យរបបនេះជួបនូវការប្រេះឆា និងបាត់បង់ការគាំទ្រពីសំណាក់ប្រជាជន ។ ចំណែកក្រុមយុវជនដែលជាអ្នកគាំទ្ររបបសាធារណរដ្ឋខ្មែរនៅដើមឆ្នាំ១៩៧១ ក៏បានបែងចែកជាពីរបក្សដែរ ក្រុមទាំងពីរជារឿយៗ មានទំនាស់នឹងគ្នាយ៉ាងស្រួចស្រាវ រហូតដល់មានការប្រយុទ្ធគ្នាចេញមុខតែម្តង ។ ដែលធ្វើឲ្យស្ថានភាពទីក្រុងភ្នំពេញ

ជួបតែភាពជ្រួលច្របល់អសន្តិសុខជារៀងរាល់ថ្ងៃ ។

ស្ថានភាពមួយទៀតដែលសំខាន់ជាងគេនោះគឺ អំពើពុករលួយក្នុងជួរកងទ័ព ដូចជាការស្រូកប្រាន់ ដើម្បីបានឡើងដំណែងធំ ឬប្រើលុយទិញតំណែងក្នុងជួរកងទ័ពតែម្តង ដែលខ្លួនមិនមែនជាកងទ័ព ។ ក្រោយពីដឹងច្បាស់ថា សហរដ្ឋអាមេរិកជួយឧបត្ថម្ភទាំងស្រុងលើវិស័យយោធា ឧត្តមសេនីយ៍ជាច្រើនបានមើលឃើញវិធីមួយចំនួនដែលអាចក្លាយជាសេដ្ឋីយ៉ាងឆាប់រហ័ស ។

ចំនួនទាហានខ្មោច ដើមឡើយ ចំនួនទាហានរបស់សេនាប្រមុខ លន់ នល់ មានតែ៣៥.០០០នាក់ប៉ុណ្ណោះ ប៉ុន្តែមិនដល់មួយឆ្នាំផង ចំនួនទាហានបានកើនឡើងដល់ជាងដប់ម៉ឺននាក់ ដែលភាគច្រើនគឺមានតែឈ្មោះប៉ុណ្ណោះ ។ អ្នកសារព័ត៌មានបរទេសបានដាក់ឈ្មោះថា “ទាហានខ្មោច” ។ នៅចុងឆ្នាំ១៩៧១ កងទ័ពខ្មោចមានចំនួនដល់ទៅ២២.០០០នាក់ ចំណែកឯកងទ័ពចំនួន៤៦.០០០នាក់ទៀត បានបាត់ខ្លួនមិនដឹងមូលហេតុ ។

ការលក់សម្ភារបរិក្ខារយោធា និងបរិក្ខារពេទ្យទៅឲ្យសត្រូវ សម្តេចព្រះ នរោត្តម សីហនុ ធ្លាប់និយាយប្រាប់ អ្នកសារព័ត៌មាននៅទីក្រុងប៉េកាំងថា “យើងខ្ញុំមានភ័ព្វសំណាងយ៉ាងខ្លាំងដោយទទួលបានអាវុធយុទ្ធភ័ណ្ឌពីសត្រូវ” ។

អំពើពុករលួយក្នុងជួររដ្ឋាភិបាលបានធ្វើឲ្យប្រជាជនស៊ីវិល និងយុវជន ដែលធ្លាប់គាំទ្ររបបសាធារណរដ្ឋខ្មែរ ប្រែជាអស់ជំនឿលើការដឹកនាំប្រទេសរបស់ លន់ នល់ ។ ចំណែកឯអំពើពុករលួយក្នុងជួរកងទ័ពវិញបានធ្វើឲ្យកងទ័ពអស់ជំនឿលើមេដឹកនាំរបស់ខ្លួន និងភាគច្រើនលែងប្រយុទ្ធតទល់ជាមួយខ្មែរក្រហម ។ កងទ័ពដែលមិនមានស្មារតីប្រយុទ្ធមានន័យថា របងការពារសត្រូវត្រូវបានដួលរលំ ដូច្នោះរដ្ឋាភិបាលដែលត្រូវការពារដោយរបងនោះក៏ត្រូវរលំដែរ ។

### ៥) រដ្ឋាភិបាលអាមេរិកផ្តាច់ជំនួយដល់សាធារណរដ្ឋខ្មែរ

នៅឆ្នាំ១៩៧៣-៧៤ ដោយអនុលោមតាមសន្ធិសញ្ញាទីក្រុងប៉ារីស រវាងសហរដ្ឋអាមេរិក និងវៀតណាមកុម្មុយនីស្តអាមេរិកបានរៀបចំខ្លួនឈប់ផ្តល់ជំនួយទៅឲ្យសាធារណរដ្ឋខ្មែរ ហើយថែមទាំងបង្ខំឲ្យ លន់ នល់ ធ្វើការចរចាជាមួយរដ្ឋាភិបាលរួបរួមជាតិដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ តែព្រះអង្គបដិសេធ ។ ទោះជាសហរដ្ឋអាមេរិកកំពុងរៀបចំបន្ថយ និងរៀបចំឈប់ផ្តល់ជំនួយដល់របបសាធារណរដ្ឋខ្មែរក៏ពិតមែន ប៉ុន្តែនៅដើមឆ្នាំ១៩៧៣ ពីខែមករា ដល់ខែសីហា សហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកយ៉ាងខ្លាំងទៅលើកងទ័ពកុម្មុយនីស្តនៅកម្ពុជា ។ ការទម្លាក់គ្រាប់បែកនេះបានបង្អាក់ដំណើរវាយយកទីក្រុងភ្នំពេញរបស់ខ្មែរក្រហម ។ ឯការផ្តល់ជំនួយផ្នែកយោធា និងសេដ្ឋកិច្ចរបស់អាមេរិកក៏បានធ្វើឲ្យរបបសាធារណរដ្ឋខ្មែរដែលភាគច្រើនរស់នៅទីក្រុងភ្នំពេញមានជីវិតរស់បានមួយរយៈពេលទៀត ពីព្រោះផ្លូវជាតិទាំង៦ចូលទីក្រុងភ្នំពេញត្រូវបានយោធាខ្មែរក្រហមកាត់ផ្តាច់ទាំងស្រុង ។

នៅឆ្នាំ១៩៧៤ កម្រិតជំនួយដែលត្រូវបានផ្តល់ដល់របបសាធារណរដ្ឋខ្មែរនៅត្រឹមតែ៣៧៧លានដុល្លារអាមេរិក ហើយរាល់ការចំណាយជាបុគ្គលនីមួយៗក៏ត្រូវរាប់បញ្ចូលក្នុងចំនួនសរុបនេះដែរ ។ ជាលទ្ធផល ស្បៀងឬជំនួយសេដ្ឋកិច្ចមិនអាចផ្តល់ឲ្យកម្ពុជាដោយមិនកាត់ចំណាយយោធាបានទេ ហើយបើផ្តល់ជំនួយយោធា ក៏ត្រូវតែកាត់ជំនួយស្បៀងឬសេដ្ឋកិច្ចដែរ ។ រហូតដល់ខែមីនា ឆ្នាំ១៩៧៥ សហរដ្ឋអាមេរិក បានកាត់រាល់ជំនួយសេដ្ឋកិច្ចនិងយោធាទាំងអស់ដល់ប្រទេសកម្ពុជា ។

សរុបមក ការរីកចម្រើន និងការឈានឡើងកាន់អំណាចរបស់ចលនាខ្មែរក្រហម មានមូលហេតុសំខាន់ៗមួយចំនួន ដូចបាន លើកយកមកពិភាក្សាខាងលើ ។ ចលនាខ្មែរក្រហមដែលពីដើមឡើយជាចលនាទ័ពព្រៃតូចតាចនិងលួចលាក់ ហើយថែមទាំងមិនមានមនុស្សស្គាល់ និងចូលចិត្តនោះ ស្រាប់តែក្នុងរយៈពេលមួយខ្លីបានកើនសមាជិកយ៉ាងឆាប់រហ័ស ។ មូលហេតុមួយ ក្នុងចំណោមមូលហេតុជាច្រើនទៀតដែលនាំឲ្យចលនាខ្មែរក្រហមអាចទទួលបានជ័យជម្នះលើសត្រូវនោះគឺ ការការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ដែលប្រជាជនខ្មែរគោរពស្រលាញ់ និងជឿជាក់លើការដឹកនាំប្រទេសរបស់ព្រះអង្គ ។ តែគួរឲ្យស្តាយ មេដឹកនាំខ្មែរក្រហមក្រោយពីទទួលបានអំណាចហើយ បានធ្វើឲ្យបាត់បង់ការគាំទ្រពីសំណាក់ប្រជាជនតាមរយៈទ្រឹស្តីកុម្មុយនីស្តឆ្វេងនិយមជ្រុលដឹកនាំប្រទេសបានតែជាងបីឆ្នាំ ក៏ត្រូវធ្លាក់ពីអំណាច ។

**ធី លីក្ស**

# ជំណើរជីវិតរបស់ ព្រំ គៀម ក្នុងរបបខ្មែរក្រហម

អ៊ឹ ព្រំ គៀម មានអាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិតាភោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ស្ថិតក្នុងសម្លៀកបំពាក់ទើបមកពីធ្វើចម្ការ ហើយអង្គុយនៅលើកៅអីវែងមួយនៅមុខផ្ទះ គៀម បាននិយាយរៀបរាប់ទាក់ទងទៅនឹងដំណើររឿងរ៉ាវជីវិតផ្ទាល់ខ្លួន ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមថា៖

សព្វថ្ងៃ គាត់ប្រកបមុខរបរលក់ដូរបន្តិចបន្តួច និងធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ គាត់មានកូនប្រាំនាក់ ស្រីពីរ ប្រុសបី ។ ប៉ុន្តែជាអកុសល នៅក្នុងរបប លន់ នល់ កូនស្រីច្បង និងកូន ស្រីទីបីរបស់គាត់បានស្លាប់ដោយសារជំងឺ ដោយបន្សល់ទុកចៅស្រីម្នាក់ឲ្យគាត់ចិញ្ចឹមរហូតដល់សព្វថ្ងៃ ។ សព្វថ្ងៃ កូនៗរបស់គាត់មានគ្រួសារ និងបែកទៅរស់នៅផ្ទះផ្សេងអស់ហើយ ។ គៀម បានត្អូញត្អែរថា ជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ពិតជាជួបការលំបាកណាស់ ព្រោះគាត់ត្រូវទទួលរ៉ាប់រងប្រកបរបរប្រចាំថ្ងៃ ដើម្បីចិញ្ចឹមប្តី ដែលមានវ័យចំណាស់ និងត្រូវចញ្ចឹមថែទាំចៅស្រីម្នាក់ដែលកំព្រាម្តាយតាំងពីតូច ។

គៀម បានរំឭកថា ដោយសារមានការទម្លាក់គ្រាប់របស់អាមេរិកនៅក្នុងរបប លន់ នល់ គាត់ និងស្វាមី ព្រមទាំងកូនៗទាំងពីរនាក់ទៀតបានរត់ភៀសខ្លួនពីគ្រាប់បែក ដោយចេញពីភូមិតាភោគក្នុង ទៅភូមិតាភោគក្រៅ ក្នុងស្រុកបល្ល័ង្ក ខេត្តកំពង់ធំ ។ គៀម បានបន្ថែមថា នៅតាមផ្លូវធ្វើដំណើរ មានសភាពលំបាកខ្លាំងព្រោះតែមានភ្លៀងផ្គរ និងរន្ទះ ។ បន្ទាប់ពីធ្វើដំណើរដោយថ្មើរជើងពេញមួយថ្ងៃ គៀម និងក្រុមគ្រួសារបានទៅដល់ភូមិតាភោគក្រៅ



ផ្ទះសម្បែង និងវត្តអារាម ដែលបានបំផ្លាញដោយការទម្លាក់គ្រាប់បែក និងគ្រាប់ផ្លោង

និងបានសុំអ្នកស្រុក អ្នកភូមិស្នាក់អាស្រ័យនៅខាងក្រោម ផ្ទះមួយរយៈ រហូតដល់គាត់ធ្វើខ្ទមសម្រាប់ក្រុមគ្រួសាររបស់គាត់បាន ។

បន្ទាប់ពីការទម្លាក់គ្រាប់បែកមានសភាពស្ងប់ស្ងាត់ គៀម និងក្រុមគ្រួសារបាននាំគ្នាវិលត្រឡប់ទៅស្រុកភូមិវិញ ។ រយៈពេលមួយឆ្នាំក្រោយមក ខ្មែរក្រហមបានចូលកាន់កាប់នៅក្នុងភូមិស្រុករបស់គាត់ ហើយគាត់ត្រូវបានគេចាត់តាំងឲ្យចូលទៅក្រុមប្រវាស់ដៃ ។ ចំណែកឯកូនៗរបស់គាត់ ត្រូវអង្គការចាត់ឲ្យទៅរើសអាចម៍គោជាមួយក្មេងៗដទៃទៀត ។ គៀម បានរំឭកថា នៅក្នុងក្រុមប្រវាស់ដៃ អង្គការតម្រូវឲ្យគាត់ដកស្ទូងពេញមួយថ្ងៃ ស្ទើរតែគ្មានពេលឈប់សម្រាក ។ គាត់បានឮអ្នកភូមិនិយាយតៗគ្នាថា ទិន្នផលស្រូវដែលប្រមូលបាន ត្រូវអង្គការដឹកទៅដាក់ក្នុងជង្រុកធំមួយ ហើយដឹកទៅឃ្លាំងនៅភ្នំពេញ បន្ទាប់មក ដឹកចេញទៅកំពង់ផែយ៉ាងប្រុងប្រយត្ន័បំផុត ។ ប៉ុន្តែគាត់មិនដឹងច្បាស់ពីគោលដៅថាដឹកចេញទៅកាន់ប្រទេសណាខ្លះនោះទេ ។

ក្រៅពីការងារដកស្ទូង គាត់ត្រូវបានអង្គការចាត់ឲ្យចូលទៅកងចល័តដើម្បីរែកដី ទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាក ។ គៀម បានដកដង្ហើមធំ រួចបន្តរៀបរាប់ពីការលំបាករបស់គាត់ថា គាត់ត្រូវបានអង្គការឲ្យលើកទំនប់១មករា ដែលស្ថិតនៅក្នុងខេត្តកំពង់ធំជាមួយនឹងកងចល័តផ្សេងៗទៀតដែលបាន កេណ្ឌមកពីគ្រប់ខណ្ឌនិងសង្កាត់ ។ គៀម ព្រមទាំងអ្នកភូមិត្រូវក្រោកពីយប់ និងត្រូវធ្វើដំណើរដោយ ថ្មើរជើងដើម្បីទៅរែកដីលើកទំនប់១មករា ។ ទំនប់នោះ មានចម្ងាយប្រហែលមួយគីឡូម៉ែត្រពីផ្ទះ ដែលគាត់ស្នាក់នៅ ។ គាត់បានបន្ថែមទៀតថា លក្ខខណ្ឌការងារនៅទំនប់ ១មករាគឺពិតជាអាក្រក់ណាស់ ហើយមានមនុស្សជាច្រើនត្រូវបានស្លាប់នៅក្នុងអំឡុងពេលលើកទំនប់នោះ ដោយសារតែការធ្វើការហួសកម្លាំង ការអត់អាហារ និងជំងឺ ។ អ្នកជំងឺដែលឈឺខ្លាំងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យប្រចាំតំបន់ដោយការមើលជំងឺ និងព្យាបាលដោយគ្រាន់តែជាការផ្តល់ថ្នាំអាចម៍ទន្សាយឲ្យផឹកប៉ុណ្ណោះ ។ នៅពេលដែលអ្នកជំងឺ មានសភាពធូរស្បើយ គឺត្រូវមកធ្វើការដូចដើមដោយមិនអនុញ្ញាតឲ្យឈប់សម្រាកទេសូម្បីតែថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យ ។ ដោយឡែក អ្នកមានវ័យចំណាស់ដែលមានកូនចៅនៅផ្ទះអាចសុំមេក្រុមមកស្នាក់នៅផ្ទះ បន្ទាប់ពីដល់ម៉ោងឈប់សម្រាក ប៉ុន្តែចំពោះកំលោះក្រមុំមិនអាចសុំបានទេ ។

គៀម បានបន្តទៀតថា របបអាហារនៅទីនោះគឺមានតែបបររាវៗពីរដងក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាចប៉ុណ្ណោះ ដូច្នេះហើយទើបធ្វើឲ្យរូបរាងកាយរបស់គាត់កាន់តែមានសភាពទ្រុឌទ្រោមពីមួយថ្ងៃទៅមួយថ្ងៃ ។ គាត់បានអះអាងថា ទំនប់១មករានេះ ចាប់ផ្តើមកសាងឡើងកាលពីដើមឆ្នាំ១៩៧៦ និងបញ្ចប់នៅឆ្នាំ១៩៧៩ ។

នៅពេលដែលវៀតណាមចូលមក នៅចុងឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមគ្រប់រូបបានបំផុសស្មារតីប្រជាជនថា វៀតណាមនឹងចូលមកស្រុកយើងដើម្បីធ្វើការសម្លាប់ប្រជាជននៅក្នុងប្រទេសយើង ។ ប្រជាជនមួយភាគធំដែលឮបែបនេះមានភាពភ័យខ្លាច ខ្លះបានរត់ពួន ខ្លះរត់ចូលព្រៃ ខ្លះប្តេជ្ញាចិត្តតស៊ូនឹងវៀតណាម ។ ប៉ុន្តែ បន្ទាប់ពីកងទ័ពវៀតណាមចូលមក ប្រជាជនឃើញថាសភាពការណ៍មិនដូចអ្វីដែលកម្មាភិបាលខ្មែរក្រហមបានប្រាប់ ទើបក្រុមគ្រួសារគាត់ ព្រមទាំងអ្នកស្រុកបាននាំគ្នាវិលត្រឡប់មកស្រុកកំណើត និងរស់នៅជួបជុំគ្រួសារវិញ ។ **ហួរ ហាច**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ការរើសអើងលើជនជាតិវៀតណាមនៅតែជាបញ្ហា ប្រឈមក្នុងសង្គមកម្ពុជា

ទោះបីអន្តជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលប្រជាជនកម្ពុជាទូទៅស្គាល់ថាតុលាការខ្មែរក្រហមកំពុងតែជំនុំជម្រះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍លើជនជាតិវៀតណាមនិងចាមយ៉ាងណាក៏ដោយ ក៏បញ្ហាជនជាតិវៀតណាមនៅតែជាប្រធានបទក្តៅនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។

ចាប់តាំងពីការបោះឆ្នោតជាតិអណត្តិទី១ រហូតមក ជនជាតិវៀតណាមតែងតែជាជនរងគ្រោះនៃការរើសអើងជាតិសាសន៍ ហើយអ្វីដែលលេចធ្លោនោះ គឺការបោះឆ្នោតជាតិអាណត្តិទី៥ និងចាប់ពីថ្ងៃបោះឆ្នោតរហូតមកដល់ពេលបច្ចុប្បន្ននេះ មេដឹកនាំបក្សនយោបាយ ប្រពន្ធ័ផ្សព្វផ្សាយ និងបណ្តាញសង្គមមួយចំនួនតែងតែយកបញ្ហាជនជាតិវៀតណាមនិងអន្តោប្រវេសន៍វៀតណាម ជាប្រធានបទសំខាន់មួយក្នុងយុទ្ធសាស្រ្តនយោបាយរបស់ខ្លួន ហើយបញ្ហានេះបានក្លាយទៅជាបំផុសឡើងវិញនូវគំនិតជាតិនិយមជ្រុលនៅក្នុងស្រទាបយុវជន បញ្ញវន្ត និងប្រជាជនប្រជាជនកម្ពុជាឲ្យខ្ជប់ខ្ជើមនិងរើសអើងប្រឆាំងនឹងជនជាតិវៀតណាមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ។ ជាក់ស្តែង អំឡុងពេលធ្វើបាតុកម្មកន្លងមករបស់គណបក្សសង្គ្រោះជាតិដើម្បីទាមទាររកយុត្តិធមជូនម្ចាស់ឆ្នោត ទាមទារឲ្យមានការបោះឆ្នោះឡើងវិញ និងបាតុកម្មរបស់កម្មកររោងចក្រកាត់ដេរ ដើម្បីទាមទារតម្លើងប្រាក់ឈ្នួលចំនួន១៦០ដុល្លា អំពើហិង្សាបានផ្ទុះឡើងនៅតាមផ្លូវវេងស្រេង រវាងកម្មករនិងអាជ្ញធររាជ រដ្ឋាភិបាលនោះ ទ្រព្យសម្បត្តិឯកជន និងហាងទំនិញរបស់ជនវៀតណាមមួយចំនួន



អ្នកទោសកុមារ ជាជនជាតិវៀតណាម នៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង

ត្រូវបានបំផ្លាញដោយបាតុករនិយមជ្រុលមួយក្រុម ។

បញ្ហារើសអើងទៅលើជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជាបានឡើងដល់កម្រិតខ្ពស់នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។ បន្ទាប់ពីលោកឧត្តមសេនីយ៍ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ របបសាធារណរដ្ឋខ្មែរបានបំផុសឲ្យប្រជាជនកម្ពុជា ជាពិសេសយុវជនមានគំនិតជាតិនិយមជ្រុលប្រឆាំងនឹងជនជាតិវៀតណាមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ។

ប្រជាជនបានធ្វើបាតុកម្ម ដោយបានស្រែកជ័យឃោសប្រឆាំងនឹងជនជាតិវៀតណាម ដូចជាពាក្យថាកាប់យួន និងធ្វើសកម្មភាពដុតបំផ្លាញហាងទំនិញ និងទ្រព្យសម្បត្តិរបស់ជនជាតិវៀតណាមជាដើម ។ ផ្ទាំងរូបភាពជាច្រើនដែលមាននិន្នាការប្រឆាំងនឹងជនជាតិវៀតណាម ត្រូវបានបិទតាមដើមឈើ និងតាមទីកន្លែងសាធារណៈនៅក្នុងទីក្រុង និងទីប្រជុំជននានានៅទូទាំងប្រទេស ។ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បានចេញច្បាប់បម្រាមគោចរ និងបានអនុញ្ញាតឲ្យជនជាតិវៀតណាមចេញពីលំនៅដ្ឋានដើម្បីប្រកបការងារផ្សេងៗតែក្នុងរយៈពេល៦ម៉ោងក្នុងមួយថ្ងៃ (នៅពេលថ្ងៃ) ។ រដ្ឋាភិបាលក៏បានចេញប័ណ្ណសម្គាល់ខ្លួនផ្សេងមួយសម្រាប់តែជនជាតិវៀតណាម ។ ជនជាតិវៀតណាមត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួនមកស្នាក់នៅក្នុងជំរំប្រមូលផ្តុំមួយជិតស្ពានមិត្តភាពកម្ពុជាជប៉ុន (ស្ពានជ្រោយចង្វារ) ក្នុងទីក្រុងភ្នំពេញមុនពេលដឹកតាមកប៉ាល់ឲ្យទៅរស់នៅក្នុងប្រទេសវៀតណាមខាងត្បូងជាមួយនឹងទ្រព្យសម្បត្តិបន្តិចបន្តួចដែលនៅជាប់នឹងខ្លួន ។ ចំពោះជនជាតិវៀតណាមរាប់ពាន់នាក់ផ្សេងទៀត ត្រូវបានសម្លាប់ដោយចោទថាជាវៀតកុង ឬក៏ចូលជាមួយវៀតកុង ។ សាកសពភាគច្រើនត្រូវបោះចូលទៅក្នុងទន្លេមេគង្គ ។ ចំណែកស្ត្រីវៀតណាមមួយចំនួនត្រូវបានចាប់រំលោភមុនពេលសម្លាប់ ។

បន្ទាប់ពីកងទ័ពវៀតកុងត្រូវដកចេញពីក្នុងទឹកដីរបស់កម្ពុជានៅឆ្នាំ១៩៧៣ ខ្មែរក្រហមក៏បានចាប់ផ្តើមសម្លាប់ជនជាតិវៀតណាម ជាពិសេសអ្នកដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាល ។ ផែនការកម្ចាត់ជនជាតិវៀតណាមបានលេចចេញជារូបរាងកាន់តែច្បាស់នៅពេលដែលខ្មែរក្រហមទទួលជ័យជន្នះលើរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាពិសេសបន្ទាប់ពីខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងចេញពីទីក្រុង និងទីប្រជុំជនឲ្យទៅរស់នៅតាមជនបទដើម្បីធ្វើស្រែចម្ការ ។ ខ្មែរក្រហមបានប្រកាសរកជនជាតិវៀតណាមដែលត្រូវជម្លៀសឲ្យទៅតាមសហករណ៍នីមួយៗ ដើម្បីដេញអ្នកទាំងនោះឲ្យទៅរស់នៅប្រទេសវៀតណាម ។ ជនជាតិវៀតណាមមួយចំនួនបានសម្រេចចិត្តលាក់បាំងប្រវត្តិរូបរបស់ខ្លួន និងបន្តរស់នៅក្នុងប្រទេសកម្ពុជា ។

ចំណែកជនជាតិវៀតណាមមួយចំនួនទៀត ដែលគ្រាន់តែជាប់ខ្សែស្រឡាយជាវៀតណាមតាំងជំនាន់ពីជីដូនជីតាមកមិនចេះនិយាយភាសាវៀតណាមជាមួយអាជ្ញាធរវៀតណាមនៅពេលដែលខ្មែរក្រហមបញ្ជូនឲ្យទៅដល់ច្រកព្រំដែនកម្ពុជាវៀតណាម ។ ដូច្នេះអ្នកទាំងនោះមិនត្រូវអនុញ្ញាតឲ្យឆ្លងព្រំដែនទៅរស់ក្នុងប្រទេសវៀតណាមទេ ។ ខ្មែរក្រហមក៏បានបញ្ជាឲ្យអ្នកទាំងនោះត្រឡប់មករស់នៅភូមិកំណើតក្នុងប្រទេសកម្ពុជាវិញ ។ ប៉ុន្តែជាអកុសលអ្នកទាំងនោះនិងជនជាតិវៀតណាមផ្សេងៗទៀតត្រូវបានសម្លាប់ស្ទើរតែទាំងអស់ ដោយខ្មែរក្រហមគ្រាន់តែចោទអ្នកទាំងនោះជាជនជាតិវៀតណាម បន្ទាប់ពីខ្មែរក្រហមធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ។

ពៅ ហុង គឺជាជនជាតិវៀតណាមដ៏កម្រម្នាក់ដែលបានរស់រានពីរបបខ្មែរក្រហម ។ ហុង មានឪពុកឈ្មោះ អៀង ពៅ ជាជនជាតិខ្មែរ និងម្តាយឈ្មោះ ម៉េង ស៊ីម ជាប់សែស្រឡាយវៀតណាម (ដោយមានជីតាទួតជាជនជាតិចិន និងជីដូនទួតជាជនជាតិវៀតណាម) ។ បងប្អូនបង្កើតនិងសាច់ញាតិខាងម្តាយរបស់ ពៅ ហុង ទាំងអស់ត្រូវខ្មែរក្រហមយកទៅសម្លាប់ក្រោមរូបភាពយកទៅរៀនសូត្រ ។ ហុង បានរួចផុតពីសេចក្តីស្លាប់ ដោយសារតែម្តាយបង្ខំឲ្យលួចរត់មកផ្ទះវិញដើម្បីមើលថែទាំជីដូនឪពុក ខណៈពេលដែលខ្មែរក្រហមចាប់យក ហុង, ម្តាយ និងបងប្អូនប្រុសស្រីរបស់ ហុង ទៅឃុំឃាំងនៅវត្តព្រែកគាំ ក្នុងឃុំព្រែកអន្ទះ ។

ពៅ ហុង បានរំឭកឡើងអំពីបទពិសោធជីវិតរបស់ខ្លួនថា

នៅចុងឆ្នាំ១៩៧៥ ប្រធានភូមិអន្លង់ស ឈ្មោះ តាមួន និង ស៊ិន បានដើរប្រកាសប្រាប់ជនជាតិវៀតណាម និងប្រជាជនដែលជាប់សែស្រឡាយវៀតណាមនៅក្នុងភូមិថា អង្គការត្រូវបញ្ជូនទៅប្រទេសវៀតណាមវិញ ។ កាលនោះ ក្រុមគ្រួសាររបស់ ហុង រួមមានក្រុមគ្រួសារខាងយាយទួត តាទួត ជីដូនជីតា ម្តាយធំ ឪពុកធំ ម្តាយមីង និងគ្រួសាររបស់ ហុង រួមជាមួយជនជាតិវៀតណាមនៅភូមិអន្លង់សជាច្រើនគ្រួសារទៀតបានធ្វើដំណើរតាមទូកចាកចេញពីភូមិអន្លង់សឆ្ពោះទៅកាន់ច្រកព្រំដែនកម្ពុជា-វៀតណាម ក្អមសំណ ស្ថិតនៅក្នុងស្រុកលើកដែក តំបន់២៥ ដោយមានកម្មាភិបាលខ្មែរក្រហមជាអ្នកនាំផ្លូវ ។ ច្រកព្រំដែនក្អមសំណ គឺជាច្រកមួយដែលភាគីខ្មែរក្រហមបញ្ជូនជនជាតិវៀតណាមទៅឲ្យភាគីវៀតណាម ។ បន្ទាប់ពីក្រុមគ្រួសាររបស់ ហុង បានមកដល់ក្អមសំណ និងស្នាក់នៅទីនោះប្រមាណ៥យប់ ទើបខាងភាគីវៀតណាមមកប្រាប់ថាប្រជាជនទាំងអស់ដែលសុទ្ធតែជាជនជាតិខ្មែរ ដូច្នេះខាងវៀតណាមមិនទទួលយកទេ ។ កម្មាភិបាលខ្មែរក្រហមដែលទទួលខុសត្រូវនៅក្អមសំណបានប្រាប់ប្រជាជនទាំងអស់ឲ្យវិលត្រឡប់មកភូមិកំណើតវិញ ។ ចំណែកក្រុមគ្រួសាររបស់ ហុង បានធ្វើដំណើរត្រឡប់មកភូមិអន្លង់សវិញ ។ នៅពេលមកដល់ភូមិអន្លង់ស គ្រួសាររបស់ ហុង ត្រូវរស់នៅ និងធ្វើស្រែចម្ការជាធម្មតាដូចប្រជាជនក្នុងភូមិ ។

នៅដើមឆ្នាំ១៩៧៧ កងឈ្លបឃុំព្រែកអន្ទះ ពីរបីនាក់បានមកហៅជីតាទួត និងយាយទួតរបស់ ហុង ទៅរៀនសូត្រ ហើយបានបាត់ខ្លួនជារៀងរហូត ។ ហុង បាននិយាយថា «ខ្ញុំមិនបានដឹងថាកងឈ្លប យកជីតាទួត និងយាយរបស់ខ្ញុំទៅសម្លាប់នៅទីណាទេ» ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ កងឈ្លបឃុំព្រែកអន្ទះ បានមកហៅម្តាយធំ ឪពុកធំ ម្តាយមីង និងឪពុកមារបស់ ហុង ទៅរៀនសូត្រទៀត ។ ប៉ុន្តែ កងឈ្លបមិនទាន់យកម្តាយរបស់ ហុង ទៅទេ ដោយសារគាត់ទើបឆ្លងទន្លេ ។ រយៈពេល១៥ថ្ងៃក្រោយ មកទើបកងឈ្លបយកម្តាយ និងបងប្អូនប្រុសស្រីរបស់ ហុង ប្រាំនាក់ទៅទៀត ។ ខណៈពេលនោះប្អូន របស់ ហុង ពីរនាក់បានគេចទៅពួននៅគុម្ពឫស្សី ដោយសារកងឈ្លបបានយកជីតាទួត យាយទួត និងសាច់ញាតិទៅអស់ហើយ គ្រួសាររបស់ ហុង បានពិភាក្សាគ្នាថា ប្រសិនបើកងឈ្លបមកយកទៀត ឲ្យយកតែម្តាយទៅចុះ ចំណែកបងប្អូនយើងមិនបាច់ទៅទេ យើងត្រូវតែរត់គេចទាំងអស់គ្នា ។

ប្រធានភូមិឈ្មោះ តាមួន មិនសុខចិត្តទេ នៅខណៈដែលកងឈ្លបមកយកគ្រួសាររបស់ ហុង ទៅរៀនសូត្រ តែមិនឃើញវត្តមានប្អូនៗរបស់ ហុង ពីរនាក់ទៀត ។ តាមួន បានតាមហៅប្អូនៗរបស់ ហុង ទាំងពីរនាក់នោះលុះត្រាតែបាន ។ ក្នុងថ្ងៃដែលប្រធានភូមិមកយកម្តាយរបស់ ហុង នោះគឺ ហុង មិនបាននៅផ្ទះទេ ។

ហុង ត្រូវបានគណៈកង ចាត់តាំងទៅមើលក្របីនៅឯវាលស្រែប្រាំង លុះពេលល្ងាចទើប ហុង ត្រឡប់មកផ្ទះវិញ ។ នៅខណៈពេលដែល ហុង កំពុងហូបបាយនៅរោងបាយសហករណ៍ភូមិអន្លង់ស តាមួន បានមកហៅ និងដឹកដៃ ហុង ត្រឡប់មកផ្ទះវិញ ។ តាមួន បាននិយាយថា «ឯងត្រូវទៅជាមួយម៉ែឯង» ។ ហុង មិនដឹងថា តាមួន មានការអ្វីទេ ។ ព្រលប់ៗ ទៅហើយ កងឈ្លបពីរនាក់បានយកកងមកខុប ហុង និងប្អូនៗ២នាក់ទៀតចេញពីភូមិអន្លង់សឆ្ពោះទៅវត្តព្រែកតាំ ដែលស្ថិតនៅក្នុងឃុំព្រែកអន្ទះនេះដែរ ។ វត្តព្រែកតាំ គឺជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។

ម្តាយរបស់ ហុង និងជនជាតិវៀតណាមដទៃទៀត ត្រូវខ្មែរក្រហមយកទៅដាក់ឃុំឃាំងនៅទីនោះ ។ ម្តាយរបស់ ហុង បាននិយាយប្រាប់ ហុង ថា «គាត់នឹកអាណិតឪពុករបស់ ហុង ណាស់ ព្រោះឪពុករបស់ ហុង មានជំងឺធំពោះ» ។ ឪពុករបស់ ហុង មានជំងឺនេះតាំងពីពេលដែលគណៈឃុំព្រែកអន្ទះ ឈ្មោះ យស ប្រើគាត់ឲ្យទៅដឹកព្រែកអន្លង់សម្ទេះ ។ ដោយសារតែគាត់ធ្វើការធ្ងន់ហួសកម្លាំង ទើបបណ្តាលឲ្យគាត់កើតជំងឺនេះ ។ ជារៀងរាល់យប់គាត់នោមប្រហែលមួយបំពង់ទឹកត្នោតដែលធ្វើអំពីស័ង្កសី មានចំណុះពីរលីត្រ ។ គាត់ត្រូវសម្រាន្តតែលើផ្ទះ ទៅណាមកណាមិនរួចទេ ។ ម្តាយរបស់ ហុង បានខ្សឹបប្រាប់ ហុង ថា កូនឯងទៅផ្ទះមើលថែទឹកក្តៅទឹកត្រជាក់ឪពុកឯងវិញចុះ ។

មនុស្សដែលខ្មែរក្រហមយកមកដាក់នៅវត្តព្រែកតាំត្រូវអត់អាហារពេញមួយថ្ងៃរហូតដល់ម៉ោងប្រមាណ១០យប់ទើបសន្តិសុខហៅឲ្យទៅហូបបបរ ។ ឆ្លៀតពេលនោះ ហុង លួចចុះតាមជណ្តើរសាលាឆាន់មកខាងក្រោយវត្តដែលសុទ្ធតែផ្សូរខ្មោច ។ ហុង ខ្លាចខ្លាំងណាស់ ប៉ុន្តែខំកាត់ចិត្តដើរកាត់ព្រៃល្បាស់ កាត់វាល

ឆ្លងទឹក និងវង្វេងផ្លូវ រហូតដល់ម៉ោង៣ទៀបភ្លឺទើបមកដល់ផ្ទះ ។

ពេល ហុង មកដល់ផ្ទះហើយប្រធានភូមិ និងកងឈ្លបមកតាមចាប់ទៀត ។ ហុង គេចមកស្នាក់នៅផ្ទះអ៊ំស្រីដែលប្ដីរបស់គាត់ត្រូវជាបងបង្កើតរបស់ម្ដាយ ហុង ។ អ៊ំស្រី របស់ ហុង មានកូនប្រុសតែម្នាក់ ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ កងឈ្លបមកយកប្ដី និងកូនប្រុសរបស់គាត់ទៅរៀនសូត្របាត់រហូតដែរ ។ ហុង បានគេចទៅនៅជាមួយគាត់ ប៉ុន្ដែក្រោយមកប្រធានភូមិឈ្មោះ តាមួនតាមរក ហុង ឲ្យខាងតែបាននោះ ហុង បានគេចខ្លួនទៅនៅផ្ទះម្ដាយធំម្នាក់ទៀតនៅភូមិកំពង់ឫស្សី ឃុំកំពង់ឫស្សី ក្នុងស្រុកជាមួយគ្នាដែរ ។ ហុង រស់នៅទីនោះមិនបានប៉ុន្មានផង កងឈ្លបនៅទីនោះតាមចាប់ ហុង ទៀត ។ ម្ដាយធំរបស់ ហុង ក៏ប្រាប់ ហុង ឲ្យត្រឡប់មកផ្ទះវិញ ។ ហុង ក៏ចាកចេញពីផ្ទះអ៊ំទៅរស់នៅ និងជួយរកខុសឲ្យក្រុមប្រជាជនដែលរម្ងាស់ស្ករត្នោត ។ ប្រជាជនដែលរម្ងាស់ស្ករត្នោតបានជួយលាក់ ហុង ឲ្យរួចពីការតាមចាប់របស់កងឈ្លប ។

នៅឆ្នាំ១៩៧៨ មានព្រឹត្តិការណ៍មួយកើតឡើង អង្គការប្រកាសថា សោ ភឹម ក្បត់ ។ នៅភូមិភាគបូព៌ាមានការច្របូកច្របល់ ។ អង្គការបើកទូលាយ គឺយើងអាចផ្លាសទីលំនៅបានហើយក៏ជាសំណាងល្អដែរ ឪពុករបស់ ហុង បានធូរស្បើយពីជំងឺនិងអាចដើរបាន ។ ទាំងពីរនាក់ឪពុក និងកូនបានវេចបង្វេចកៀសខ្លួនមកនៅជាមួយអ៊ំប្រុសខាងឪពុកនៅឃុំស្វាយអន្ទរ ។ ហុង និងឪពុកបានរស់នៅភូមិស្វាយអន្ទររហូតដល់វៀតណាមចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ។

ទោះបីជា ហុង មានភ័ព្វវាសនាបានរួចផុតពីសេចក្ដីស្លាប់ក៏ដោយ ក៏សេចក្ដីទុក្ខសោក និងសេចក្ដីឈឺចាប់នៅតែញាំញីក្នុងចិត្តរបស់គាត់រហូតមកដល់សព្វថ្ងៃ ។ នៅពេលមានពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ វៀតណាម និងពេលភ្ជុំបិណ្ឌម្ដងៗ ហុង មានអារម្មណ៍ឯកោ និងនៅតែនឹកឃើញជានិច្ចនូវសម្ដីចុងក្រោយរបស់ម្ដាយគាត់ថា «បើទឹកដោះម្ដាយថ្ងៃគង់តែបានជួបកូនវិញ» ។

នៅទីបញ្ចប់ ហុង មិនបានជួបម្ដាយរបស់ខ្លួនជារៀងរហូត ។ ម្ដាយ បងប្អូន និងសាច់ញាតិរបស់ ហុង ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយមូលហេតុក្រុមគ្រួសាររបស់គាត់ជាប់ពូជពង្សជាវៀតណាម ។

ពៅ ហុង បានសំណូមពរថា សូមឲ្យអ្នកដឹកនាំប្រទេសជំនាន់ក្រោយ កុំឲ្យប្រកាន់ពូជសាសន៍បានជាគ្នារស់នៅទីនេះយូរលង់តាំងពីដូនតាមកហើយ សូមឲ្យគ្នារស់បានសុខសាន្តដូចប្រជាជនដទៃទៀតនៅទូទាំងប្រទេសផង ។ **ឡុង ដានី**



ជនជាតិជាតិវៀតណាមដែលត្រូវបានរៀបចំជម្លៀសទៅស្រុកកំណើតរបស់ខ្លួនវិញ នៅក្នុងសម័យ លន់ នល់

# ពិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័











# យព្រះមុនីវង្ស ខេត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤











# ការរៀបចំសំណង ការប្រឈមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

*(តពីលេខមុន)*

សំណើទាមទារឲ្យមានថវិការបស់អង្គជំនុំជម្រះតុលាការកំពូល កើតចេញពីការអនុវត្តរបស់អន្តរជាតិ ។ ការខូចខាតនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប ត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានស្មើគ្នា ។ កត្តាដែលកំណត់លើការផ្តល់សំណង គឺផ្អែកលើការបង្កហេតុដល់ជនរងគ្រោះ, ភាពធ្ងន់ធ្ងរនៃការរំលោភបំពាន, ការអនុវត្តរបស់រដ្ឋ, និងអ្នកដាក់ពាក្យស្នើសុំ និងភាពត្រឹមត្រូវនៃការទាមទាររបស់ជនរងគ្រោះ ។ សមត្ថភាពផ្នែកហិរញ្ញវត្ថុរបស់រដ្ឋមិនមែនជាកត្តាកំណត់នោះឡើយ ។ ស្រដៀងគ្នានេះដែរ នៅក្នុងតុលាការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស ការផ្តល់សំណងត្រូវផ្អែកលើគោលការណ៍សមធម៌ ។ ក្នុងការអនុវត្តគោលការណ៍សមធម៌ក្នុងការផ្តល់សំណង ឬគណនាសំណងសម្រាប់ជនរងគ្រោះ តុលាការបានវាយតម្លៃកត្តាផ្សេងៗមួយចំនួន រួមមានតួនាទីផ្នែកសេដ្ឋកិច្ចនិងសង្គមរបស់អ្នកទទួលបានផលប្រយោជន៍ និងការរងទុក្ខដែលជនរងគ្រោះទទួលរង ។ សមត្ថភាពផ្នែកហិរញ្ញវត្ថុរបស់រដ្ឋមិនមែនជាកត្តាកំណត់នោះឡើយ ។ ការអនុវត្តរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្សមានលក្ខណៈស្មើគ្នា ហើយមិនធ្វើឲ្យប្រឡូកប្រឡល់ដល់សិទ្ធិក្នុងការទទួលបានសំណងមួយចំនួនតាមផ្លូវច្បាប់របស់អ្នកដាក់ពាក្យស្នើសុំ ដែលចុងចោទមានសមត្ថភាពផ្តល់សំណង ។ ម្យ៉ាងវិញទៀត តុលាការពីរ



ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានញែកដោយឡែក រវាងសិទ្ធិគាំពារផ្លូវច្បាប់ និងសមត្ថភាពក្នុងការអនុវត្តសិទ្ធិនោះ ។

ឧទាហរណ៍ ក្នុងសំណុំរឿង រាហ្សាម៉ាគូបា អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដា បានផ្តល់សំណងថ្មីបើការពិតដែលថាការិយាល័យរដ្ឋបាល មិនមានថវិកាដើម្បីផ្តល់សំណងនោះទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដា បានលើកឡើងថា បញ្ហាថវិកា មិនអាចជ្រៀតជ្រែកនឹងអំណាចរបស់តុលាការ ក្នុងការផ្តល់សំណងផ្នែកហិរញ្ញវត្ថុ ជាផ្នែកមួយនៃដំណោះស្រាយដ៏មានប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សនោះទេ ។ អង្គជំនុំជម្រះដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានយល់ស្របនោះបានថ្លែងថា “សំណួរជាច្រើនដែលជាប់ទាក់ទងទៅនឹងយន្តការក្នុងការចេញសេចក្តីសម្រេចផ្តល់សំណង ដូចជាបញ្ហាថវិកា ឬអង្គភាពសម្រាប់ទាមទារសំណង បានបង្កើតការពិចារណាផ្នែកច្បាប់បន្ថែម ដែលមិនអាចរារាំងដល់ការផ្តល់សំណងផ្នែកហិរញ្ញវត្ថុ នៅពេលដែលវាទំនងជាដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ចំពោះការរំលោភសិទ្ធិមនុស្ស ។ ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ភាពខុសប្លែកគ្នាកើតឡើងតាមរយៈការពិចារណាទាក់ទងទៅនឹងការចេញសេចក្តីសម្រេច រួមមានបញ្ហាផ្នែកថវិកា និងសេចក្តីសម្រេចទាក់ទងនឹងថាតើអ្នកដាក់ពាក្យស្នើសុំមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការទទួលបានសំណង ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ ប្រទេសរ៉្វាន់ដា បានសន្និដ្ឋានថា សេចក្តីសម្រេចពីរ ត្រូវតែធ្វើឡើងដោយឡែក ។

នៅក្នុងសំណុំរឿងហ្សាម៉ាគូបា តុលាការបានអនុវត្តស្របតាមប្រព័ន្ធច្បាប់ក្នុងស្រុក ដែលកង្វះផ្នែកធនធានថវិកា មិនអាចត្រូវបានប្រើប្រាស់ដើម្បីទាញហេតុផលមិនព្រមផ្តល់សំណងនោះឡើយ ។ តាមក្របខណ្ឌទំនៀមទម្លាប់ដំណោះស្រាយ សេចក្តីសម្រេចផ្នែកថវិកា មិនមែនជាកត្តាដែលត្រូវបានប្រើប្រាស់ដោយតុលាការក្នុងការកំណត់អំពីការខូចខាត ។ ការខូចខាតត្រូវបានវាយតម្លៃដោយផ្អែកលើផលប៉ះពាល់របស់ដើមបណ្តឹង ។ ការកំណត់អំពីសិទ្ធិតាមផ្លូវច្បាប់របស់ដើមបណ្តឹង ក្នុងការទទួលបានដំណោះស្រាយផ្នែកថវិកាពីជនជាប់ចោទ ឬប្រភពហិរញ្ញវត្ថុរបស់ស្ថាប័ន ដូចជាអង្គភាពគាំពារជនរងគ្រោះ ឬមូលនិធិសំណងជនរងគ្រោះ ដែលមិនមានលក្ខណៈត្រឹមត្រូវ យុត្តិធម៌ និងស្មើភាព ។ ទន្ទឹម ពេលដែលវាជាការពិតដែលចុងចោទមួយចំនួន គឺជាភ័ស្តុតាងវិនិច្ឆ័យ ប្រការនេះមិនមានន័យថាតុលាការ មិនបានចេញសេចក្តីសម្រេចលើសំណងប្រឆាំងរូបគាត់ ដែលសំណងទាំងនេះមិនអាចត្រូវបានបង្គាប់ ។ សមត្ថភាពរបស់តុលាការ នឹងកំណត់ថាតើសំណងត្រឹមត្រូវគួរតែជាអ្វី ។ បន្ទាប់មក វាជាកាតព្វកិច្ចរបស់រដ្ឋដើម្បីជំរុញឲ្យមានសំណង ។

ជាការពិតណាស់ សំណងលើឧក្រិដ្ឋកម្មសង្គ្រាមនឹងកើតចេញពីក្របខណ្ឌនៃសំណងប្រពៃណី ។ សំណងសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម ជារឿយៗ នឹងរាប់បញ្ចូលចំនួនជនរងគ្រោះ, ទំហំនៃការខូចខាត និងចំនួនលុយក្រៅពីសមត្ថភាពរបស់ចុងចោទដែលអាចផ្តល់បាន ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតមូលនិធិសំណងជនរងគ្រោះ ដើម្បីដាក់បញ្ចូលទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និងធនធានដទៃដើម្បីផ្តល់ថវិកាដល់ផែនការសំណង ។ ដោយអនុលោមតាមមាត្រា៧៥(២) របស់លក្ខន្តិកៈទីក្រុងរ៉ូម តុលាការព្រហ្មទណ្ឌអន្តរជាតិអាចបង្គាប់ឲ្យផ្តល់សំណងតាមរយៈមូលនិធិសំណងជនរងគ្រោះ ជាជាងតាមរយៈជនជាប់ចោទ ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវតែប្រយ័ត្នប្រយែងក្នុងការចេញសេចក្តីសម្រេចផ្តល់សំណងប្រឆាំងនឹងមូលនិធិ សំណងជនរងគ្រោះ ដែលជាអង្គភាពឯករាជ្យ មិនទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់ឡូបានហ្គា ។ ទន្ទឹមពេលដែលវាមិនមែនជាការត្រឹមត្រូវក្នុងការកំណត់សិទ្ធិផ្លូវច្បាប់របស់ជនរងគ្រោះ ក្នុងការទទួលបានសំណងពីជនជាប់ចោទ និងមូលនិធិសំណងជនរងគ្រោះ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចចេញសេចក្តីសម្រេចលើសំណងផ្លូវច្បាប់មកលើមូលនិធិសំណងជនរងគ្រោះនោះទេ ។ ចំពោះគោលការណ៍ក្នុងការផ្តល់សំណងនៅក្នុងសេចក្តីសម្រេចរបស់ ឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិបានព្យាយាមធ្វើឲ្យមានតុល្យភាពរវាងការគោរពសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានសំណងចំពោះការខូចខាត និងការទទួលស្គាល់ដែលថាមូលនិធិសំណងជនរងគ្រោះនឹងដំណើរការជាមួយនឹងធនធានដែលបានកំណត់ ។ វិធីសាស្ត្រ

ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រើប្រាស់ គឺមានភាពបត់បែនជាងវិធីសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលប្រើក្នុងសំណុំរឿង០០១ ហើយកាន់តែមានភាពស្មើគ្នាជាង ។

ចំពោះគោលការណ៍ក្នុងការទទួលសំណង នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងសំណុំរឿង ឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិបានសរសេរថា "សំណងត្រូវបានអនុវត្តដោយរបៀបមួយបើកចំហ ដែលអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះយល់ស្របទៅនឹងដំណោះស្រាយដ៏ទូលំទូលាយសម្រាប់ ការរំលោភបំពានសិទ្ធិរបស់ជនរងគ្រោះ និងមធ្យោបាយក្នុងការអនុវត្តការផ្តល់សំណង ។ វិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនមានកាតព្វកិច្ចក្នុងការធ្វើសេចក្តីសម្រេចលើការកំណត់ថវិកា ឬ ថវិកាដែលកំណត់សម្រាប់ផ្តល់ជាសំណង ។ ផ្ទុយទៅវិញ វិធានការផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ជាក់ថា សំណងគួរតែត្រូវបានវាយតម្លៃដោយពិចារណាអំពីវិសាលភាពនៃការខូចខាត ការបាត់បង់, និងការបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចតែងតាំងអ្នកជំនាញ ដើម្បីកំណត់វិសាលភាពការខូចខាត, ការបាត់បង់, និងការគ្រោះថ្នាក់ដល់ជនរងគ្រោះ ហើយដើម្បីលើកឡើងអំពីជម្រើសផ្សេងៗទាក់ទងនឹងប្រភេទ ឬគំរូនៃសំណងដែលត្រឹមត្រូវ ។ នៅក្នុងសំណុំរឿង ឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិបាននិយាយថា សំណងគួរតែសមាមាត្រទៅនឹង ការខូចខាត, គ្រោះថ្នាក់, ការខាតបង់តាមការលើកឡើងរបស់តុលាការ ។ មធ្យោបាយនោះ នឹងផ្អែកលើបរិបទនៃសំណុំរឿងនេះ និងស្ថានភាពរបស់ជនរងគ្រោះ ហើយមធ្យោបាយនោះ គួរតែស្របជាមួយនឹងគោលបំណងនៃការផ្តល់សំណង ។ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានដាក់បញ្ចូលថវិកាបស់មូលនិធិសំណងជនរងគ្រោះ ឬជនជាប់ចោទនៅក្នុងការគណនាអំពីចំនួននៃសំណង ប៉ុន្តែផ្ទុយទៅវិញបានផ្តោតលើតែវិសាលភាពនៃការប៉ះពាល់ដល់ជនរងគ្រោះ ។

ទោះបីជាយ៉ាងណាក៏ដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចពិចារណាអំពីប្រាក់សំណង នៅពេលដែលខ្លួនសម្រេចចិត្តអំពីសំណងនោះ ឧទាហរណ៍ជាសំណងបុគ្គល ឬសមូហភាព ។ ដោយអនុលោមតាមវិធានផ្ទៃក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចផ្តល់សំណងសមូហភាព ដែលខ្លួនអាចចាត់ទុកថាជាសំណងសមស្រប ។ ជាងនេះទៅទៀត តុលាការអាចបង្គាប់ជនជាប់ចោទឲ្យផ្តល់សំណង តាមរយៈមូលនិធិសំណងជនរងគ្រោះ ដែលចំនួនជនរងគ្រោះ, វិសាលភាព, និងគំរូនៃការផ្តល់សំណង បានធ្វើឲ្យសំណងសមូហភាពក្លាយជាការសមស្រប ។ ម្យ៉ាងវិញទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិ បានយល់ឃើញថាមិនមានប្រាក់សំណងគ្រប់គ្រាន់សម្រាប់សំណងបុគ្គលឡើយ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចចេញសេចក្តីបង្គាប់សំណងសមូហភាពសម្រាប់ជនរងគ្រោះភាគច្រើន ។

ចេតនារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងការផ្តល់ប្រាក់សំណងជាសំណងសមូហភាពសម្រាប់បុគ្គលត្រូវបានកំណត់ជាជាងសំណើទាមទារប្រកបដោយប្រសិទ្ធភាពនៅក្នុងសំណុំរឿង០០១ ដែលបង្កើតឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ចំពោះសំណុំរឿងឡូបានហ្គា នៅពេលដែលតុលាការរៀបចំគោលការណ៍ស្តីពីប្រភេទនៃសំណងខុសៗគ្នា ដែលផ្តល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិរួមមានការប្រគល់ឲ្យវិញ, សំណង, និងការស្តារសម្បទា ។ តុលាការបាននិយាយអំពីការដែលអាចមានប្រាក់សំណង ។ តុលាការបានកត់សំគាល់ថា កត្តាពគួរតែត្រូវបានពិចារណា នៅពេលដែលកំណត់ថា តើសំណងគួរតែត្រូវបានផ្តល់ ប្រសិនបើមានប្រាក់សំណង ។ ការពិចារណាអំពីប្រាក់សំណងបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងការវាយតម្លៃថាតើគួរតែផ្តល់សំណងបុគ្គលឬយ៉ាងណា ឬនៅពេល ដែលវាយតម្លៃថាតើគួរតែផ្តល់សំណងនោះ ។ ទាំងនេះមានន័យថា ការដែលអាចទទួលបានប្រាក់សំណង មិនមែនជាសេចក្តីសម្រេចនៅពេលដែលកំណត់អំពីខ្លឹមសារនៃសំណងសមូហភាពឡើយ ។ នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់សំណងសមូហភាព ជាជាងសំណងបុគ្គលដោយពិចារណាអំពីការទទួលបានប្រាក់សំណង នៅពេលដែលពិចារណាថាតើសំណងមិនមានលក្ខណៈស្របទៅនឹងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

នៅក្នុងសំណុំរឿងឡូបានហ្គា តុលាការបានគាំទ្រឲ្យមាននីតិវិធីសមូហភាពក្នុងការទទួលបានសំណង ។ ឡូបានហ្គា គឺជាមនុស្សក្រីក្រដូចជា ឌុច ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានមើលឃើញ

ភាពក្រីក្ររបស់ឡូបានហ្គា ថាជារបាំងក្នុងការចេញសេចក្ដីសម្រេចផ្ដល់សំណងប្រឆាំងរូបគាត់ ដូចគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចចិត្តថា ឡូបានហ្គា មិនអាចផ្ដល់សំណងជាថវិកាបាននោះទេ ។ ភាគីជាច្រើនដែលបានដាក់ពាក្យបណ្ដឹងនៅក្នុងសំណុំរឿងនោះមិនបានយល់ស្របជាមួយនឹងតុលាការនោះឡើយ ។ មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកស្វែងរកយុត្តិធម៌សម័យអន្តរកាល បានកត់សម្គាល់ថា ការបង្គាប់សំណងប្រឆាំង ឡូបានហ្គា នឹងជះឥទ្ធិពលយ៉ាងសំខាន់ ទោះបីជាសំណងទំនងជានឹងមិនត្រូវបានបង្គាប់ ។ ព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះមានសិទ្ធិក្នុងការបង្គាប់ឲ្យឡូបានហ្គាផ្ដល់សំណង ដោយសារមិនមានការរារាំងក្នុងការបង្គាប់ឲ្យផ្ដល់សំណងប្រឆាំងទៅនឹងបុគ្គលក្រីក្រ ។ ព្រះរាជអាជ្ញា បានកត់សម្គាល់ថា ការចេញសេចក្ដីសម្រេចបង្គាប់ សំណងប្រហែលជាលើកឡើងនូវ ការរំពឹងទុករបស់ជនរងគ្រោះ ប៉ុន្តែខ្លួនបានកត់សម្គាល់ថា តុលាការគួរតែដាក់បញ្ហាទ្រព្យសម្បត្តិលុយកាក់របស់ ឡូបានហ្គា ឲ្យស្ថិតក្រោមការឃ្លាំមើលនៅក្នុងសំណុំរឿងដែលបញ្ហានោះជំរុញឲ្យមានការផ្ដល់សំណងនាពេលក្រោយ ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចថា សំណងនៅក្នុងសំណុំរឿង ឡូបានហ្គា នឹងទាញយកប្រភពមូលនិធិសំណង ជាជាងប្រាក់សន្សំរបស់ជនជាប់ចោទ ។

ទន្ទឹមពេលដែលតុលាការព្រហ្មទណ្ឌអន្តរជាតិ មានការប្រយ័ត្នប្រយែងចំពោះពាក្យសុំដីរបស់ខ្លួនទាក់ទងនឹងលក្ខណៈនៃសំណងដែលត្រូវអនុវត្តតាមរយៈមូលនិធិសំណង តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានការដាក់កំហិតដូចគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការបកស្រាយអំពីទំហំសំណងតាមរយៈមូលនិធិសំណងជនរងគ្រោះនោះទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានថ្លែងថា មូលនិធិសំណងជនរងគ្រោះ ត្រូវតែបន្ថែមថវិកាសម្រាប់សំណង ទោះបីជាមានធនធានតាមការកំណត់ក៏ដោយ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ជំនួយ ។ ម្យ៉ាងវិញទៀត មូលនិធិសំណងជនរងគ្រោះ ត្រូវតែផ្ដល់ប្រាក់សំណងតាមការបង្គាប់របស់តុលាការ ។ ប៉ុន្តែតុលាការមិនបានកំណត់ចំនួនដែលមូលនិធិសំណងបានលើកឡើង ។ ដូចគ្នាទៅនឹងអង្គភាពគាំពារជនរងគ្រោះ មូលនិធិសំណង អាចធ្វើគម្រោងជំនួយក្រៅពីសំណងដែល បង្គាប់ដោយតុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងសំណុំរឿងឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិ បានកត់សម្គាល់ថា ការទទួលខុសត្រូវដ៏សំខាន់របស់មូលនិធិសំណង គឺត្រូវធានាថាសំណង ដែលបង្គាប់ដោយតុលាការមានថវិកាគ្រប់គ្រាន់ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចទាញយកធនធានហិរញ្ញវត្ថុអំពីមូលនិធិសំណងដើម្បីអនុវត្តការផ្ដល់សំណង ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបន្តកត់សម្គាល់ថា នៅពេលតុលាការបានបង្គាប់សំណងប្រឆាំងទៅនឹងជនជាប់ចោទក្រីក្រ តុលាការអាចទាញយកប្រភពផ្សេងដែលមូលនិធិសំណងបានខិតខំប្រឹងប្រែងក្នុងការបង្កើត ។ ម្យ៉ាងវិញទៀត តុលាការអាចចេញសេចក្ដីបង្គាប់លើមូលនិធិសំណងដើម្បីប្រើប្រាស់ធនធានរបស់ខ្លួន ក្នុងការអនុវត្តសំណង ដូចដែលបានបង្ហាញនៅក្នុងសេចក្ដីសម្រេចចុងក្រោយ ។ ប៉ុន្តែមិនអាចដាក់ទណ្ឌកម្មមូលនិធិសំណងពីបទខកខានលើក ឡើងពីចំនួនថវិកា ។

មិនដូចគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានកំណត់ពីសំណងជាថវិកាដែលមាននៅក្នុងមូលនិធិសំណង ។ ផ្ទុយទៅវិញ តុលាការ និងមូលនិធិសំណងបានប្រមើលមើលនូវការរៀអង្គាសបន្ថែម ដែលជាដំណាក់កាលចុងក្រោយក្នុងដំណើរការសំណង បន្ទាប់ពីគោលការណ៍ត្រូវបានដាក់ចេញ ការប្រឹក្សាយោបល់ជាមួយជនរងគ្រោះត្រូវបានបញ្ចប់ ហើយតុលាការបានយល់ស្របចំពោះផែនការសំណងចុងក្រោយរបស់មូលនិធិសំណង ។ មូលនិធិសំណងបានកត់សម្គាល់ថាខ្លួននឹងចាប់ផ្ដើមការរៃអង្គាសថវិកា នៅពេលដែលអង្គជំនុំជម្រះបានសម្រេចចិត្តលើលក្ខខណ្ឌកំណត់នៃសំណងហើយអង្គជំនុំជម្រះបានយល់ព្រមលើវិធិសាស្ត្រក្នុងការអនុវត្ត ។ មូលនិធិសំណងបានកត់សម្គាល់ថា សភា (Assembly of State Parties) ដែលត្រួតពិនិត្យមើលមូលនិធិសំណង នឹងរួមចំណែកដល់ការផ្ដល់សំណងនេះ ។ មូលនិធិសំណងបានរួមចំណែកជា «ដើមទុនដំបូង» សម្រាប់ការផ្ដល់សំណងដែលការរួមចំណែកបានបង្កើតផ្នែកសំខាន់នៃសំណង ។ ជាងនេះទៅទៀត ការិយាល័យរដ្ឋបាល ដែលជាផ្នែកមួយក្នុងចំណោមផ្នែក៤របស់តុលាការ បានកត់សម្គាល់ថា ប្រសិនបើជនជាប់ចោទមិនមានថវិកា ឬមូលនិធិសំណងមិនអាចផ្ដល់ឲ្យតាមការ

បង្គាប់បញ្ជា មូលនិធិសំណងនឹងអាចលើកឡើងអំពីចំនួនថវិកាក្នុងការអនុវត្តសំណង ។ ការិយាល័យរដ្ឋបាល ជឿជាក់ថាតុលាការអាចដើរតួនាទីក្នុងការជូនដំណឹង ជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ចដំណើរនិតិវិធីផ្តល់សំណងរបស់រដ្ឋដោយអំពាវនាវឲ្យរដ្ឋរួមចំណែកដល់ការផ្តល់សំណង តាមរយៈការរួមចំណែកដោយស្ម័គ្រចិត្តរបស់ខ្លួន ។ បន្ទាប់ពីមានការលើកឡើងរបស់ការិយាល័យរដ្ឋបាលនៅក្នុងគោលការណ៍ដែលបានដាក់ចេញក្នុងសំណុំរឿង ឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិបានអំពាវនាវឲ្យរដ្ឋ, អង្គការអន្តរជាតិ, បុគ្គល, ការសហការ និងផ្នែកដទៃដើម្បីរួមចំណែកដល់មូលនិធិសំណងដើម្បីធានាឲ្យមានការផ្តល់សំណង ។

ទន្ទឹមពេលដែលមានភាពខុសប្លែកគ្នា រវាងតម្រូវការផ្នែកថវិកានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ មានសភាពតិចតួច វិធីសាស្ត្រខុសប្លែកគ្នារវាងតុលាការទាំងពីរ មានឥទ្ធិពលយ៉ាងខ្លាំងលើលទ្ធភាពរបស់សំណងក្នុងការដោះស្រាយតម្រូវការរបស់ជនរងគ្រោះ ជាជាងការប៉ងប្រាថ្នារបស់ម្ចាស់ជំនួយ ។ អំឡុងពេលដែលសំណុំរឿង ០០២/០១ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះបានធ្វើការបង្កើតផែនការសំណង និងរៃអង្គាសថវិកា ។ នៅពេលដែលបង្ហាញអំពីការទាមទារសំណងចុងក្រោយ ទាំងសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ យល់ឃើញថា ខ្លួនត្រូវតែធានាឲ្យបាននូវថវិកាដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការអនុម័តលើគម្រោងនោះ ។ ដោយសារ មានសំណើទាមទារប្រកបដោយប្រសិទ្ធភាព និងតម្រូវការសម្រាប់ថវិកា សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ ប្រហែលជាមានភាពត្រឹមត្រូវក្នុងការសន្មតថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងយល់ស្របលើគម្រោងនោះដែលមានថវិកាគ្រប់គ្រាន់ ។ ទន្ទឹមពេលដែលការរៃអង្គាសថវិកា មានអត្ថប្រយោជន៍ វិធីសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានភាពគ្រោះថ្នាក់ដល់គម្រោងអនុម័ត ដែលជ្រើសរើសដោយម្ចាស់ជំនួយ ឧទាហរណ៍ គម្រោងដែលទទួលបានថវិកា មុនសេចក្តីសម្រេចរបស់តុលាការជាជាងការដាក់អាទិភាពរបស់ជនរងគ្រោះក្នុងការបង្គាប់នូវគម្រោងសំណង ។ ទន្ទឹមពេលដែលវាជាការពិតណាស់ដែលថវិកាត្រូវបានកំណត់ ហើយសំណងដែលត្រូវបានដាក់ឲ្យអនុវត្ត នឹងពឹងផ្អែកលើថាតើវិភាគទានមានចំនួនប៉ុន្មានប្រការនេះមិនមានន័យថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែអនុញ្ញាតដល់ការធ្វើអាទិភាពដល់ការចង់បានរបស់ម្ចាស់ជំនួយលើតម្រូវការរបស់ជនរងគ្រោះតាមផ្លូវច្បាប់ ។

ការចេញសេចក្តីបង្គាប់ក្នុងដំណើរការផ្តល់សំណងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មានសារសំខាន់ដល់ការគោរពសិទ្ធិរបស់ជនរងគ្រោះ ។ ឧទាហរណ៍ ក្រោមដំណើរការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិតម្រូវការរបស់ជនរងគ្រោះត្រូវបានវាយតម្លៃ ។ មូលនិធិសំណងបានបង្កើតផែនការអនុវត្តសំណង ហើយតុលាការបានយល់ស្របជាមួយនឹងផែនការនេះ ។ ការរៃអង្គាសថវិកាបានធ្វើឡើង ក្នុងដំណើរការនោះ ប៉ុន្តែសេចក្តីសម្រេចរបស់តុលាការមិនផ្អែកលើថាតើគម្រោងមានថវិកានោះទេ ។ ប្រសិនបើមូលនិធិសំណង មិនមានថវិកានៅពេលដែលតុលាការចេញសេចក្តីសម្រេចនោះ មូលនិធិសំណងនឹងរៃអង្គាសវិភាគទានបន្ថែម ។ និតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមានអត្ថប្រយោជន៍ក្នុងការផ្តល់សំណង ដោយផ្អែកលើសាលក្រមបញ្ជាក់អំពីតម្រូវការរបស់ជនរងគ្រោះ ជាជាងសាលក្រមដែលផ្អែកលើសំណងដែលកំណត់ដោយការគាំទ្ររបស់ម្ចាស់ជំនួយ ។ ក្រៅពីនេះ ការយល់ស្របលើ គម្រោងសំណងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទំនងជាជួយរៃអង្គាសថវិកា នៅពេលដែលម្ចាស់ជំនួយ ទំនងជាគាំទ្រគម្រោងដែលបានលើកឡើងថាជាសំណងដែលបង្គាប់ដោយតុលាការដោយផ្លូវការ ។

ក្រោមក្របខណ្ឌនាពេលបច្ចុប្បន្ន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើការងារខិតខំប្រឹងប្រែងតិចតួចដល់ដំណើរការផ្តល់សំណង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមិនបង្គាប់បង្កើត ឬជំរុញគម្រោងសំណង ដែលមិនត្រូវបានកំណត់ ហើយយល់ស្របដោយម្ចាស់ជំនួយ ។ មុនពេលចេញសាលក្រម អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តល់វេទិកាសម្រាប់នាំយកជនរងគ្រោះ និងផ្នែកពាក់ព័ន្ធអន្តរជាតិ សហការក្នុងការបង្កើត និងអនុវត្តគម្រោងសំណង ។ ទោះបីជាយ៉ាងណា

ក៏ដោយ នៅពេលដែលចេញសាលក្រម គម្រោងនោះត្រូវបានកំណត់ហើយសេចក្តីសម្រេចរបស់តុលាការចំពោះគម្រោងទាំងនេះ បន្ថែមតម្លៃតិចតួចដល់ខ្លឹមសារ និងវិសាលភាពរបស់គម្រោងសំណង ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវសម្របខ្លួនទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងសំណុំរឿង ០០២ ខ្លួនអាចបន្ថែមតម្លៃដ៏សំខាន់ដល់ដំណើរការផ្តល់សំណង ។ ជំនួសឲ្យការយល់ស្របលើគម្រោងដែលកំណត់ដោយម្ចាស់ជំនួយ តុលាការអាចវាយតម្លៃ, ចេញសេចក្តីសម្រេច ហើយគាំទ្រគម្រោងអធិភាពមួយចំនួន ដែលមិនទាន់មានថវិកានៅឡើយ ហើយមានតម្លៃបន្ថែមលើការទទួលស្គាល់តម្រូវការរបស់ជនរងគ្រោះ ថ្វីបើមានការកំណត់ផ្នែកថវិកា ។

អង្គជំនុំជម្រះតុលាការកំពូល បានធ្វើការសន្យាមួយចំនួនថ្វីបើមានការចន្លុលបង្ហាញនៅក្នុងសំណុំរឿង០០១ក៏ដោយ ។ ឧទាហរណ៍នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលនឹងគាំទ្រការទាមទារសំណងថា ជាទម្រង់នៃការទាមទារសំណងដ៏ត្រឹមត្រូវសម្រាប់ការខូចខាត សូម្បីតែតុលាការមិនអាចចេញសេចក្តីបង្គាប់ឲ្យប្រតិបត្តិ ។ ឧទាហរណ៍ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលស្គាល់អំពីការផ្តល់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តសម្រាប់ជនរងគ្រោះដោយផ្ទាល់ ឬដោយប្រយោលដោយដាក់ឈ្មោះអគារតាមឈ្មោះជនរងគ្រោះ ការរៀបរាប់ពីទុក្ខវេទនារបស់ជនរងគ្រោះ, ការធ្វើពិធី រំឭកខួប, ការសាងសង់បូជនីយដ្ឋាន, ដូចជាវត្តអារាម របងវត្តអារាម, និងវិមានឯករាជ្យ ថាជាទម្រង់នៃសំណងដ៏ត្រឹមត្រូវ ។ តុលាការបានជំរុញអាជ្ញាធរជាតិ, សហគមន៍អន្តរជាតិ, និងម្ចាស់ជំនួយផ្សេងៗក្នុងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការគាំទ្រផ្នែកផ្សេងៗក្នុងការអនុវត្តសំណងទាំងនេះ ។ នៅពេលដែលសំណើសុំសំណងមិនមានភាពជាក់លាក់គ្រប់គ្រាន់ តុលាការកាន់តែមានភាពរួញរាក្នុងការគាំទ្រការទាមទារសំណង ។ ដើម្បីធ្វើដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ការទទួលស្គាល់សំណងដែលបានស្នើឡើងថាជាមធ្យោបាយផ្តល់សំណងដ៏សមស្របមួយ មានសារសំខាន់ជាទម្រង់នៃការបំពេញចិត្ត និងការកែតម្រូវដែលអាចទាញចំណាប់អារម្មណ៍កិច្ចខិតខំប្រឹងប្រែង និងធនធានផ្សេងដើម្បីសម្រេចឲ្យបាននូវការផ្តល់សំណង ។ ម្យ៉ាងវិញទៀត តុលាការបានកត់សម្គាល់ថា "ការទទួលស្គាល់ផ្លូវការ និងមុតមាំរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីសំណើទាមទារសំណងនាពេលបច្ចុប្បន្នដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ បង្កើតបាននូវទម្រង់មួយនៃសំណង ដោយមិនគិតអំពីការអនុវត្តនាពេលអនាគត ។ ទន្ទឹមពេលដែលការគាំទ្ររបស់អង្គជំនុំជម្រះតុលាការកំពូលមានតម្លៃ ការគាំទ្រទាំងនោះត្រូវបានកំណត់ដោយការជួយជនរងគ្រោះ ។

ក្នុងសំណុំរឿង០០២ តុលាការមានឱកាសផ្តល់ការការពាររឹងមាំដល់ជនរងគ្រោះ តាមរយៈការចេញសេចក្តីសម្រេចជាជាងការលើកឡើងថា គម្រោងជាអាទិភាព គួរតែបានដាក់បញ្ចូលក្នុងបញ្ជីគម្រោងដែលត្រូវអនុវត្ត ។ ដើម្បីធ្វើដូច្នេះបាន តុលាការនឹងត្រូវបង្កើតយន្តការគ្រប់គ្រងដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងសំណង ។ តុលាការអាចបង្គាប់អង្គភាពគាំពារជនរងគ្រោះ ឬផ្នែកគ្រប់គ្រងដទៃ ដូចគ្នាទៅនឹងក្រុមជំនាញរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីរៃអង្គាសថវិកា និងដោះស្រាយបញ្ហារដ្ឋបាលមួយចំនួនដើម្បីអនុវត្តគម្រោងទាំងនេះ ។ ដូចគ្នាទៅនឹងសំណុំរឿងរបស់ឡូបានហ្គា ការបង្គាប់របស់តុលាការ នឹងលើកទឹកចិត្តកាន់តែខ្លាំងដល់អង្គភាពគ្រប់គ្រងជំនាញដើម្បីរៃអង្គាសថវិកា ហើយទាមទារថា អង្គភាពគ្រប់គ្រងនេះគួរតែបន្តដើរតួនាទី រហូតដល់សំណងបង្គាប់ទាំងអស់ត្រូវបានធ្វើឡើង ។ ប្រសិនបើសំណងត្រូវបានលើកឡើង អង្គភាពគ្រប់គ្រងនឹងមានឱកាសរំលាយ មុនពេលសំណងដ៏សំខាន់ត្រូវបានធ្វើឡើង ។ ក្រៅពីនេះ ការបង្គាប់របស់តុលាការដ៏ជាក់លាក់ នឹងធ្វើឲ្យកាន់តែមានភាពងាយស្រួល ក្នុងការទាក់ទាញម្ចាស់ជំនួយសម្រាប់គម្រោងនោះ ។ ការអនុវត្តគម្រោងសំណងនឹងជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជារបៀបផ្តល់អាទិភាពដល់គម្រោង, របៀបធានាថាសំណងត្រូវបានផ្តល់ដោយ ស្មើភាពគ្នា, របៀបធានាថាអង្គភាពគ្រប់គ្រងបានដើរតួនាទីយ៉ាងមានប្រសិទ្ធភាព, និងគិតពីប្រយោជន៍ របស់ជនរងគ្រោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រឈមដ៏សំខាន់បំផុត គឺជាការព្រួយបារម្ភរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងទៅនឹងការចេញបង្គាប់ឲ្យភាគីទីពដែលមិនទទួលខុសត្រូវដើម្បីអនុវត្តសំណងដែលមិនមានថវិកា ។ ការព្រួយបារម្ភនេះនឹងក្លាយជាបញ្ហាដ៏

លំបាកបំផុត ដើម្បីដោះស្រាយមុនពេលដែលចេញសេចក្តីសម្រេចបន្តាប់សំណង ឬការបង្កើតយន្តការគ្រប់គ្រង ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះមិនគួរត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រើប្រាស់ដើម្បីទាញហេតុផលអំពីភាពបរាជ័យក្នុងការផ្តល់សំណងដល់ជនរងគ្រោះ ។

**៥) ការពិភាក្សាអំពីផ្លូវច្បាប់ និងគោលនយោបាយ ៖ តម្រូវការលើភាពជាក់លាក់ និងយន្តការគ្រប់គ្រងដើម្បីត្រួតពិនិត្យសំណងបន្ទាប់ពីចេញសេចក្តីសម្រេចក្នុងសំណុំរឿង ០០២**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែដាក់លក្ខខណ្ឌតម្រូវជាក់លាក់តិចតួចសម្រាប់គម្រោងសំណង ហើយបង្កើតគណៈកម្មការគ្រប់គ្រងដើម្បីត្រួតពិនិត្យមើលដំណើរការ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតម្រូវការជាក់លាក់សម្រាប់សំណង ។ ក្នុងដំណាក់កាលរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ សំណើឲ្យមានសំណងមួយចំនួនត្រូវបានបដិសេធដោយខ្វះភាពជាក់លាក់ ។ អង្គជំនុំជម្រះតុលាការកំពូល បានរៀបរាប់បន្ថែមអំពីតម្រូវការជាក់លាក់នៅក្នុងសេចក្តីសម្រេចខទ្ធរណ៍ក្នុងសំណុំរឿង០០១ ។ ជាថ្មីម្តងទៀត ការព្រួយបារម្ភជាចម្បងរបស់តុលាការ គឺជាសមត្ថភាពដែលត្រូវធានាថាសំណងមានប្រសិទ្ធិភាព ។ ភាពជាក់លាក់ដែលតុលាការហាក់បីដូចជាមានការព្រួយបារម្ភជាពិសេសនៅក្នុងសំណុំរឿង ០០១ គឺជាការដាក់កាតព្វកិច្ចលើភាគីទី៣ ហើយតម្រូវការលើកិច្ចការងាររដ្ឋបាលដ៏ស្មុគស្មាញ និងមានរយៈពេលវែងស្តីពីការផ្តល់សំណង ។ ឧទាហរណ៍តុលាការមិនបានផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តថាជាសំណង ដោយសារតែកិច្ចការងាររដ្ឋបាលដ៏ស្មុគស្មាញត្រូវបានតម្រូវ ។ ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យមានការសាងសង់បូជនីយដ្ឋាន ។ តុលាការបានកត់សម្គាល់ថា ការសាងសង់បូជនីយដ្ឋានបានឈ្លានពានដល់ភាពម្ចាស់ការលើដីធ្លីឯកជន និងសាធារណៈ ហើយទាមទារឲ្យមានការអនុញ្ញាតសាងសង់អាគារ ។ តុលាការបានយល់ឃើញអំពីបញ្ហាភាពម្ចាស់ការលើដីធ្លី ហើយការអនុញ្ញាតត្រូវតែបានធ្វើឡើងមុនពេលដែលសេចក្តីបន្តាប់សំណងត្រូវបានផ្តល់ ។ អង្គជំនុំជម្រះតុលាការកំពូលមានការរុញរាក្នុងការផ្តល់សំណង ដែលនឹងទាមទារឲ្យមានការគ្រប់គ្រងដ៏ស្មុគស្មាញ និងការត្រួតពិនិត្យ បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឈប់ដំណើរការ ។ ការទាមទារភាពជាក់លាក់ ត្រូវបានផ្សារភ្ជាប់ទៅនឹងកង្វល់របស់តុលាការស្តីពី “ប្រសិទ្ធិភាព” ។ អង្គជំនុំជម្រះតុលាការកំពូល បានថែងថា សំណងត្រូវតែដាក់បញ្ចូលសេចក្តីលម្អិត សមហេតុផល ហើយត្រូវតែមានភាពជាក់លាក់គ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យមានការប្រតិបត្តិ ដោយមិនចាំបាច់ទាមទារឲ្យមានសេចក្តីសម្រេចផ្នែករដ្ឋបាល និងឆន្ទានុសិទ្ធិផ្លូវរដ្ឋបាលសម្រាប់ការអនុវត្តលើសំណង ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានកត់សំគាល់ថា កង្វះខាតផ្នែកជាក់លាក់មិនមែនជាគុណវិបត្តិដ៏គ្រោះថ្នាក់នៅក្នុងសំណើសុំឲ្យមានសំណង ដរាបណាសំណើបង្ហាញថា សំណងដែលត្រូវស្វែងរកនឹងសមស្រប និងត្រូវបានបន្តាប់ប្រឆាំងទៅនឹងចុងចោទ ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថែងថា តុលាការអាចជួយដើមបណ្តឹងរដ្ឋប្បវេណី ស្វែងរកអំពីភាពជាក់លាក់នៃសំណង តាមរយៈការប្រើប្រាស់អំណាចផ្ទាល់របស់ខ្លួន ។ តុលាការមិនបញ្ជាក់ថាតើដំណើរការនេះប្រព្រឹត្តទៅយ៉ាងដូចម្តេច ក្រៅពីការកត់សម្គាល់ដែលថា ដោយអនុលោមតាមក្រមនៃនិតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា តុលាការអាចបង្ហាញភ័ស្តុតាងលើគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ។ នៅក្នុងសំណុំរឿង ០០១ តុលាការមិនដែលព្យាយាមស្វែងរកភាពជាក់លាក់បន្ថែមអំពីសំណងនោះឡើយ ។

អង្គជំនុំជម្រះតុលាការកំពូល មិនបានគាំទ្រសំណើលើសំណង ដែលមិនមានភាពជាក់លាក់នោះឡើយ ។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូល មិនបានគាំទ្រសំណើដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ដំណើរទស្សនកិច្ចប្រចាំឆ្នាំទៅកាន់បូជនីយដ្ឋាន ដោយសារតែខ្វះភាពច្បាស់លាស់ ទោះបីជាសំណើនោះគឺជាអនុសាសន៍ដែលមិនជាប់ជាកាតព្វកិច្ច ។ តុលាការបានបដិសេធមិនគាំទ្រសំណើ សុំសំណងរបស់ដើម្បីបណ្តឹងរដ្ឋប្បវេណី សម្រាប់ជំនួយផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត ដោយសារសំណើនោះមិនមានភាពរឹងមាំដើមទទួលបានការគាំទ្ររបស់អង្គជំនុំជម្រះ ។ តុលាការបានគូសបញ្ជាក់ថា សំណើខ្វះព័ត៌មាន ស្តីពីចំនួនតម្លៃសំណងនិងអត្តសញ្ញាណអ្នកដែលទទួលប្រយោជន៍ ។ មួយក្នុងចំណោមសំណើ

សុំធ្វើដំណើរទស្សនកិច្ចទៅកាន់បូជនីយដ្ឋាន ត្រូវបានចាត់ទុកថាជាគំរូដ៏ប្រសើរចំពោះការដែលមានភាពជាក់លាក់នៃសំណើតាមការស្នើសុំ ។ តុលាការបានកោតសរសើរអំពីកម្រិតនៃភាពជាក់លាក់ខ្ពស់របស់សំណើ ដែលជាការគាំទ្រ ដែលគួរឲ្យកត់សម្គាល់ តាមរយៈអ្នកដាក់ពាក្យស្នើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាំងអស់នៅក្នុងសំណុំរឿង០០១ ហើយការពិតដែលថា សហគមន៍ជនរងគ្រោះបានបង្កើតគំនិតផ្ដួចផ្ដើមរៃអង្គាសថវិការបស់ខ្លួន ។ សំណើសុំឲ្យមានសំណង រួមមានកត្តាបរិយាយដ៏សំខាន់អំពីបូជនីយដ្ឋាន, ទីតាំងនៅក្នុងស-២១, ផលប៉ះពាល់របស់សំណើលើទីតាំង ដែលទទួលស្គាល់ដោយ យូនេស្កូ និងភាពជាក់លាក់ផ្នែកបច្ចេកទេសលើការគ្រប់គ្រងលើតំបន់នោះ និងតម្លៃនៃការគ្រប់គ្រង ។ ផែនការនោះបានកត់សម្គាល់ថា បូជនីយដ្ឋានមិនគួររំខានដល់តំបន់ដែលទទួលស្គាល់ដោយយូណេស្កូ ហើយបូជនីយដ្ឋាននឹងត្រូវបានកែប្រែប្រសិនបើមានភាពចាំបាច់ក្នុងការអនុវត្តតាមការចង្អុលបង្ហាញរបស់យ៉ូណេស្កូ ។ ថ្វីបើការសាងសង់បូជនីយដ្ឋានគឺជាដំណើរការដ៏ស្មុគស្មាញ ដែលត្រូវការការចូលរួម និងការសម្របសម្រួលអំពីផ្នែកជាច្រើន និងផ្នែករដ្ឋបាល ។ តុលាការបានគាំទ្រប្រការនោះថា ជាសំណងដ៏សមស្រប ហើយបានជំរុញឲ្យផ្នែកពាក់ព័ន្ធជាតិ និងអន្តរជាតិ ដើម្បីជួយសម្របសម្រួលមធ្យោបាយដែលចាំបាច់ធ្វើឲ្យសំណងមានប្រសិទ្ធិភាព ។

តម្រូវការភាពជាក់លាក់ដ៏ស្មុគស្មាញ ដែលខុសពីបទដ្ឋានអន្តរជាតិ ។ តម្រូវការភាពជាក់លាក់ បានដាក់បន្ទុកដល់ជនរងគ្រោះដើម្បីគណនាអំពីតម្លៃផ្នែកហិរញ្ញវត្ថុ និងបង្កើតផែនការលម្អិតអំពីសំណើសំណង ។ ដើមបណ្ដឹងរដ្ឋប្បវេណី មិនមានមូលដ្ឋានដើម្បីធ្វើរឿងបែបនេះបានទេ ដោយសារតែ ភាគច្រើនខ្វះបទពិសោធដែលចាំបាច់បង្កើតផែនការសំណង ដែលបំពេញតម្រូវការផ្នែកច្បាប់ដ៏ស្មុគស្មាញ ហើយទាមទារឲ្យមានប្រវត្តិផ្នែករដ្ឋបាល, ហិរញ្ញវត្ថុ និងផែនការដ៏ស្មុគស្មាញ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានជំហប្រសើរក្នុងការស្វែងរកតម្លៃនៃគម្រោងសំណង ដែលជាសំណើ ផ្លូវច្បាប់ដ៏សំខាន់លើសិទ្ធិរបស់ភាគីទីពនិងចំណោទសួរទាក់ទងថាតើអង្គភាពអ្វីមានភាពសកសមបំផុតក្នុងការត្រួតពិនិត្យមើល គ្រប់គ្រង ចាត់ចែងគម្រោងបន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឈប់ដំណើរការ ។

តម្រូវការភាពជាក់លាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺខុសពីការអនុវត្ត របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការសិទ្ធិមនុស្សតំបន់ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានផ្ដល់អំណាចដ៏សំខាន់ដើម្បីជួយស្វែងរកសំណងសម្រាប់ជនរងគ្រោះ ។ យោងតាមមាត្រា ៧៥(១) នៃលក្ខន្តិកៈទីក្រុងរូម តុលាការព្រហ្មទណ្ឌអន្តរជាតិអាចកំណត់អំពីវិសាលភាពនៃការខូចខាត ការបាត់បង់ ការបង្កការគ្រោះថ្នាក់ដល់ជនរងគ្រោះនៅពេលដែលមានសំណើ ។ ក្រៅពីនេះ មាត្រា ៩៧(២) របស់វិធានផ្ទៃក្នុងនៃនិតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានផ្ដល់ថា តាមសំណើរបស់ជនរងគ្រោះ តុលាការអាចតែងតាំងអ្នកជំនាញសមស្របដើម្បីជួយកំណត់វិសាលភាពនៃការខូចខាត ការប៉ះពាល់ ការបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ និងត្រូវលើកឡើងអំពីជម្រើសផ្សេង ទាក់ទងទៅនឹងប្រភេទ និងគំរូដ៏សមស្របអំពីសំណង ។ នៅក្នុងសំណុំរឿងឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនបានធ្វើឲ្យខ្លួនឯងជាប់ពាក់ព័ន្ធទៅនឹងភាពជាក់លាក់នៃសំណង ។

តុលាការព្រហ្មទណ្ឌ អន្តរជាតិបានប្រមើមើលការបង្កើតគម្រោងសំណង បន្ទាប់ពីមានការជំនុំជម្រះដោយមូលនិធិសំណងជនរងគ្រោះ ។ អង្គជំនុំជម្រះសាលាដំបូង បានរៀបចំគោលការដើម្បីចង្អុលបង្ហាញអំពីការបង្កើតគម្រោងសំណង ប៉ុន្តែខ្លួនមិនបានកំណត់ភាពជាក់លាក់ ទាក់ទងទៅនឹងមាតិកា ឬថវិកា ។ តុលាការសិទ្ធិមនុស្សតំបន់ភាគច្រើន មិនសូវមានតម្រូវការភាពជាក់លាក់ដ៏ស្មុគស្មាញសម្រាប់សំណើសំណង ជាជាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។ ឧទាហរណ៍ តុលាការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស មានការទទួលខុសត្រូវក្នុងការបង្កើតដំណោះស្រាយយុត្តិធម៌ និងភាពស្មើភាពសម្រាប់ជនរងគ្រោះ ។ តុលាការអន្តរអាមេរិកកាំងទទួលបន្ទុកសិទ្ធិមនុស្ស អាចបង្កើតសំណង ដែលខ្លួនចាត់ទុកថាសមស្រប ហើយមិនត្រូវបានផ្សារភ្ជាប់ទៅនឹងសំណើដែលធ្វើឡើងដោយជនរងគ្រោះ ។

***(នៅមានត)***

**គ្រីស្ទីន ប័រគ័រលី**

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្ដើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនិងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី “សហកម្មខក្រិដ្ឋកម្មរួម” ដែលភាសាអង់គ្លេសហៅថា “Join Criminal Enterprise” ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម “ផែនការខក្រិដ្ឋរួម” ដែលភាសាអង់គ្លេសហៅថា “Common Criminal Plan” ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្ដេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្ដង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**





# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthpechet@dccam.org ។

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្ដៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។





















# តម្លៃនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា


ភួល ស្រីនាថ

ប្រទេសកម្ពុជាបាននឹងកំពុងអភិវឌ្ឍខ្លួនទៅមុខជាបណ្តើរៗ ។ ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម កម្ពុជាបានងើបខ្លួនឡើងវិញចេញពីកម្ទេចដេះដង់ធូលី ។ កន្លងផុតទៅជាងបីទសវត្សរ៍ រហូតមកដល់សព្វថ្ងៃនេះ ទើបយើងឃើញថាកម្ពុជាបានអភិវឌ្ឍសេដ្ឋកិច្ចកើនឡើងពិតមែន ដោយឃើញមានផ្លូវក្រាលដោយកៅស៊ូ និងមានរថយន្តទំនើបៗ ។ លើសពីនេះទៀត បើយើងក្រឡេកមើលទីក្រុងភ្នំពេញវិញ គ្រប់ទីកន្លែងយើងនឹងឃើញប្រជាជនកម្ពុជាប្រើប្រាស់តិចណូឡូជីទំនើប និងបច្ចេកវិទ្យាចុងក្រោយ ចំណែកយុវជននិងយុវនារីជិះម៉ូតូយ៉ាងសង្ហា ស្លៀកសម្លៀកបំពាក់តាមរបៀបកូរ៉េ ។ តើយើងនឹងមកដល់ចំណុចនេះបានយ៉ាងលឿនដោយរបៀបណា? នេះគឺដោយសារតែកម្ពុជាគឺជាប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់លឿនអាស្រ័យនឹងស្ថេរភាពនយោបាយ សុខសន្តិភាព សុវត្ថិភាព សេដ្ឋកិច្ចបើកចំហ និងលំហូរនៃមូលធនសាធារណៈ និងឯកជន ។

និយាយអំពីលក្ខខណ្ឌជីវភាពរស់នៅរបស់ប្រជាជនវិញ មានការប្រសើរឡើងជាងមុន ប្រៀបធៀបទៅនឹងស្តង់ដានៃការរស់នៅមួយសតវត្សរ៍កន្លងទៅនេះ ។ យោងតាមរបាយការណ៍សន្ទស្សន៍អភិវឌ្ឍធនធានមនុស្សរបស់កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិដែលចេញផ្សាយប្រចាំឆ្នាំ២០១២បង្ហាញថា ទសវត្សរ៍ចុងក្រោយនេះ សន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសកម្ពុជាបានកើនឡើងពី០.៤៤ភាគរយ នៅក្នុងឆ្នាំ២០០០ដល់០.៥៤ភាគរយក្នុងឆ្នាំ២០១២ ។ ការកើនឡើងតិចតួចនេះបង្ហាញពីចំណុចវិជ្ជមាននៃការផ្លាស់ប្តូររបស់រដ្ឋាភិបាលលើនិយមន័យនៃបន្ទាត់ភាពក្រីក្រដែលស្មើនឹងកម្រិតនៃអាហារូបត្ថម្ភ ២២០០កាឡូរីដែលមនុស្សម្នាក់ៗត្រូវទទួលបានក្នុងមួយថ្ងៃ ជំនួសឲ្យការវាស់ស្ទង់លើប្រាក់ចំណូលដែលប្រជាជនម្នាក់ៗទទួលបានតិចជាងមួយដុល្លារនៅក្នុងមួយថ្ងៃដើម្បីកំណត់និយមន័យនៃភាពក្រីក្រ ។ ការកើនឡើងនេះក៏បង្ហាញពីការកើនឡើងនៃអាយុរំពឹងទុកកំណើនពលកម្មការងារនិងអាត្រាអក្ខរភាព ។ល ។

បើយើងមើលទៅហាក់ដូចជាល្អណាស់មែនទេ? ហើយទាំងនេះសុទ្ធតែបង្ហាញពីសញ្ញាណវិជ្ជមានប៉ុន្តែប្រទេសកម្ពុជានៅមានការងារជាច្រើនទៀត ។ បើយើងធ្វើដំណើរប្រមាណជាមួយម៉ោងចេញពីក្រុងភ្នំពេញ យើងនឹងឃើញពីរបៀបខុសប្លែកគ្នានៃការរស់នៅរបស់ប្រជាជន ។ ប៉ុន្តែបើយើងធ្វើដំណើរឆ្ងាយបន្តទៀត យើងនឹងឃើញពីតម្លៃនៃការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ។ ឧស្សាហកម្មធំៗដូចជា ឧស្សាហកម្មកែច្នៃនិងឧស្សាហកម្មព្រៃឈើបានផលិតនូវបរិមាណច្រើនដើម្បីបំពេញតម្រូវការទីផ្សារ ក៏ប៉ុន្តែបែរជាធ្វេសប្រហែសនូវផលប៉ះពាល់ការបំផ្លិចបំផ្លាញដែលបន្សល់ទុក ដោយសារការរកប្រាក់ចំណូលនេះ ។ ធនធានធម្មជាតិត្រូវបានដកហូតដោយគ្មានការពិចារណាឲ្យបានត្រឹមត្រូវនិងឲ្យតម្លៃលើមនុស្សនិងបរិស្ថាន ។ ការសឹករេចរិលនិងការបំពុលបរិស្ថានធម្មជាតិ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះប្រទេសជាតិទាំងមូល ។ កម្ពុជាទទួលរងការប៉ះពាល់យ៉ាងខ្លាំងពីបម្រែបម្រួលបរិយាកាសជាសកល ប៉ុន្តែប្រទេសកម្ពុជាពុំមានការទប់ស្កាត់ណាមួយចំពោះបញ្ហានេះនៅឡើយទេ យើងគ្រាន់តែមើលទៅលើវិនាសកម្ម ទាំងស្រុងថ្មីៗនេះ ដោយសារព្យុះទីហ្វុងហៃយ៉ានដែលប្រទេសកម្ពុជាក៏អាចងាយរងគ្រោះដូចនេះដែរ ។ បើយើងមិនបានគិតឲ្យបានស៊ីជម្រៅចំពោះបញ្ហាបម្រែបម្រួលបរិយាកាសនេះទេ ប្រទេសកម្ពុជានឹងប្រឈមមុខទៅនឹងបញ្ហាកង្វះស្បៀង និងការប៉ះពាល់នៅក្នុងវិស័យកសិកម្ម ជាពិសេស តំបន់ដែលងាយទទួលរងគ្រោះទឹកជំនន់និងភាពរាំងស្ងួត ហើយក៏នឹងប៉ះពាល់ដល់ការទទួល

បាននូវទឹកស្អាតប្រើប្រាស់ ។ នេះគ្រាន់តែជាបញ្ហាមួយចំនួនដែលកម្ពុជាបានជួបប្រទះតិចឬច្រើន ចុងក្រោយអាចនឹងប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចដោយសារគ្រោះធម្មជាតិនៃបាតុភូតធម្មជាតិ និងភាពទន់ខ្សោយដែលមិនអាចការពារបាននូវប្រព័ន្ធអេកូឡូស៊ី ។

ចុះចំពោះមនុស្សវិញ? តាមប្រវត្តិសាស្ត្របានបង្ហាញថា មនុស្សគឺជាអ្នករងគ្រោះធ្ងន់ធ្ងរទៅលើតម្លៃនៃការអភិវឌ្ឍ ។ ពាណិជ្ជករនិងអ្នកមូលធនតែងតែកេងប្រវ័ញ្ចពីកម្លាំងពលកម្ម និងធនធានកម្រក្នុងតម្លៃថោក ។ ក្រុមហ៊ុនបរទេសធំៗព្យាយាមជ្រៀតជើងចូលក្នុងទីផ្សារការងារក្នុងប្រទេសដែលមានកម្លាំងពលកម្មថោក ដូចជាកម្ពុជាជាដើម ដូច្នេះពាណិជ្ជករទាំងនោះអាចផលិតបានច្រើនដើម្បីបំពេញតម្រូវការនិងបង្កើតនូវផលចំណេញច្រើន ក្រោមញើសឈាមពលករ តែចំណាយតិចតួចដល់ពលករទាំងនោះ ។ មើលទៅលើការធ្វើបាតុកម្មកាលពីសប្តាហ៍មុននៅស្ទឹងមានជ័យ កម្មករ-កម្មការនីរោងចក្របានប្រថុយប្រថានជីវិតធ្វើបាតុកម្មដើម្បីលាតត្រដាងនូវសម្ពាធដល់សង្គមទាំងមូល រាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិផ្សេងៗ ប៉ុន្តែជាក់ស្តែង យើងបែរជាយកចិត្តទុកដាក់បន្តិចបន្តួចប៉ុណ្ណោះលើកម្មករ-កម្មការនីទាំងនោះ ។ យើងពិតជារស់នៅស្រួលដោយឥតកង្វល់ ហើយយើងមិនបានដឹងទេថា កម្មករទាំងនេះហើយដែលជាអ្នកផ្តល់ឲ្យយើងនូវស្បែកជើងម៉ាកណៃគី **(Nike)** និងសម្លៀកបំពាក់ម៉ាកអេក្សអែនអឹម **(H&M)** ដែលមានតម្លៃថោក ។ ប្រសិនបើយើងមិនយកចិត្តទុកដាក់លើសិទ្ធិរបស់កម្មករ-កម្មការិនីទាំងនោះ ប្រហែលជាយើងនឹងយកចិត្តទុកដាក់ខ្លាំងជាងនេះនៅពេលដែលតម្លៃនៃផលិតផលទាំងអស់នេះកើនឡើងមែនទេ? ។

តើខ្ញុំបានចាប់យកនូវចំណាប់អារម្មណ៍របស់អ្នកបានហើយឬនៅ? នៅទេ! មែនទេ? ចុះចំណែកឯព្រឹត្តិការណ៍មួយនេះវិញនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ កាសែតជាភាសាអង់គ្លេសមួយបានសរសេរទាក់ទងនឹងអត្ថបទមួយនិងវីដេអូឃ្លីបមួយស្តីពីការរឹបអូសយកដីនៅខេត្តកោះកុង ។ ក្រុមហ៊ុន *Tate & Lyle Sugars* មានចម្ការស្ករអំពៅធំមួយ ហើយរាល់ផលិតផលដែលផលិតបានត្រូវនាំចេញទៅកាន់សហគមន៍អឺរ៉ុបសម្រាប់ប្រើប្រាស់ដោយសារតែនេះជាផ្នែកមួយនៃគ្រោងការពាណិជ្ជកម្មរបស់សហគមន៍អឺរ៉ុបដែលមានឈ្មោះថា «អ្វីៗទាំងអស់ស្ថិតនៅលើជំនួយសហការគ្នា» ។ យើងបាននឹងកំពុងធ្វើពាណិជ្ជកម្មជាមួយនឹងខាងទ្វីបអឺរ៉ុប ស្តាប់ទៅដូចជាអស្ចារ្យណាស់មែនទេ? ប៉ុន្តែដើម្បីឲ្យការធ្វើពាណិជ្ជកម្មនេះកើតឡើងពិតមែននោះគឺក្រុមហ៊ុនត្រូវការដីសម្រាប់ការដាំដុះ ។ ដោយសាររឿងនេះ ប្រជាជនជាច្រើនត្រូវបង្ខំចិត្តចាកចេញពីផ្ទះសម្បែងជាកន្លែងជម្រកនិងចេញពីដីរបស់ខ្លួន ។ អ្នកភូមិត្រូវចាកចេញដោយគ្មានទទួលបាននូវអ្វីទាំងអស់ តែបែរជាទៅបម្រើការឲ្យអ្នកដែលបណ្តេញខ្លួនចេញទៅវិញ ។ អ្វីដែលបានកើតឡើងនៅក្នុងខេត្តកោះកុងនេះមិនមែនជាបញ្ហាដាច់ដោយឡែកនោះទេ តែជាបញ្ហាចាំបាច់ទាក់ទងនឹងការរឹបអូសយកដីដែលកំពុងបានកើតឡើងពាសពេញផ្ទៃប្រទេស ។ វីដេអូឃ្លីបមួយដែលបានបង្ហោះលើអ៊ីនធឺណេតបានបង្ហាញប្រាប់នូវសាច់រឿងមួយរបស់ក្មេងប្រុសដែលមានអាយុ១១ឆ្នាំម្នាក់ដែលខំប្រឹងធ្វើការដប់ម៉ោងក្នុងមួយថ្ងៃដើម្បីទទួលប្រាក់ចំណូលបានត្រឹមតែមួយម៉ឺនរៀលក្នុងមួយថ្ងៃធ្វើការនៅចម្ការស្ករអំពៅ ។ ក្មេងប្រុសម្នាក់នោះធ្វើការដើម្បីជួយផ្គត់ផ្គង់ក្រុមគ្រួសារនិងនៅសល់បន្តិចបន្តួចគ្រាន់ទុកទៅសាលាបើសិនជាមានឱកាស ។ រូបភាពរបស់ក្មេងប្រុសនេះវាមិនគួរណាកើតឡើងនោះទេ ។

ខ្ញុំមានអាយុជាងម្ភៃឆ្នាំហើយ ហើយប្រសិនបើជំនាន់នេះជំនាន់ឪពុកម្តាយរបស់ខ្ញុំនៅតែបន្តរបៀបនេះ ខ្ញុំមិនប្រាកដថាតើនៅពេលអនាគតជាពិសេសចំពោះក្មេងជំនាន់ក្រោយនឹងជួបប្រទះនូវអ្វីខ្លះនោះទេ ។ យើងកំពុងតែអភិវឌ្ឍន៍ ហើយរៀបចំកសាងខ្លួនចេញពីបាតដៃទទេ ។ រូបភាពបង្ហាញពីការផុសផុលទៅមុខ ហើយជាអ្វីដែលបង្ហាញពីភាពអស្ចារ្យ តែសួរថាតើអ្នកណាជាអ្នកដែលទទួលបាននូវអត្ថប្រយោជន៍ទាំងនេះ? កម្ពុជាបាននឹងកំពុងអភិវឌ្ឍទៅរកបែបបទមួយដែលនឹងបន្សល់ទុកដល់ជំនាន់របស់ខ្ញុំនិងជំនាន់ក្រោយនូវផលប៉ះពាល់ទាំងឡាយដែលមិនបានគិតគូរតាំងពីជំនាន់ឪពុកម្តាយរបស់ខ្ញុំ ។ ដូច្នេះយើងគឺជាអ្នកដែលត្រូវកែប្រែនូវកំហុសធំៗទាំងឡាយដែលមនុស្សជំនាន់មុនបានបន្សល់ទុកពីព្រោះបើនៅតែបន្ត ចុងក្រោយ យើងនឹងមិនមានកេរដំណែលអ្វីបន្សល់ទុកដល់កូនចៅជំនាន់ក្រោយសូម្បីតែឈ្មោះរបស់យើងក៏មិនមានផង ។ **ភួល ស្រីនាថ**

# ជីវិតគ្រួសារម្តាយខ្ញុំក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ អ៊ុំ ណាត្រី កើតនៅសង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ ។ ខ្ញុំរស់នៅក្នុងក្រុមគ្រួសារមួយដែលមានសមាជិកចំនួនប្រាំមួយនាក់ដែលមានឪពុកឈ្មោះ អ៊ុំ វ៉ាន ម្តាយឈ្មោះ ជឹម កាន បងប្រុសឈ្មោះ អ៊ុំ សម្បត្តិ ប្អូនប្រុសឈ្មោះ អ៊ុំ សុធា និង ប្អូនស្រីឈ្មោះ អ៊ុំ វ៉ានី ហើយម្តាយរបស់ខ្ញុំជាកូនទីពី ។

នៅក្នុងឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំបានបាត់បង់ឪពុកជាទីស្រលាញ់ម្នាក់ ដោយសារតែគាត់មានជំងឺលើសឈាម និងចំពេលដែលប្រទេសកំពុងកើតមានសង្គ្រាម ។

មួយរយៈខ្លីប៉ុណ្ណោះ ខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ហើយបានជម្លៀសប្រជាជនដែលរស់នៅទីក្រុងទាំងអស់ឲ្យទៅតាមបណ្តាខេត្តផ្សេងៗ ។ ម្តាយខ្ញុំបានធ្វើដំណើរតាមយាយឆ្ពោះទៅស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ម្តាយខ្ញុំបានទូល និងរែករបស់ប្រើប្រាស់មួយចំនួនទៅជាមួយ ។ ម្តាយខ្ញុំបានទៅស្នាក់នៅស្រុកកៀនស្វាយបានមួយរយៈ ទើបខ្មែរក្រហមបញ្ជូនគ្រួសារគាត់ឲ្យទៅខេត្តពោធិ៍សាត់ ។ ខ្មែរក្រហមមិនឲ្យក្រុមគ្រួសារម្តាយខ្ញុំធ្វើដំណើរពេលថ្ងៃទេ គឺឲ្យធ្វើដំណើរនៅពេលយប់វិញដើម្បីកុំឲ្យស្គាល់ផ្លូវ ។ នៅពេលកំពុងជិះនៅលើឡាន ម្តាយខ្ញុំឃើញអ្នកបើកបរឈប់ឡានហើយឲ្យប្រជាជនមួយចំនួនចុះ រួចហើយក៏ធ្វើដំណើរទៅមុខទៀត ។ ទៅដល់កន្លែងមួយ ក្រុមគ្រួសារម្តាយខ្ញុំបានឡើងជិះរថភ្លើងបន្តរហូតទៅដល់ភូមិអន្លង់ជ្រៃ ឃុំ អូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

មានថ្ងៃមួយ ខ្មែរក្រហមបានចុះមកសាកសួរតាមផ្ទះប្រជាជន និងបានប្រកាសរកអ្នកដែលមានចំណេះដឹង ឬអ្នកធ្លាប់ធ្វើការធំៗក្នុងរបបចាស់ មកជួយធ្វើការអង្គការ ។ ពេលនោះ យាយរបស់ខ្ញុំបានជឿការឃោសនានោះ ក៏បានប្រាប់ពីប្រវត្តិពិតរបស់កូនប្រុសច្បង (ត្រូវជាប្រុសអ៊ំរបស់ខ្ញុំ) របស់គាត់ថាជានិស្សិត ។ ក្រៅពីនោះ ក៏មានមានមនុស្សមួយចំនួនបានជឿលើការឃោសនានេះដែរ ហើយក្រោយមកអ្នកដែលមានប្រវត្តិរូបមួយចំនួនត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។ ចំណែកអ៊ំរបស់ខ្ញុំ និងអ្នកខ្លះទៀត ខ្មែរក្រហមបានបញ្ជូនឲ្យទៅកាប់ថ្ម នៅជន្លង់កូន ។ នៅពេលកំពុងធ្វើការ ស្រាប់តែអ៊ំរបស់ខ្ញុំឈឺ ហើយអង្គការបានបញ្ជូនគាត់ទៅព្យាបាលនៅមន្ទីរពេទ្យ ។ អ៊ំខ្ញុំបានឆ្លៀតលួចសរសេរសំបុត្រ ដោយប្រាប់យាយពីជំងឺរបស់គាត់ ។ ពេលទទួលបានសំបុត្រភ្លាម យាយរបស់ខ្ញុំបានលួចទៅមើលកូន និងបានសុំយកអ៊ំត្រឡប់មករស់នៅក្នុងភូមិវិញ ។ ជំងឺរបស់អ៊ំមិនទាន់បានធូរស្បើយទេនៅពេលមកដល់ភូមិ តែខ្មែរក្រហមបានបញ្ជាឲ្យគាត់ទៅកាប់ឫស្សីវិញ ។ ពេលនោះ អ៊ំបានឃើញទំពាំងដុះល្អ ហើយដោយស្រេកឃ្លានផង គាត់ក៏កាប់យកមកផ្ទះ ។ ឃើញដូច្នេះ ខ្មែរក្រហមក៏បានចាប់គាត់វាយដំយ៉ាងខ្លាំង ដោយចោទគាត់ថា បានលួចរបស់របរអង្គការ ។ កងឈ្លបវាយរហូតដល់យាយទៅសុំអង្វរ ទើបឈ្លបព្រមដោះលែងអ៊ំមកវិញ ប៉ុន្តែជំងឺរបស់គាត់បានលាប់ឡើងកាន់តែខ្លាំង ។ មួយរយៈក្រោយមក អ៊ំប្រុសរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ និងការស្រេកឃ្លាន ។ នៅក្នុងថ្ងៃដែលអ៊ំស្លាប់ ក៏មានប្រជាជននៅក្នុងភូមិបីនាក់បានស្លាប់ដែរ ហើយអង្គការបានយកសកសពទៅកប់ក្នុងរណ្តៅតែមួយ ។

ចំណែកម្តាយខ្ញុំ ខ្មែរក្រហមបានចាត់តាំងគាត់ឲ្យលើកទំនប់ និងរែកអាចម៍គោ ប៉ុន្តែដោយសារគាត់ឈឺច្រើន ហើយនៅក្មេងទៀត ទើបខ្មែរក្រហមផ្លាស់គាត់ឲ្យមកនៅខាងចុងភៅវិញ ។ មានថ្ងៃមួយ យាយរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ ពេលដឹងដំណឹងនេះ ម្តាយខ្ញុំក៏បានសុំរបបអង្ករខាងចុងភៅមួយកំប៉ុង និងបានវេចជាយក្រមារយកមកឲ្យយាយនៅមន្ទីរពេទ្យ ។ ពេលនោះ យាយឈឺខ្លាំង ប៉ុន្តែគាត់បានយករបស់របរបន្តិចបន្តួចទៅដូរយកម្ហូប និងបាយយកមកឲ្យម្តាយខ្ញុំវិញ ។ យាយខ្ញុំចាប់ផ្តើមធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ ហើយម្តាយខ្ញុំ និងប្អូនប្រុសទីបីតែងតែមកមើលថែទាំគាត់ជាប្រចាំ ចំណែកប្អូនរបស់គាត់ម្នាក់ទៀតបានទៅលួចបូតស្រូវនៅពេលយប់យកមកបុកដាំបាយឲ្យយាយហូប ។ មានថ្ងៃមួយ ពេលម្តាយខ្ញុំ

ដាំបាយឆ្អិនរួចហើយយកទៅឲ្យយាយ ស្រាប់តែចំពេលដែលឈ្លបខ្មែរក្រហមមកឆែកមើលរកអ្នកដែលលួចហូបបាយឯកជន ។ ឈ្លបចាប់បានបាយយាយរបស់ខ្ញុំ ប៉ុន្តែដោយយាយរបស់ខ្ញុំរត់ទៅឱបជើង និងយំអង្វរទើបឈ្លបអនុញ្ញាតឲ្យគាត់ហូប ។

នៅពេលនោះដោយសារម្តាយខ្ញុំជាចុងភៅ ទើបគាត់យកបានទឹកត្រី អង្ករ ត្រីងាត កប់នៅក្នុងដីដើម្បីទុកហូប ស្រាប់តែខ្មែរក្រហមដឹងក៏មកគាស់យកវិញ ប៉ុន្តែសំណាងល្អរកមិនឃើញត្រីងាត ។ ម្តាយខ្ញុំសប្បាយចិត្តជាខ្លាំង រួច ហើយយកត្រីងាតនោះមករុំជុំវិញចង្កេះរបស់គាត់ ដើម្បីយកទៅឲ្យយាយហូប ។ ប៉ុន្តែក្រោយមក ដោយសារមានជំងឺធ្ងន់ធ្ងរយាយរបស់ខ្ញុំក៏ស្លាប់ទៅ ។

ចំណែកប្អូនស្រីពៅម្តាយខ្ញុំដែលមានអាយុទើបតែពីរឆ្នាំ ហើយរស់នៅជាមួយយាយនោះ ខ្មែរក្រហមបានបំបែកឲ្យទៅនៅកងកុមារវិញ ។ ក្រោយមក ដោយសារតែមិនមានអាហារហូបគ្រប់គ្រាន់ ទើបមីងរបស់ខ្ញុំបានស្លាប់នៅពេលនោះទៅទៀត ។

នៅក្នុងឆ្នាំ១៩៧៩ ខ្មែរក្រហមបានឲ្យគាត់ធ្វើស្រែ ដកស្ទូង ប្រូតកាត់ កាប់ដើមទន្រ្ទានខែត្រ ។ មានថ្ងៃមួយ ដោយសារម្តាយខ្ញុំអត់អាហារហូប គាត់បានលួចទៅបាចត្រី រហូតហួសម៉ោងធ្វើការ ពេលនោះខ្មែរក្រហមបានគំរាមថានឹងយកគាត់ទៅអប់រំ ។ ម្តាយខ្ញុំបានគិតនៅក្នុងចិត្តថា ប្រសិនបើយកគាត់ទៅអប់រំមែននោះគឺមានតែយកគាត់ទៅសម្លាប់មិនខាន ។ ខ្មែរក្រហមបានបណ្តើគាត់ទៅកន្លែងមួយ ប៉ុន្តែដោយសារផ្លូវធ្វើដំណើរឆ្ងាយពេក ក៏នាំគ្នាឈប់សម្រាក ។ ភ្លាមនោះ ស្រាប់តែមាននីរសារមកប្រាប់ថាមានស្ថានការមិនស្រួលទេ ទើបខ្មែរក្រហមដោះលែងម្តាយខ្ញុំដោយបានពោលពាក្យថា បានហើយ ថ្ងៃក្រោយឈប់ធ្វើអ៊ីចឹងទៀត ។ មួយរយៈក្រោយមក វៀតណាមបានចូលមកដល់ ដូច្នេះ ខ្មែរក្រហមក៏បានកៀរប្រជាជនទៅនៅព្រៃនាមវិញ ។ ម្តាយខ្ញុំបានដើរវង្វេងនៅក្នុងព្រៃអស់មួយយប់ដោយសារគេចពីវៀតណាម ។ ម្តាយខ្ញុំដើររហូតដល់ខេត្តបាត់ដំបង ហើយបានសុំការដ្ឋានចុងភៅស្នាក់នៅមួយរយៈទើបត្រឡប់មកនៅខេត្តពោធិ៍សាត់វិញ ។ នៅទីនោះ ម្តាយខ្ញុំបានសរសេរសំបុត្រ ហើយផ្ញើតាមរយៈអ្នកស្គាល់ទៅឲ្យលោកតា ជឹម ថន ដែលត្រូវជាបងប្រុសយាយខ្ញុំ ។ ពេលនោះ តាជឹម ថន បានជួលមនុស្សទៅយកម្តាយរបស់ខ្ញុំពីខេត្តពោធិ៍សាត់ ។ ម្តាយខ្ញុំបានជិះឡានទាហានវៀតណាម តែវៀតណាមបានទារយកមាសក្នុងមួយគ្រួសារចំនួន៥ជី ។ ម្តាយខ្ញុំ និងប្អូនប្រុសទីបីរបស់គាត់បានទៅសួរកផ្ទះរបស់ តាជឹម នៅស្រុកកៀនស្វាយ ។ តាជឹម មានការរន្ធត់ចិត្តជាខ្លាំង និងបានស្ទុះមកឱបម្តាយខ្ញុំ និងប្អូនប្រុសម្តាយខ្ញុំ ហើយគាត់ក៏បានសួរនាំពីសុខទុក្ខបងប្អូនម្តាយខ្ញុំពីរនាក់ទៀត ។ ម្តាយខ្ញុំបានប្រាប់ទៅគាត់វិញថា បានស្លាប់អស់ហើយនៅសល់តែគាត់ និងប្អូនប្រុសម្នាក់ប៉ុណ្ណោះ ។

រហូតមកដល់សព្វថ្ងៃនេះ ម្តាយខ្ញុំនៅតែពុំអាចបំភ្លេចបាននូវរឿងរាវឈឺចាប់ ខ្លោចផ្សា ការបែកបាកបងប្អូន និងម្តាយជាទីស្រលាញ់របស់គាត់បានទេ ។ របបខ្មែរក្រហមបានឆក់យកជីវិតយាយ និងបងប្អូនរបស់ម្តាយខ្ញុំដែលមិនបានប្រព្រឹត្តកំហុសអ្វីទាំងអស់ តែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ អស់រយៈពេលជាង៤០ឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែនៅពេលដែលរំឭកពីអតីតកាលឡើងវិញ ម្តាយខ្ញុំតែង តែបង្ហូរទឹកភ្នែករហូតដោយគាត់នឹកឃើញពីរឿងរ៉ាវរបស់គាត់ ហើយគាត់តែងតែយករឿងទាំងនោះមកប្រាប់ខ្ញុំ និងបងប្អូនរបស់ខ្ញុំ ។ **អ៊ឹុ ណាត្រី**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី “សំឡេងអំពើប្រល័យពូជសាសន៍ ៖ យុត្តិធម៌ និងការអត់ឃ្លាន” ចាក់ផ្សាយតាមស្ថានីយ៍វិទ្យុ ◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញវេលាម៉ោង១រសៀល និងម៉ោង៧និង៣០នាទីល្ងាច ◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៤រសៀល ◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

# ផេង កេង បាត់បង់ប្តីជារៀងរហូត

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានធ្វើឲ្យប្រជាជនរាប់លាននាក់បានស្លាប់ បែកបាក់ ព្រាត់ប្រាស់ ហើយខ្លះទៀតរងនូវការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តរហូតដល់សព្វថ្ងៃនេះ ។ ដោយឡែក ដំណើរជីវិតរបស់មីង ផេង កេង ក៏មិនខុសពីប្រជាជនរាប់លាននាក់ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។

មីង ផេង កេង បច្ចុប្បន្ន រស់នៅភូមិបន្ទាយស្ទោង ស្រុកស្ទោង ខេត្តកំពង់ធំ ។ គាត់បាននិយាយរៀបរាប់ទាំងក្តីឈឺចាប់ថា នៅក្នុងរបបខ្មែរក្រហមគាត់បានឆ្លងកាត់នូវការលំបាក និងទុក្ខវេទនាយ៉ាងខ្លាំង ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ជាពិសេសគាត់ត្រូវព្រាត់ប្រាស់បងប្អូន និងប្តីជាទីស្រឡាញ់ជារៀងរហូត ។

នៅឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិមុនដំបូង ខ្មែរក្រហមបានរុះរើផ្ទះ និងយករបស់របរនៅក្នុងផ្ទះគ្មានសល់ សូម្បីតែចានឆ្នាំង ស្រូវអង្ករក៏គ្មានសល់ដែរ ។ នៅឆ្នាំ១៩៧៧ ក្រុមគ្រួសាររបស់គាត់ ដែលមានរូបគាត់ កូនបីនាក់ និងឪពុកម្តាយ ព្រមទាំងប្រជាជនចំនួនបីរយគ្រួសារផ្សេងទៀតត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅភូមិរលៀបទង ស្រុកស្ទោង ខេត្តកំពង់ធំ ។ ការជម្លៀសនោះ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយករបស់របរទៅជាមួយទេ គឺយកបានតែអីវ៉ាន់ប្រើប្រាស់បន្តិចបន្តួចតែប៉ុណ្ណោះ ។ ខ្មែរក្រហមបានឲ្យគាត់ជិះរទេះគោ ដោយបែងចែកឲ្យពីរគ្រួសារជិះរទេះមួយ ។ ដោយសារតែមនុស្សច្រើនពេកជិះមិនអស់គ្នា កេង បានឲ្យឪពុកម្តាយគាត់ជិះ ចំណែកគាត់បានពរកូនដើរតាមពីក្រោយ ។ នៅពេលដែលគាត់កំពុងដើរ គាត់បានគិតក្នុងចិត្ត និងឆ្ងល់យ៉ាងខ្លាំងចំពោះរបបថ្មីមួយនេះថា ចាំបាច់ធ្វើការជម្លៀសប្រជាជនចេញពីស្រុកភូមិធ្វើអ្វី? គាត់បានត្រឹមតែនឹកឆ្ងល់ក្នុងចិត្តតែម្នាក់ឯង ប៉ុន្តែមិនដែលហ៊ានសួរ និងនិយាយជាមួយអ្នកផ្សេងទេ ព្រោះតែពេលនោះអង្គការបានគំរាមថា ប្រសិនបើមាននរណានិយាយប្រឆាំងនឹងអង្គការ អង្គការនឹងយកទៅសម្លាប់ចោលមិនខាន ។

នៅពេល កេង ទៅដល់ភូមិរលៀបទង គាត់គ្មានកន្លែងសម្រាប់ដេកទេ ដូច្នេះគាត់បាននាំកូន និងឪពុកម្តាយទៅដេកតាមសំយាបផ្ទះរបស់អ្នកភូមិ តែសំណាងល្អ ម្ចាស់ផ្ទះឲ្យកន្ទេលស្លឹកត្នោតមួយ ។ នៅទីនោះ គាត់ត្រូវធ្វើការងារនៅរោងបាយ ជួយដាំបាយ ដាំស្ល និងលាងសម្អាតជ្រូក ។

ផេង កេង រៀបការនៅអាយុ១៧ឆ្នាំ និងកំពុងពរពោះកូនទីបួន នៅពេលខ្មែរក្រហមគ្រប់គ្រងអំណាច ។ ចំណែកប្តីរបស់ កេង ឈ្មោះ ទីវ មានតួនាទីជាប្រធានសង្កាត់របស់ខ្មែរក្រហម ។ ប៉ុន្តែទោះបីជាប្តីគាត់មានតួនាទីក៏ដោយ ក៏ការងារដែលតម្រូវឲ្យគាត់ធ្វើគឺលំបាកដូចជាប្រជាជនទូទៅដែរ ។ ប្តីគាត់មានអត្តចរិតស្លូតបូត និងមានទំនាក់ទំនងល្អចំពោះអ្នកជិតខាង និងគ្រួសារ ។ នៅពេលដែលពេល កេង និយាយប៉ះពាល់ដល់អង្គការ ប្តីគាត់តែងតែហាមមិនឲ្យនិយាយទេ ដោយគាត់លើកឡើងថា គាត់ខំធ្វើការរាល់ថ្ងៃនេះដើម្បីឲ្យតែកូនៗបានរស់ប៉ុណ្ណោះ ។ ជារៀងរាល់ថ្ងៃ តែងតែមាននីរសារយកសំបុត្រមកឲ្យប្តីគាត់ឲ្យទៅប្រជុំនៅតាមភូមិ និងដើរស្រង់ជីវប្រវត្តិរបស់អ្នកភូមិ ។ ប្តីគាត់បានចេញទៅធ្វើការនៅពេលព្រឹក រហូតដល់ពេលល្ងាចទើបត្រឡប់មកដល់ផ្ទះវិញ ។ ប៉ុន្តែមានថ្ងៃមួយ វេលាប្រហែលជាម៉ោង៥ល្ងាច នៅឆ្នាំ១៩៧៧ នីរសារបានយកសំបុត្រមកឲ្យប្តីគាត់ថា អង្គការឲ្យទៅប្រជុំនៅភូមិអង្គតាសោម នៅវេលាម៉ោង៨ព្រឹកស្អែករួមជាមួយមិត្តរបស់គាត់ម្នាក់ឈ្មោះមិត្ត តែន ដែលធ្វើការនៅឃុំជាមួយគ្នា ។ កេង មិនបានដឹងថា អង្គការឲ្យប្តីគាត់ទៅប្រជុំក្នុងគោលបំណងយកទៅសម្លាប់ចោលនោះទេ ។ ចាប់តាំងពីពេលនោះ ប្តីគាត់មិនឃើញត្រឡប់មកផ្ទះវិញទេ ។ ពេលនោះបងបង្កើតរបស់ កេង បានសួរ កេង ថា ហេតុអ្វីមិនឃើញ អាទីវ ប្តីឯងត្រឡប់មកវិញ បើមិត្តតែនដែលទៅជាមួយនោះត្រឡប់មកវិញហើយ ។ នៅពេលនោះដែរ នីរសាររបស់គាត់ឈ្មោះ ឡី បានជួយដើររកនៅសង្កាត់ស្ទោង តែរកមិនឃើញ ។ នៅពេលនោះ កេង បានស្រែកយំយ៉ាងខ្លាំង

ព្រោះមិនឃើញប្តី ហើយចាប់ពីរៀបការជាមួយគ្នាមក ប្តីគាត់មិនដែលប្រើពាក្យអាក្រក់ និងឈ្លោះប្រកែកជាមួយគាត់ទេ ។ កេង បានខំប្រឹងរស់ដោយពរពោះកូន៨ខែ និងត្រូវចិញ្ចឹមកូនតូចៗទៀត ។

ជារៀងរាល់យប់ កេង តែងតែដេកយំខ្សឹកខ្សួល ប៉ុន្តែទោះជាយ៉ាងណាតែងតែមានកងឈ្លបលបចាំស្តាប់នៅខាងក្រោមផ្ទះរបស់គាត់ ។ ឈ្លបបានតាមដានគាត់ បន្ទាប់ពីប្តីរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។

នៅឆ្នាំ១៩៧៧ វេលាម៉ោង៤រសៀល កេង បានឈឺពោះឆ្លងទន្លេកូនទីបួន ។ ពេលនោះ អង្គការបានបញ្ជូនគាត់ឲ្យទៅដេកនៅមន្ទីរពេទ្យ ប៉ុន្តែគាត់បានបដិសេធ ដោយសុខចិត្តនៅសម្រាលកូនជាមួយឈ្មបភូមិម្នាក់ឈ្មោះ ម៉ា គៀន ។ កេង គិតថាទោះបីជាគាត់ត្រូវស្លាប់ក៏ដោយឲ្យតែបានស្លាប់ក្បែរឪពុកម្តាយ បងប្អូនម៉្យាងទៀត នៅមន្ទីរពេទ្យមានសុទ្ធតែពេទ្យក្មេងៗ ដែលមិនបានបណ្តុះបណ្តាលត្រឹមត្រូវ ។ ក្រោយពេលគាត់ទើបសម្រាលកូនបានរយៈពេលមួយខែ អង្គការបានចាត់តាំងគាត់ឲ្យទៅធ្វើការនៅរោងបាយ ដាំស្ល និងចិញ្ចឹមជ្រូក ។ នៅយប់មួយ ដោយសារតែគាត់គិតច្រើនពេក ទើបធ្វើឲ្យគាត់ទាស់ បណ្តាលឲ្យគាត់មិនអាចទៅធ្វើការបាន ។ នៅកំឡុងឆ្នាំ១៩៧៩ ពេលដែលរបបខ្មែរក្រហមដួលរលំ កេង បាននាំឪពុកម្តាយព្រមទាំងកូនចំនួនបួននាក់ ត្រឡប់មកស្រុកកំណើតវិញ ។ ប៉ុន្តែគួរឲ្យសោកស្តាយផ្ទះរបស់គាត់ត្រូវគ្រាប់ផ្លោង និងឆេះខ្ទេចខ្ទីអស់ ។

កេង បានបាត់បង់ប្តីជាទីស្រឡាញ់ និងទ្រព្យសម្បត្តិទាំងអស់ ។ ដូច្នេះ ដើម្បីបំបាត់ការឈឺចាប់ គាត់បានទៅបួសធ្វើជាដូនជីនៅអាយុ៣០ឆ្នាំ ។ ការឈឺចាប់ និងរឿងរ៉ាវដែល កេង បានជួបប្រទះ មិនខុសប្លែកពីប្រជាជនខ្មែរទាំងអស់ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមទេ ។ **ភោ សែប**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាឡឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី និងប្រទេសអង់គ្លេស ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជាដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*





# ហម រុំ : ខ្មែរក្រហមសម្លាប់ប្តីខ្ញុំ

ហម រុំ អាយុ៥៨ឆ្នាំ មានស្រុកកំណើតនៅភូមិកំពង់ស្រឡៅ ឃុំកំពង់ស្រឡៅ១ ស្រុកឆែប (នៅក្នុងសម័យសង្គមរាស្ត្រនិយម ស្រុកជូនទុន ក្រោយមកខ្មែរក្រហមប្តូរឈ្មោះទៅជាស្រុកឆែប) ខេត្តព្រះវិហារ ។ សព្វថ្ងៃ រុំ មានតួនាទីជាក្រុមប្រឹក្សាឃុំ ទទួលបន្ទុកស្ត្រីនិងកុមារ និងធ្វើស្រែចម្ការ ។ ឪពុករបស់ រុំ ឈ្មោះ ហម ស៊ុំ ធ្លាប់ធ្វើជាទាហានកាលពីសម័យសង្គមរាស្ត្រនិយម ។ សព្វថ្ងៃនេះ ឪពុករបស់គាត់បានបួសជាព្រះសង្ឃ ។ ម្តាយរបស់គាត់ឈ្មោះ ដូ ស៊ី ស្លាប់នៅឆ្នាំ១៩៨៩ ។ រុំ មានបងប្អូនបីនាក់ ស្លាប់អស់ពីរនាក់ ។ ប្អូនប្រុសរបស់គាត់ឈ្មោះ ហម ញ៉ាំង ក្រោយពីរបបខ្មែរក្រហមដួលរលំ បានចូលធ្វើជាទាហានសាធារណរដ្ឋប្រជាមានិតកម្ពុជា តែត្រូវគ្រាប់របស់ខ្មែរក្រហមស្លាប់ក្នុងឆ្នាំ១៩៨៤ ។ ចំណែកបងប្រុសរបស់គាត់ស្លាប់ដោយសារជំងឺនៅពេលថ្មីៗនេះ ។

រុំ បានរៀបរាប់ថា ខ្មែរក្រហមបានចូលកាន់កាប់ភូមិកំពង់ស្រឡៅតាំងពីឆ្នាំ១៩៧០មកម្ល៉េះ ។ បន្ទាប់មក ខ្មែរក្រហមធ្វើចលនាឃោសនា និងជំរុញឲ្យប្រជាជនធ្វើការលះបង់ និងចាកចេញពីក្រុមគ្រួសារ ដើម្បីចូលរួមបម្រើបដិវត្តន៍នៅមន្ទីរស្រុកជូនទុន ឬហៅថាមន្ទីរ-គ៣ ។ រុំ ក៏បានចូលរួមជាមួយអង្គការដែរ និងបានធ្វើចលនាទាក់ទាញមិត្តភក្តិ ប្រជាជននៅក្នុងភូមិឲ្យចូលមកខាងខ្មែរក្រហម ។ ដោយសារនៅខណៈនោះ អាមេរិកបានធ្វើការទម្លាក់គ្រាប់បែក ដូច្នេះសកម្មភាពប្រជាជនចូលបដិវត្តន៍ ក៏កាន់តែច្រើនដែរ ។ បន្ថែមលើនេះ ខ្មែរក្រហមក៏បានរៀបចំក្រុមសិល្បៈចម្រៀង រាំ ដើម្បីផាយ ស្រួលក្នុងការទាក់ទាញយុវជនក្មេងៗទៀត ។

នៅឆ្នាំ១៩៧១ អង្គការបញ្ជូន រុំ ឲ្យទៅរៀនផ្នែកពេទ្យទៅនៅមន្ទីរបឹងស្នាយ ខេត្តកំពង់ចាម ។ អ្នកគ្រប់គ្រងមន្ទីរពេទ្យបឹងស្នាយឈ្មោះ សាត ជាពេទ្យដែលមកពីខាងភូមិភាគនិរតី ។ សាត មានតួនាទីបង្រៀនដោយផ្ទាល់ដល់សិស្សនៅទីនោះ ។ រុំ និយាយដោយហួសចិត្តថា ការរៀនពេទ្យក្នុងសម័យខ្មែរក្រហម មានរយៈពេលតែប្រាំមួយខែប៉ុណ្ណោះ ។ បន្ទាប់ពីរៀនចប់ អង្គការក៏បែងចែកសិស្សទាំងនោះទៅតាមតំបន់ផ្សេងៗ ។

នៅចន្លោះឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៣ រុំ បានត្រឡប់មករស់នៅមន្ទីរ-គ៣ វិញ ដោយមាន តួនាទីជាពេទ្យទាហាន ។ រុំ ទទួលបន្ទុកចាក់ថ្នាំឲ្យអ្នកជំងឺ បង្កើតកូនឲ្យកម្មាភិបាលនៅក្នុងអង្គភាព និងប្រជាជនផ្សេងៗទៀត ។ រុំ និយាយថា គាត់មិនពិបាកទេសម្រាប់ការងារពេទ្យ ដោយសារតែមានថ្នាំមួយប្រភេទប៉ុណ្ណោះសម្រាប់ចាក់ឲ្យអ្នកជំងឺ ។ នៅអំឡុងឆ្នាំនោះដែរ ប្រជាជន និងកងទ័ពដែលមានជំងឺគ្រុនចាញ់ រួមទាំងអ្នករបួសពីសមរភូមិបានដឹកមកមន្ទីរពេទ្យកាន់តែច្រើន ធ្វើឲ្យការងាររបស់ រុំ កាន់តែមមាញឹក ។ រុំ បានបំពេញការងាររហូតដល់គាត់អស់កម្លាំង ហើយដួលសន្លប់ដោយមិនដឹងខ្លួន ក្រោយពីដឹងខ្លួន ផន គណៈមន្ទីរ-គ៣ បានដកគាត់ឲ្យទៅនៅកងចល័តស្រុកវិញ ។ នៅទីនោះ រុំ ទទួលបន្ទុកត្រួតពិនិត្យកងនារីផ្នែកតម្បាញ កាត់ដេរខោអាវ ជូនយុទ្ធជន ។

រុំ បានរៀបការក្នុងឆ្នាំ១៩៧៤ ដោយ ផន ជាអ្នករៀបចំផ្សំផ្គុំជាមួយប្អូនប្រុសរបស់ខ្លួនឈ្មោះ ជុង ភី ដែលមានតួនាទីជាប្រធានកងពលក្នុងភូមិភាគឧត្តរ ។ រុំ មិនដែលបានស្គាល់កូនកំលោះនោះពីមុនមកទេ គាត់ទើបតែឃើញមុខគ្នាក្នុងថ្ងៃរៀបការប៉ុណ្ណោះ ។ ក្នុងពិធីមង្គលការមិនមានការចូលរួម សូម្បីតែឪពុកម្តាយ បងប្អូនរបស់ រុំ ។ អង្គការចាត់ចែងឲ្យ រុំ ឡើងប្តេជ្ញាចំពោះមុខអង្គការ រួចសន្មត់ថាចប់កម្មវិធីមង្គលការឥតខាន់ស្លា ។ រុំ និងគ្រួសាររបស់គាត់មិនទាន់បានមើលមុខគ្នាច្បាស់លាស់ផង អង្គការចេញលិខិតបញ្ជាឲ្យប្តីរបស់គាត់ទៅវាយខ្មាំង នៅខេត្តកំពង់ធំ ។

ក្នុងនាមជាប្អូនថ្លៃរបស់គណៈមន្ទីរ-គ៣ និងជាប្រពន្ធរបស់ប្រធានកងពល រុំ ត្រូវអង្គការតម្លើងតួនាទីជាអនុប្រធានកងនារីស្រុក ។ ប៉ុន្មានខែក្រោយមក អង្គការស៊ើបការណ៍ដឹងថា បងថ្លៃរបស់ រុំ ជាខ្មាំង និងជាខ្សែក្បត់មកពីវៀតណាមចូលមករំដោះ

កំពង់ស្រឡៅ និងខេត្តព្រះវិហារ ។ ចំណែកប្តីគាត់ បញ្ឈរជើង ប្រហែលមួយខែ (នៅក្នុងអំឡុងឆ្នាំ១៩៧៦) និងបានទម្លាក់ឋានៈ ប្តីរបស់គាត់ពីប្រធានកងពល មកត្រឹមប្រធានវរៈសេនាតូចវិញ ។ នៅពេលនោះ សូម្បីតែ រ៉ុំ ខ្លួនឯងក៏អង្គការដកចេញពីអនុប្រធាន កងនារីស្រុក ឲ្យទៅនៅមន្ទីរតម្បាញស-២៨ នៅដូនទុនរយៈពេល មួយ ឆ្នាំដែរ ។

ចន្លោះឆ្នាំ១៩៧៦ ដល់១៩៧៧ អង្គការបានផ្លាស់ រ៉ុំ ទៅ រស់នៅជាមួយប្តីរបស់គាត់ក្នុងកងវរៈសេនាតូច នៅវាំងញ៉ាង ដោយគាត់មានតួនាទីជាអ្នកដាំបាយឲ្យប្តី និងជួយព្យាបាលនៅ ពេលមានអ្នករបួសច្រើន ។ នៅខែមេសា ឆ្នាំ១៩៧៨ អង្គការបាន ហៅប្តីរបស់គាត់ឲ្យទៅរៀនសូត្រ ។ ដោយដឹងខ្លួនមុន ប្តីរបស់ រ៉ុំ ក៏ផ្តាំផ្ញើ រ៉ុំ ថា «ប្របើសិនបើមិនឃើញគាត់ត្រឡប់មកវិញទេ ឲ្យ រ៉ុំ នាំកូនរត់ចូលទៅប្រទេសឡាវ ព្រោះពេលនេះប្តីគាត់ដឹងថា អង្គការ យក ស៊ឹម ដែលជាអនុប្រធានកងវរៈសេនាតូច នៅជ័យសែន ទៅមុនហើយ» ។ ប្តីរបស់ រ៉ុំ បានបាត់ខ្លួនតាំងពីពេលនោះមក ។

នៅខែកក្កដា ឆ្នាំ១៩៧៨ អង្គការបានមកហៅ រ៉ុំ និងស្ត្រី ដទៃទៀត ដែលប្តីត្រូវអង្គការយកទៅរៀនសូត្រកាលពីរបីខែមុន ថាឲ្យទៅតាមប្តីនៅទំនប់កំពីងពួយ ។ នៅតាមផ្លូវ រ៉ុំ បានឮយោធា ជជែកគ្នាថា តាស៊ី ប្រធានយោធាភូមិភាគ ក៏ត្រូវអង្គការចាប់ខ្លួន ដែរ ព្រោះអង្គការមិនទុកចិត្ត ។ រ៉ុំ ធ្វើដំណើររហូតដល់ស្រុក ក្រឡាញ់ ខេត្តសៀមរាប ដោយសង្ឃឹមថានឹងបានជួបជាមួយប្តី វិញ ។ ពេលឈប់សម្រាកនៅក្រឡាញ់ ស្រាប់តែ រ៉ុំ ឮយោធា និយាយអំពីការដោះលែងអ្នកទោស រ៉ុំ និងអ្នកផ្សេងទៀតនាំគ្នា រង់ចាំមើលក្រែងបានឃើញប្តីរបស់គាត់វិញ ។ អ៊ីដែល រ៉ុំ សង្ឃឹម ខ្លាំង ប្រែជាអស់សង្ឃឹមស្ទើរទប់ខ្លួនមិនជាប់ ព្រោះអ្នកផ្សេងបាន ឃើញប្តីរបស់ខ្លួនត្រឡប់មក ចំណែកគាត់បែរជាបាត់ប្តី ជា ហេតុធ្វើឲ្យកូនរបស់គាត់ដែលទើបមានអាយុ២ឆ្នាំសួររកឪពុក ដោយសួរគាត់ថា "ម៉ែ! ណាពុកយើង" ។ រ៉ុំ បានត្រឹមតែស្រក់ទឹក ភ្នែក ដោយឆ្លើយតបនឹងសំណួររបស់កូនមិនរួច ។ អ្នកទោស ម្នាក់ដែលអង្គការដោះលែង ហើយដែលធ្លាប់រស់នៅភូមិជាមួយ រ៉ុំ និយាយប្រាប់ រ៉ុំ ថា «ប្តីរបស់មិត្តឯង អង្គការយកទៅដាក់កន្លែង ផងនឹតហើយ» ហើយអង្គការឃាមទាំងយប់ទាំងថ្ងៃ ។ ដោយអស់ សង្ឃឹម រ៉ុំ ក៏បានស្នើសុំប្រធានសហករណ៍ត្រឡប់មកខេត្តព្រះវិហារ វិញ ។ ប្រធានសហករណ៍ និយាយថា បើមិត្តឯងរកផ្លូវទៅផ្ទះ ឃើញក៏ទៅចុះ ។ ភ្លាមនោះ រ៉ុំ ឆ្លើយតបទៅវិញថា មិនពិបាក នោះទេគ្រាន់តែទៅវិញនោះ ។ សំណាងល្អ ពេល រ៉ុំ ដើររកផ្លូវ ត្រឡប់មកផ្ទះ វិញក៏ស្រាប់តែឃើញឡានដឹកជញ្ជូនអង្ករទៅខេត្ត ព្រះវិហារ ។ អ្នកគ្រប់គ្រងឡាននោះឈ្មោះ ជាតិ ជាមិត្តរួមថ្នាក់ជា មួយគាត់កាលពីក្មេងបានអនុញ្ញាតឲ្យគាត់ទៅជាមួយរហូតមកដល់ ផ្ទះរបស់គាត់នៅភូមិគោក ឃុំស្អាង ស្រុកជ័យសែន ។

រហូតជិតដល់ថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ខ្មែរក្រហម បានមកកៀរប្រជាជន តាមវាលស្រែឲ្យឡើងទៅលើភ្នំមុំបី (ស្ថិត នៅជាប់ព្រំប្រទល់ប្រទេសខ្មែរ ឡាវ និង ថៃ) ។ ប៉ុន្តែ រ៉ុំ មិនព្រម ឡើងទៅទេ គាត់ថែមទាំងនិយាយទៅកាន់ក្រុមយោធាខ្មែរក្រហម វិញថា «ខ្ញុំមិនឡើងទេ យកប្តីខ្ញុំទៅសម្លាប់បាត់ហើយ ឲ្យខ្ញុំឡើង ទៅធ្វើស្អីទៀត» ។ ប៉ុន្មានថ្ងៃក្រោយមក កងទ័ពវៀតណាម ចូល មកដល់ ចំណែកកម្មាភិបាលខ្មែរក្រហមភាគច្រើនដែលមកពីខាង និរតីក៏រត់ឡើងភ្នំ ដោយបន្សល់ទុកកូនចៅនៅតាមផ្លូវ ។ រ៉ុំ បន្ថែម ទៀតថា ការប្រមូលផ្តុំគ្នារត់ឡើងភ្នំនេះ ដើម្បីជាការគេចខ្លួន និង បង្កកម្លាំងឡើងវិញ ព្រោះ តាម៉ុក ស្ថិតនៅលើភ្នំស្រាប់ ។ រ៉ុំ បន្តថា ការមកជុំគ្នានៅត្រង់ភូមិសាស្ត្រភ្នំនេះ ជាយុទ្ធសាស្ត្រល្អសម្រាប់ ខ្មែរក្រហមវាយបកទៅលើទាហានវៀតណាមវិញ ។ ចំណែក រ៉ុំ ក៏បានត្រឡប់ មកភូមិកំណើតវិញ ។

**មីន សាណាស់**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាម គេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបាន តាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ．ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# រឿងរ៉ាវរបស់ ឈុន វ៉ាត

អ៊ំប្រុស ឈុន វ៉ាត អាយុ៦៦ឆ្នាំ ជាកសិកររស់នៅភូមិព្រៃកប្បាស ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

ឈុន វ៉ាត បានរៀបរាប់ពីការចងចាំរបស់គាត់ថា នៅមុនឆ្នាំ១៩៧០ ក្នុងសម័យសង្គមរាស្ត្រនិយមគាត់ប្រកបមុខរបរធ្វើស្រែ ។ រហូតដល់ឆ្នាំ១៩៧០ នៅពេលដែលមានរដ្ឋប្រហារនៅទីក្រុងភ្នំពេញ ស្ថានភាពភូមិឃុំរបស់គាត់ស្រាប់តែមានការប្រែប្រួល ។ ប្រជាជននៅជនបទជាច្រើនបានប្រមូលគ្នាឡើងទៅធ្វើបាតុកម្ម តែត្រូវបានបង្ក្រាបពីទាហានសាធារណៈរដ្ឋរបស់សេនាប្រមុខ លន់ នល់ ។ ចាប់តាំងពីពេលនោះមក ស្ថានភាពអសន្តិសុខនៅក្នុងភូមិរបស់គាត់កាន់តែអាក្រក់ទៅៗ ។

ក្រោយពីព្រឹត្តិការណ៍រដ្ឋប្រហារ ក៏មានការទម្លាក់គ្រាប់បែកមកលើតំបន់ដែលគាត់រស់នៅពីសំណាក់សហរដ្ឋអាមេរិកដែលបានធ្វើឲ្យមនុស្ស រងគ្រោះថ្នាក់និងបាត់បង់ជីវិតអស់ជាច្រើននាក់ ។ ដោយសារការទម្លាក់គ្រាប់បែក និងការប្រយុទ្ធគ្នាកាន់តែសាហាវឡើងៗ បានធ្វើឲ្យប្រជាជនមានការភ័យខ្លាចគ្រប់ៗគ្នា គ្រួសារខ្លះបានសម្រេចចិត្តរត់ទៅនៅតំបន់ផ្សេង ខ្លះរត់ចេញពីផ្ទះទៅសម្ងំលាក់ខ្លួននៅក្នុងព្រៃ ។ ឈុន វ៉ាត បានរាប់រៀបរាប់បន្តថា គាត់និងក្រុមគ្រួសារមិនខុសពីប្រជាជនក្នុងភូមិប៉ុន្មានទេ គឺមានការភ័យខ្លាចយ៉ាងខ្លាំង ។ គាត់បានទៅកាប់ដើមត្នោតដើម្បីយកមកធ្វើត្រង់សេ ដើម្បីរត់ចូលទៅលាក់ខ្លួនពេលព្យន្តហោះហោះមកទម្លាក់គ្រាប់ម្តងៗ ។

រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបការទម្លាក់គ្រាប់បែកមានការស្ងប់ស្ងាត់ទៅវិញ ។ ឈុន វ៉ាត នៅចងចាំថានៅថ្ងៃដដែលនោះគឺជាថ្ងៃដែលទ័ពខ្មែរក្រហមបានយកជ័យជម្នះ



កងចល័តខ្មែរក្រហមសម្អាតស្មៅ

លើរបបសាធារណរដ្ឋខ្មែរ ។ គាត់គិតថា ប្រទេសកម្ពុជាប្រាកដជាមានសន្តិភាពជាក់ជាមិនខាន ក្រោមការគ្រប់គ្រងរបស់របបថ្មី ។ តែផ្ទុយពីការរំពឹងគិតរបស់គាត់ទាំងស្រុង នៅឆ្នាំនោះគាត់បានឃើញប្រជាជនជាច្រើនត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំឲ្យទៅនៅភូមិឃុំដែលគាត់រស់នៅ ។ ប្រជាជនថ្មី ឬប្រជាជន១៧មេសាដែលទើបមកដល់ថ្មីទាំងនោះ ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការយ៉ាងលំបាក និងបានបាត់ខ្លួននៅពេលក្រោយមកទៀត ។ ប្រជាជនមួយចំនួនទៀត ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅទៅស្រុកបាទី ។ ដោយឡែក ឈុន វ៉ាត ខ្មែរក្រហមមិនបានជម្លៀសកន្លែងផ្សេងទេ គឺនៅធ្វើការនៅក្នុងភូមិឃុំដដែល ។ គាត់បានបន្ថែមថា មុនដំបូង ខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនហូបបាយ និងធ្វើការរៀងខ្លួន ។ មកដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបង្កើតឲ្យមានសហករណ៍រួម ។ ប្រជាជនជាច្រើនមិនពេញចិត្តនឹងការធ្វើបែបនេះទេ ដោយយល់ថាជាការមិនត្រឹមត្រូវ ជាពិសេសប្រជាជនដែលមានជីវភាពធូរធារ ។ ទោះបីជាយ៉ាងនេះក្តី ក៏ប្រជាជនទាំងនោះនៅតែមិនហ៊ានតវ៉ានឹងការបញ្ជារបស់អង្គការដែរ ព្រោះអង្គការជាម៉ែឪរបស់យើងរាល់គ្នា ។ អង្គការឲ្យធ្វើយ៉ាងណាប្រជាជនទាំងនោះត្រូវតែធ្វើដូច្នេះដែរ មិនអាចប្រកែកបានទេ ។ ថ្វីត្បិតតែខ្មែរក្រហមមិនបានជម្លៀស ឈុន វ៉ាត ទៅតំបន់ផ្សេងក៏ពិតមែន តែគាត់ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរ និងស្ទើរតែគ្មានពេលសម្រាក ។

គាត់ត្រូវបានខ្មែរក្រហមបានបញ្ចូលទៅក្នុងកងចល័ត ហើយមានម្តងនោះគាត់ត្រូវខ្មែរក្រហម បញ្ជូនឲ្យទៅធ្វើការនៅអង្គរបុរីដែលមានចម្ងាយប្រមាណ១៥គីឡូម៉ែតពីផ្ទះរបស់គាត់ដោយអង្គការតម្រូវឲ្យគាត់ដើរ ។ នៅទីនោះអង្គការ តម្រូវឲ្យភ្ជួរស្រែ លើកភ្លឺ លើកទំនប់ និងជីកប្រឡាយ ។ ពីមួយថ្ងៃទៅមួយថ្ងៃការងាររបស់គាត់កាន់តែលំបាកទៅៗ ចំណែកការហូបចុកក៏កាន់តែតិចទៅៗ មានតែហូបបបររាវៗតែប៉ុណ្ណោះ ។ នៅពេលដែលប្រជាជនមានជំងឺហើម ដោយសារកង្វះជីវជាតិ គឺមានតែថ្នាំអាចម៍ទន្សាយ និងទឹកដូងសម្រាប់ព្យាបាលតែប៉ុណ្ណោះ ។ ឈុន វ៉ាត រំឭកថា កាលជំនាន់ នោះគាត់ធ្លាប់មានជំងឺគ្រុនចាញ់ តែជាសំណាងល្អ គាត់បានជា និងមានជីវិតមកដល់សព្វថ្ងៃ ។

ក្រោយពីរបបខ្មែរក្រហមបានដួលរលំទៅ ឈុត វ៉ាត នៅចង់ចាំរឿងរ៉ាវជូរចត់ និងការចង់ចាំជាច្រើន ដូចជា ការបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរ ការហូបចុកមិនគ្រប់គ្រាន់ និងការបាត់បង់សាច់ញាតិ ។ សព្វថ្ងៃ ឈុន វ៉ាត រស់នៅជាមួយប្រពន្ធ និងកូនប្រាំពីរនាក់ ។ វ៉ាត់ បានបន្តថា គាត់មិនចង់បាត់បង់សាច់ញាតិទេ តែខ្មែរក្រហមបានសម្លាប់បងប្អូនរបស់គាត់ ។ ដូច្នេះហើយ សាលាក្តីខ្មែរក្រហម ពិតជាមានសារសំខាន់ណាស់មិនត្រឹមតែជួយរកយុត្តិធម៌ដល់ជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងបង្ហាញឲ្យយើងឃើញថាទោះបីជានរណាក៏ដោយ មានអំណាចយ៉ាងណាក៏ដោយ ឲ្យតែមានកំហុស គឺត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ដោយមិនអាចគេចវេសបានទេ ។ **រ៉េត ណៃហ៊ីរ**

## ដំណឹងសួររកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ឹន ស៊ី ស្នាក់នៅផ្ទះលេខ៤៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសសួររកឈ្មោះ អៀវ ទៀងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅភូមិក្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ពីមុន ទៀងហាវ គឺជាសាស្ត្រាចារ្យរូបវិទ្យា-គីមី នៅវិទ្យាល័យអង្គរ ទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ទៀងហាវ និងភរិយាឈ្មោះ គួច សាយទៀង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ទៀងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ទៀងហាវ និងភរិយាបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនរគនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០ ១២ ៩៥៨ ៥៤៦ ឬ អ៊ីមែល nhansy04@yahoo.com ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ *truthkokthay@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 169, January 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.